## រាជរដ្ឋាភិបាលកម្ពុជា

### គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
### នៅថ្នាក់ក្រោមជាតិ ( គ.ជ.អ.ប )

# កម្រង

# មេរៀនបទពិសោធន៍ល្អៗមួយចំនួន
# ដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ

**រៀបចំចងក្រងដោយលេខាធិការដ្ឋាន គ.ជ.អ.ប**

**គាំទ្រដោយកម្មវិធីកំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល (DAR)**

**ខែមេសា ឆ្នាំ២០២០**

# មាតិកា


អារម្ភកថា .......... i

១. ការដោះស្រាយករណីរំលោភបំពានផ្លូវភេទលើកុមារ .......... 1

២. ការរៀបចំសណ្តាប់ធ្នាប់ជុំវិញផ្សារបាណន់ .......... 3

០៣. ការពង្រឹងការគ្រប់គ្រងសំណល់ និងអនាម័យបរិស្ថាន .......... 6

៤. ការរៀបចំសណ្តាប់ធ្នាប់សាធារណៈនៅផ្សារបរវេល .......... 8

៥. ការរៀបចំទីតាំងលក់ដូរដើម្បីបញ្ចៀសការលក់ដូរនៅតាមដងផ្លូវ .......... 11

៦. ការបង្កើតមគ្គុទ្ទេសក៍សិក្សាសហគមន៍ .......... 13

៧. ការដោះស្រាយផលប៉ះពាល់ពីការបង្ហូរកាកសំណល់ និងក្លិនស្អុយពីកសិដ្ឋានចិញ្ចឹមជ្រូក .......... 15

៨. ការលើកកម្ពស់ការយល់ដឹងអំពីការសម្អាតដៃនៅតាមសាលាបឋមសិក្សា .......... 18

៩. រៀបចំយុទ្ធនាការយល់ដឹងពីការគ្រប់គ្រងសំរាម សំណល់រឹង .......... 21

១០. ការលើកកម្ពស់ការយល់ដឹងអំពីការផ្តល់សេវានៅការិយាល័យច្រកចេញចូល តែមួយ និង ការិយាល័យប្រជាពលរដ្ឋ .......... 24

១១. ការអភិវឌ្ឍន៍មគ្គុទ្ទេសក៍សិក្សាសហគមន៍ .......... 27

១២. ការលើកកម្ពស់អនាម័យ និងសុវត្ថិភាពចំណីអាហារនៅសាលារៀន .......... 29

១៣. ការសម្របសម្រួលការគាំទ្រដល់ជនចាស់ជរានៅតាមសហគមន៍ .......... 31

១៤. ការបញ្ឈប់ការបង្ហូរកាកសំណល់ពីរោងចក្រចូលទៅក្នុងទន្លេ .......... 34

១៥. ការលើកកម្ពស់អនាម័យ និងសុវត្ថិភាពចំណីអាហារនៅសាលារៀន .......... 37

១៦. រៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវក្នុងទីប្រជុំជនស្រុក .......... 40

១៧. ការបង្កើតមគ្គុទ្ទេសក៍សិក្សាសហគមន៍ក្នុងភូមិជនជាតិដើមភាគតិច .......... 42

១៨. ការសម្របសម្រួលការគាំទ្រដល់ដំណើរការមគ្គុទ្ទេសក៍សិក្សាសហគមន៍ .......... 45

១៩. យុទ្ធនាការអប់រំការយល់ដឹងលើការគ្រប់គ្រងសំរាម .......... 47

២០. ការរៀបចំតំបន់ទេសចរណ៍ធម្មជាតិ .......... 50

២១. ការគ្រប់គ្រងសហគមន៍ឥណទានមានជ័យ .......... 53

២២. រៀបចំមគ្គុទ្ទេសក៍សិក្សាសហគមន៍ .......... 55

២៣. សហគមន៍ទេសចរណ៍ធម្មជាតិ ........ 58
២៤. ជីកស្រះយកទឹកសម្រាប់សហគមន៍ ........ 61
២៥. ស្វែងរកទីផ្សារកសិផលជូនប្រជាពលរដ្ឋ ........ 63
២៦. ការលើកកម្ពស់អនាម័យជូនប្រជាពលរដ្ឋ ........ 65
២៧. គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ........ 67
២៨. ការស្តារប្រឡាយស្រោចស្រព សង្គ្រោះស្រូវ ........ 69
២៩. និរន្តរភាពអនាម័យដើម្បីទាំងអស់គ្នា ........ 72

# អារម្ភកថា

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលកំណត់ក្របខណ្ឌជាមូលដ្ឋាន ក្នុងការរៀបចំរចនាសម្ព័ន្ធ ការផ្តល់នូវសិទ្ធិអំណាច មុខងារ និងធនធានបែបវិមជ្ឈការនៅកម្ពុជា ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឱ្យរដ្ឋបាលដែលកើតពីការបោះឆ្នោតនេះមានលទ្ធភាពក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់នូវសិទ្ធិអំណាច មុខងារ និងធនធានដែលបានផ្តល់ក្នុងការលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។ តាមរយៈច្បាប់នេះ ក្រសួង ស្ថាប័នថ្នាក់ជាតិ បានផ្ទេរ (ទាំងការប្រគល់ និងការប្រតិភូកម្ម) នូវមុខងារ និងធនធានសមស្របមួយចំនួនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កើននូវប្រសិទ្ធភាព គុណភាព តម្លាភាព នៃការផ្តល់សេវាមួយចំនួនដែលសមស្របតាមថ្នាក់រដ្ឋបាលនីមួយៗ ដោយផ្អែកតាមនីតិវិធី បែបបទ ស្តង់ដារដែលកំណត់ដោយក្រសួង ស្ថាប័នសាមី។ ក្រៅពីមុខងារដែលបានផ្ទេរ (ទាំងការប្រគល់ និងការប្រតិភូកម្ម) រដ្ឋបាលថ្នាក់ក្រោមជាតិបានផ្តួចផ្តើមរៀបចំ និងបានអនុវត្តដោយផ្ទាល់នូវមុខងារជាជម្រើស ឬមុខងារជាអាណត្តទូទៅមួយចំនួន ដើម្បីដោះស្រាយនូវបញ្ហា កង្វល់ តម្រូវការជាអាទិភាពចាំបាច់នានាដែលបានលើកឡើងដោយប្រជាពលរដ្ឋ ហើយបញ្ហា កង្វល់ និងតម្រូវការជាអាទិភាពចាំបាច់ទាំងអស់នោះមិនបានដោះស្រាយដោយក្រសួង ស្ថាប័ន អង្គភាពជំនាញនៅឡើយ។ ម្យ៉ាងទៀត ក្រៅពីការប្រើប្រាស់នូវធនធានមានកម្រិតរបស់ខ្លួន រដ្ឋបាលថ្នាក់ក្រោមជាតិ បានដើរតួនាទីយ៉ាងសកម្មក្នុងការកៀរគរការគាំទ្រ ការសម្របសម្រួល ការជំរុញ និងការលើកទឹកចិត្តដល់អង្គការសង្គមស៊ីវិល ផ្នែកឯកជន និងអ្នកពាក់ព័ន្ធនានាដែលធ្វើសកម្មភាពនៅមូលដ្ឋាន ដើម្បីចូលរួមអនុវត្ត និងគាំទ្រនូវសំណើ សំណូមពរ និងតម្រូវការចាំបាច់នានារបស់ប្រជាពលរដ្ឋដែលបានលើកឡើងតាម រយៈរដ្ឋបាលថ្នាក់ក្រោមជាតិ ឬលើកផ្ទាល់ទៅអង្គការសង្គមស៊ីវិល ផ្នែកឯកជន និងអ្នកពាក់ព័ន្ធនានាទាំងនោះ។

ជារួម រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ បានអនុវត្តនូវមុខងារជាច្រើនផ្អែកតាមបញ្ហា តម្រូវការ ធនធាន សមត្ថភាព បទពិសោធន៍ វិធីសាស្ត្រ សក្តានុពល និងដៃគូសហប្រតិបត្តិការនានា ដែលមាននៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ អាស្រ័យដោយកត្តាទាំងនេះ ធ្វើឱ្យគុណភាព ប្រសិទ្ធភាព និងកម្រិតនៃការពេញចិត្តរបស់ប្រជាពលរដ្ឋក៏មានលក្ខណៈខុសៗគ្នាផងដែរ ដែលអាចធ្វើជាមេរៀនបទពិសោធន៍ជាច្រើន សម្រាប់ចែករំលែកទៅវិញទៅមករវាងរដ្ឋបាលថ្នាក់ក្រោមនីមួយៗ។ អាស្រ័យហេតុនេះ អង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ នៃលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជអ.ប)ដោយមានការគាំទ្រផ្នែកបច្ចេកទេស និងថវិកា ពីកម្មវិធីកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការ (DAR) អនុវត្តដោយGIZ បានចងក្រងសង្ខេបនូវការអនុវត្តល្អៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួនសម្រាប់ផ្តល់ជាមេរៀនបទពិសោធន៍ និងជាឯកសារៀនសូត្រសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិនានាដែលមានស្ថានភាព ឬសក្តានុពលប្រហាក់ប្រហែលគ្នា ហើយមានបំណងចង់អនុវត្តនូវមុខងារជាជម្រើសនានាដែលជាតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋ ។

យើងខ្ញុំក៏ទទួលស្គាល់ និងសូមអធ្យាស្រ័យផងដែរថា គម្រោងខ្លះមាននិរន្តរភាព គម្រោងខ្លះមិនមាននិរន្តរភាពរយៈពេលយូរតែបានដោះស្រាយតាមពេលវេលានៃបញ្ហាកើតឡើង ប៉ុន្តែដំណើរការទាំងនេះសុទ្ធតែបានផ្តល់នូវមេរៀន បទពិសោធន៍ដ៏មានតម្លៃ សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗបន្តសិក្សា ស្រាវជ្រាវស្វែងយល់ និងពង្រឹងបន្ថែមឱ្យកាន់តែប្រសើរនៅពេលជ្រើសរើសអនុវត្តនូវមុខងារជាជម្រើសណាមួយ។

# ១. ការដោះស្រាយករណីរំលោភបំពានផ្លូវភេទលើកុមារ

# ស្រុក បាណន់ ខេត្តបាត់ដំបង

## ១. សង្ខេបអំពីស្ថានភាពបញ្ហា

បញ្ហាអំពើហិង្សាក្នុងគ្រួសារ នៅតែជាបញ្ហាប្រឈមសម្រាប់ប្រជាពលរដ្ឋមួយចំនួន រួមទាំងការរំលោភបំពានផ្លូវភេទចំពោះកុមារ។ តាមរយៈកិច្ចប្រជុំប្រចាំខែរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារស្រុក (គ.ក.ស.ក) តំណាងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំតែងបានសំណូមពរដល់ក្រុមប្រឹក្សា និងគណៈអភិបាលស្រុក ជួយសម្របសម្រួលជាមួយសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីដោះស្រាយករណីរំលោភបំពានផ្លូវភេទលើកុមារ។ គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារស្រុក ក៏បានរាយការណ៍ជូនកិច្ចប្រជុំក្រុមប្រឹក្សាដែលមានអភិបាលចូលរួម ហើយកិច្ចប្រជុំក៏បានសម្រេចចាត់វិធានការតឹងរ៉ឹងបំផុតចំពោះជនល្មើស។ ការដោះស្រាយករណីរំលោភបំពានផ្លូវភេទលើកុមារ ត្រូវបានអនុវត្តក្នុងត្រីមាសទី១ ឆ្នាំ២០១៨ ជូនចំពោះជនរងគ្រោះ១គ្រួសារ ប៉ុន្តែបានផ្តល់នូវមេរៀន និងបទពិសោធន៍ចំពោះសហគមន៍ទាំងមូល។

## ២. ដំណើរការអនុវត្ត និងលទ្ធផល

ក្រុមប្រឹក្សាស្រុកប្រមូលព័ត៌មានអំពីការកើតនោទ្បើងករណីអំពើហឹង្សាក្នុងគ្រួសារ ការរំលោភបំពានផ្លូវភេទលើក្មេងស្រី និងបានពិភាក្សាអំពីផលប៉ះពាល់រយៈពេលវែងដល់បញ្ហាផ្លូវចិត្តចំពោះជនរងគ្រោះ គ្រួសារជនរងគ្រោះ និងសហគមន៍ទាំងមូលតាមរយៈគ.ក.ស.ក។ ក្រុមប្រឹក្សាបានណែនាំឱ្យ គ.ក.ស.ក សម្របសម្រួលករណីនេះជាមួយអភិបាល ដើម្បីសម្របសម្រួល និងសហការជាមួយអង្គភាពជំនាញ និងសមត្ថកិច្ចពាក់ព័ន្ធក្នុងការអន្តរាគមន៍លើករណីនេះ។

ក្រោយទទួលបានការណែនាំពីក្រុមប្រឹក្សា គណអភិបាលបានចាត់តាំងអភិបាលរង១រូបជាស្ត្រីដែលជាអនុប្រធានគ.ក.ស.ក ធ្វើការសម្របសម្រួល និងទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធ រួមមានការិយាល័យអន្តរវិស័យ ការិយាល័យកិច្ចការនារី ការិយាល័យសង្គមកិច្ច និងអធិការនគរបាលស្រុក និងអង្គការសង្គមស៊ីវិល។ គណអភិបាលក៏បានណែនាំ គ.ក.ស.ក. ដោយមានការគាំទ្រពីការិយាល័យកិច្ចការនារី ការិយាល័យសង្គមកិច្ច និងអធិការនគរបាលស្រុក ទទួលបន្ទុកតាមដាន ការអនុវត្តវិធានការនានាតាមនីតិវិធីច្បាប់ចំពោះជនល្មើស និងធានាសុវត្ថិភាពចំពោះកុមាររងគ្រោះ ហើយអង្គការជំនួយផ្លូវច្បាប់សហគមន៍ បានផ្តល់ជំនួយជាមេធាវីសម្រាប់ការពារក្តីចំពោះជនរងគ្រោះ។ ដំណើរការនៃករណីនេះ មានតម្រូវការថវិកាមួយចំនួនសម្រាប់រៀបចំកិច្ចប្រជុំសម្របសម្រួលជាមួយការិយាល័យអង្គភាពជំនាញពាក់ព័ន្ធ និងចំណាយសម្រាប់ប្រឹក្សាយោបល់ជាមួយជនរងគ្រោះ និងគ្រួសារជនរងគ្រោះ។

ក្រោមកិច្ចអន្តរាគមន៍របស់រដ្ឋបាលស្រុក និងជំនួយផ្នែកច្បាប់ពីអង្គការជំនួយផ្លូវច្បាប់សហគមន៍ ជនល្មើសត្រូវបានចាប់បញ្ជូនទៅតុលាការ និងបានបង្ហាញអំពីការចូលរួមរបស់រដ្ឋបាលស្រុកក្នុងការ

ចាត់វិធានតឹងរ៉ឹងចំពោះជនល្មើស សម្រាប់ជាគំរូនៅក្នុងសហគមន៍អំពីការយកចិត្តទុកដាក់របស់រដ្ឋបាល និងអង្គភាពពាក់ព័ន្ធក្នុងការរួមចំណែកលើកកម្ពស់សន្តិសុខ សុវត្ថិភាពក្នុងមូលដ្ឋាន។

## ៣. បទពិសោធន៍ និងបញ្ហាប្រឈម

ជាមេរៀនបទពិសោធន៍ទទួលបានពីការអនុវត្តមុខងារនេះមានដូចជា៖ (១)ការដោះស្រាយបញ្ហាដែលមានលក្ខណៈផ្នែកផ្លូវច្បាប់ទាមទារឱ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ (២)ករណីរំលោភបំពានផ្លូវភេទប៉ះពាល់ដល់កិត្តិយសគ្រួសារ និងសហគមន៍ហេតុនេះទាមទារនូវការសហការទាំងគ្រួសារជនរងគ្រោះ និងសហគមន៍ (៣)ករណីពាក់ព័ន្ធនីតិវិធីច្បាប់ ដែលលើសពីសមត្ថភាព និងដែនសមត្ថកិច្ចរបស់ស្រុកចាំបាច់ត្រូវមានផ្តល់ការគាំទ្ររដ្ឋបាលខេត្ត ដែលមានដែនសមត្ថកិច្ចធំជាងស្រុក។

ទោះជាយ៉ាងណាក្តីនៅក្នុងការអនុវត្តករណីនេះ មានបញ្ហាប្រឈមមួយចំនួនដូចជាការលំបាកក្នុងការចាប់ជនប្រព្រឹត្ត ក្រុមគ្រួសារជនរងគ្រោះមានការស្ទាក់ស្ទើរក្នុងការផ្តល់កិច្ចសហការដោយសារមានការព្រួយបារម្ភពីអារម្មណ៍សុវត្ថិភាពនៅពេលរាយការណ៍ជូនសមត្ថកិច្ច។

## ៤. សក្តានុពលក្នុងការពង្រីកការអនុវត្តទៅទីកន្លែងផ្សេងទៀត

ជាទូទៅ ការដោះស្រាយបញ្ហានេះ ច្រើនជាសមត្ថកិច្ចរបស់នគរបាលស្រុក និងនគរបាលប៉ុស្តិ៍នៅតាមឃុំ ដែលត្រូវបំពេញតួនាទីនាំមុខ ក្នុងការស្វែងរកជនល្មើស។ ករណីជាច្រើនគណៈអភិបាលក្រុងស្រុក ធ្វើការងារនេះជាមួយសមត្ថកិច្ចពាក់ព័ន្ធ ដោយពុំចាំបាច់ស្នើសុំយោបល់ និងអនុម័តពីក្រុមប្រឹក្សានោះទេ។

<u>**ព័ត៌មានទំនាក់ទំនង**</u>


- **នាយករដ្ឋបាលសាលាស្រុក៖ លោក មៀត សីនី**
- **លេខទូរស័ព្ទ៖ ០៨៨ ៤៥៥ ៧០៧០**

# ២. ការរៀបចំសណ្តាប់ធ្នាប់ជុំវិញផ្សារបាណន់
# ស្រុក បាណន់ ខេត្តបាត់ដំបង

## ១. សង្ខេបអំពីស្ថានភាពបញ្ហា

ផ្សារនៅក្នុងទីរួមស្រុកបាណន់ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការដោះដូរទំនិញ និងផលិតផលកសិកម្មសម្រាប់ប្រជាពលរដ្ឋទាំងក្នុងស្រុក និងក្រៅស្រុកបាណន់ ដែលបានរួមចំណែកលើកកម្ពស់ចរន្តសេដ្ឋកិច្ចនៅក្នុងមូលដ្ឋាន។ ដោយសារកំណើនអាជីវករ និងសកម្មភាពលក់ដូរកាន់តែកើនឡើង បានធ្វើឱ្យអាជីវករតូចតាចដែលពុំមានទីតាំងច្បាស់លាស់ រួមទាំងប្រជាពលរដ្ឋដែលលក់ដូរកសិផលមិនអចិន្ត្រៃយ៍ (លក់មួយព្រឹកៗ ឬកសិផលតាមរដូវកាល) ត្រូវលក់ដូរនៅតាមដងផ្លូវ ដែលបង្កឱ្យមានការបាត់សណ្តាប់ធ្នាប់នៅលើដងផ្លូវសាធារណៈ បង្កបញ្ហាកកស្ទះក្នុងការធ្វើដំណើរ កាកសំណល់ផ្សេងៗត្រូវបានបោះចោលពាសវាលពាសកាល បង្កជាក្លិនមិនល្អ ប៉ះពាល់សុខភាពប្រជាពលរដ្ឋ ប៉ះពាល់បរិស្ថាន សោភ័ណភាពទីផ្សារ និងទីប្រជុំជនស្រុក។ ដើម្បីលុបបំបាត់បញ្ហានេះ ក្រុមប្រឹក្សាបានសម្រេចតាមរយៈកិច្ចប្រជុំរបស់ក្រុមប្រឹក្សាបញ្ចូលទៅក្នុងកម្មវិធីវិនិយោគស្រុក សម្រាប់គម្រោងសាងសង់ផ្សារ ការរៀបចំសណ្តាប់ធ្នាប់ផ្សារ ការរៀបចំសណ្តាប់ធ្នាប់តូបលក់ដូរ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធផ្សេងៗក្នុងផ្សារ ការរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវនៅជិតផ្សារឡើងវិញ និងការប្រមូលផ្តុំអាជីវករនៅកន្លែងជុំគ្នា។ ការអនុវត្តគម្រោងនេះគឺបានប្រើប្រាស់មូលនិធិស្រុក ក្នុងគោលបំណងដើម្បីរួមចំណែកលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ដោយបង្កលក្ខណៈសម្រាប់អាជីវករ និងកសិករតូចតាច ព្រមទាំងលើកកម្ពស់បរិស្ថាន សោភ័ណភាពល្អទីប្រជុំជនស្រុក ហើយការអនុវត្តមុខងារនេះត្រូវបានចាត់ទុកជាអាទិភាពខ្ពស់របស់រដ្ឋបាលស្រុក ដែលត្រូវបានអនុវត្តក្នុងឆ្នាំ២០១៧-២០១៨។

## ២. ដំណើរការអនុវត្ត និងលទ្ធផល

រដ្ឋបាលស្រុក (ដោយមានការជំរុញ និងតាមដានពីក្រុមប្រឹក្សាស្រុក) បានបង្កើតក្រុមការងារចំពោះកិច្ចដើម្បីសម្របសម្រួល និងអនុវត្តសកម្មភាព និងទិសដៅនានាដែលបានឯកភាពរវាងរដ្ឋបាលស្រុក និងភាគីពាក់ព័ន្ធ។ ក្រុមការងារដឹកនាំដោយអភិបាលរង០១រូប និងមានសមាសភាពមកពីអង្គភាពលទ្ធកម្ម ការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ ការិយាល័យអន្តរវិស័យ ការិយាល័យបរិស្ថាន និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ហើយនៅពេលអនុវត្តសកម្មភាពក្រុមការងារនេះ បានសហការជាមួយនគរបាល និងកម្លាំងអាវុធហត្ថស្រុក។ ក្រុមការងារនេះបានរៀបចំផែនការសកម្មភាព និងពេលវេលាលម្អិត ដូចជាប្រមូលទិន្នន័យចំនួនអាជីវករ ធ្វើការពិគ្រោះយោបល់ជាមួយអាជីវករ ការកំណត់ទីតាំង ការចូលរួមបដិភាគថវិកាសម្រាប់ការសាងសង់ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធក្នុងផ្សារ។ ក្រុមការងារបានរៀបចំរបាយការណ៍ជូនគណៈអភិបាលស្រុកពិនិត្យ និងឯកភាពមុនពេលស្នើសុំការពិភាក្សានិងអនុម័តដោយក្រុមប្រឹក្សា។ បន្ទាប់ពីក្រុមប្រឹក្សាអនុម័ត គណៈអភិបាលបាន បានណែនាំដល់គណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលស្រុក រៀបចំផែនការ

សកម្មភាពពាក់ព័ន្ធការងារលទ្ធកម្មនៃការសាងសង់ផ្សារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗក្នុងផ្សារ ស្រប តាមវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ក្រុមប្រឹក្សាបានពិនិត្យ និងសម្រេច លើសំណើគម្រោង ព្រមទាំងអនុម័តលើលទ្ធផលនៃការធ្វើលទ្ធកម្ម និងផែនការសកម្មភាព និងពេល វេលានៃការសាងសង់ផ្សារ។ ក្នុងអំឡុងពេលដំណើរការអនុវត្តមុខងារនេះ អភិបាលស្រុក បានសម្រប សម្រួល ស្នើសុំការគាំទ្រពីរដ្ឋបាលខេត្ត និងមន្ទីរពាក់ព័ន្ធចំពោះការងារមួយចំនួនដែលហួសពីសមត្ថ កិច្ចរបស់រដ្ឋបាលស្រុក។ ជាលទ្ធផលនៃគម្រោងនេះ គឺបានសាងសង់ផ្សារថ្មី១កន្លែង រៀបចំសណ្តាប់ ធ្នាប់តូបលក់ដូរ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗក្នុងផ្សារ រៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវនៅជិតផ្សារ និង បានប្រមូលផ្តុំអ្នកលក់ឱ្យលក់នៅកន្លែងជុំគ្នា។

## ៣. បទពិសោធន៍ និងបញ្ហាប្រឈម

តាមរយៈការអនុវត្តមុខងារនេះ ក្រុមប្រឹក្សាស្រុក និងអ្នកពាក់ព័ន្ធនានាបានទទួលបទពិសោធន៍ មួយចំនួនដូចជា៖ រដ្ឋបាលស្រុកមានការតាំងចិត្ត និងផ្តល់អាទិភាពខ្ពស់ចំពោះការអនុវត្តមុខងារ ឬ សកម្មភាពណាដែលសម្រេចនូវគោលបំណងច្រើនយ៉ាង ដូចករណីគម្រោងខាងលើនេះគឺបានចូលរួម លើកកម្ពស់សកម្មភាពសេដ្ឋកិច្ចក្នុងមូលដ្ឋានផង លើកកម្ពស់បរិស្ថាននិងសោភ័ណភាពទីប្រជុំជន កាត់បន្ថយបញ្ហាកកស្ទះចរាចរជាដើម ចៀសជាងប្រើប្រាស់មូលនិធិស្រុកតែលើហេដ្ឋារចនាសម្ព័ន្ធតែ មួយមុខ ដែលក្នុងនោះ ប្រជាពលរដ្ឋភាគច្រើនពេញចិត្តនឹងការកែលម្អផ្សារនេះ។ រាល់បញ្ហាទាំងអស់ ដែលកើតឡើង រដ្ឋបាលស្រុកត្រូវការស្វែងរកដៃគូដើម្បីគាំទ្រ ហើយប្រសិនបើហួសពីសមត្ថកិច្ចរបស់ ស្រុក នោះរដ្ឋបាលស្រុកបានរាយការណ៍ និងស្នើសុំការគាំទ្រពីរដ្ឋបាលខេត្ត។ ក្នុងអំឡុងពេលអនុវត្ត រដ្ឋ បាលស្រុកបានយកចិត្តទុកដាក់ពង្រឹង តាមដាន ត្រួតពិនិត្យយ៉ាងទៀងទាត់ និងមានវិធានការសម ស្របចំពោះអ្នកមិនព្រមអនុវត្តនូវប្រការដែលបានឯកភាពគ្នា ទោះបីមានកន្លែងសមរម្យក្នុងការលក់ដូរ ក៏ដោយ បើមិនដូច្នោះទេ អាជីវករខ្លះនឹងវិលមកលក់កន្លែងដើមវិញ។

ទន្ទឹមនឹងទទួលបានលទ្ធផល និងបទពិសោធន៍ខាងលើ បញ្ហាប្រឈមលើការអនុវត្តគម្រោងនេះ មានដូចជា៖ អ្នកលក់មួយចំនួនមិនសប្បាយចិត្ត ដោយសារពួកគាត់ចង់លក់នៅតាមផ្លូវ ឬនៅមុខផ្ទះ របស់ពួកគាត់ជាជាងទៅកន្លែងថ្មី ដោយសារមានភាពងាយស្រួលសម្រាប់អ្នកទិញជាងទៅទិញក្នុងផ្សារ។ អាជីវករមួយចំនួននៅតែព្យាយាមមកលក់កន្លែងដើមវិញ ទោះបីរដ្ឋបាលស្រុកមានវិធានការតឹងរឹង យ៉ាងណាក៏ដោយ ជាមួយគ្នានេះការខ្វះខាតបទពិសោធន៍ ហើយនីតិវិធីលទ្ធកម្ម ការទូទាត់ថវិកានៅ តែជាបញ្ហាលំបាក ស្មុគស្មាញ និងយឺតយ៉ាវ។

## ៤. សក្តានុពល និងអនុសាសន៍ក្នុងការអនុវត្តនៅកន្លែងផ្សេងទៀត

ដោយសារកំណើនប្រជាពលរដ្ឋ សកម្មភាពភាពសេដ្ឋកិច្ចតាមទីប្រជុំជន និងការរីកចម្រើន តាមទីប្រជុំជនយ៉ាងឆាប់រហ័សស្ទើរគ្រប់ស្រុកទូទាំងប្រទេស ហេតុនេះផ្សារនៅតាមទីប្រជុំជនទាំង នោះត្រូវប្រឈមនឹងខ្វះហេដ្ឋារចនាសម្ព័ន្ធក្នុងផ្សារ ការគ្រប់គ្រងកាកសំណល់មិនបានល្អ ដែលជាទូទៅ ការលក់ដូរតូចតាចដែលពុំមានលទ្ធភាពទិញស្តង់លក់ជាអចិន្ត្រៃយ៍ ត្រូវបង្ខំចិត្ត លក់ដូរនៅតាមចិញ្ចើម

ថ្នល់នៅតាមទីប្រជុំជន។ ស្ថានភាពបែបនេះ តម្រូវឱ្យរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ពាក់ព័ន្ធត្រូវយកចិត្តទុកដាក់លើការរៀបចំផ្សារ ឬទីតាំងលក់ដូរឱ្យបានសមរម្យ។ ទោះបីតម្រូវការប្រើប្រាស់ធនធានហិរញ្ញវត្ថុជាកត្តាសំខាន់បំផុតក៏ដោយ ប៉ុន្តែរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ក៏ត្រូវយកចិត្តទុកដាក់លៃលករក្សាទុកទីតាំងសាធារណៈសម្រាប់រៀបចំផ្សារ ឬទីតាំងដោះដូរទំនិញផ្សេងៗពិសេសលើកកម្ពស់ការចូលរួមរបស់អាជីវករ និងកសិករខ្នាតតូច ដែលនឹងជួយលើកកម្ពស់សេដ្ឋកិច្ចមូលដ្ឋាន។

<u>ព័ត៌មានទំនាក់ទំនង</u>

- នាយករដ្ឋបាលសាលាស្រុក៖ **លោក មៀត សីនី**
- **លេខទូរស័ព្ទ៖ ០៨៨ ៤៤៥ ៧០៧០**

# ៣. ការពង្រឹងការគ្រប់គ្រងសំណល់ និងអនាម័យបរិស្ថាន

# ក្រុងបាត់ដំបង ខេត្តបាត់ដំបង

## ១. សង្ខេបអំពីស្ថានភាពបញ្ហា

បញ្ហាសំរាម សំណល់រឹងតាមផ្ទះ ពិសេសនៅតំបន់ទីប្រជុំជន បានកំពុងក្លាយជាអាទិភាពខ្ពស់របស់រដ្ឋបាលក្រុង ស្រុក ដែលត្រូវដោះស្រាយ។ ការបោះចោលសំរាមពាសវាលពាសកាលនៅតាមដងក្នុងមូលដ្ឋាន និងតាមផ្លូវជាតិ ខ្វះការវេចខ្ចប់សំរាមបានត្រឹមត្រូវ ដែលបង្កក្លិនកខ្វក់ ប៉ះពាល់សុខភាពប្រជាពលរដ្ឋ បរិស្ថាន និងសោភ័ណភាពដែលមានទេសចរណ៍ជាតិ អន្តរជាតិ។ រដ្ឋបាលក្រុងតែងទទួលរងការរិះគន់ពីប្រជាពលរដ្ឋ សមាជិកក្រុមប្រឹក្សាក្រុង និងសង្កាត់ ថ្នាក់ដឹកនាំខេត្ត អំពីការខ្វះចន្លោះនៃការគ្រប់គ្រងសំរាម ហើយតែងបានលើកសំណូមពរតាមរយៈវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ ឬកិច្ចប្រជុំនានា ដោយស្នើសុំឱ្យរដ្ឋបាលក្រុង យកចិត្តទុកដាក់ដោះស្រាយ លើការគ្រប់គ្រងសំរាមឱ្យបានល្អ។ ដោយមានសំណូមពរជាច្រើន ក្រុមប្រឹក្សាក្រុងបានដាក់បញ្ចូលបញ្ហានេះទៅក្នុងកិច្ចប្រជុំរបស់ខ្លួនដោយពិភាក្សាជាមួយគណៈអភិបាល និងការិយាល័យជំនាញពាក់ព័ន្ធ បានសម្រេចជ្រើសរើសយកគម្រោងផ្សព្វផ្សាយអំពីវិធានការនានាសម្រាប់ការគ្រប់គ្រងសំណល់ និងអនាម័យបរិស្ថានជាអាទិភាពដែលត្រូវដោះស្រាយ។ មុខងារនេះ ជាមុខងារជាកាតព្វកិច្ចដែលក្រសួងបរិស្ថានបានផ្ទេរទៅរដ្ឋបាលក្រុង ត្រូវបានអនុវត្តក្នុងឆ្នាំ ២០១៨ ដូច្នេះរដ្ឋបាលបានប្រើប្រាស់ថវិកាដែលគាំទ្រដោយក្រសួងបរិស្ថាន។

## ២. ដំណើរការអនុវត្ត និងលទ្ធផល

អនុវត្តតាមការសម្រេចរបស់ក្រុមប្រឹក្សា គណៈអភិបាលធ្វើការសម្របសម្រួល ទំនាក់ទំនង និងណែនាំដល់ការិយាល័យចំណុះសាលាក្រុង ការិយាល័យជំនាញពាក់ព័ន្ធ និងសង្កាត់នានា ព្រមទាំងសម្របសម្រួលជាមួយអង្គការ Compet ដែលធ្វើការងារខាងបរិស្ថាននិងផលិតជីកំប៉ុស្តពីកាកសំណល់ដើម្បីចូលរួមក្នុងគម្រោងសកម្មភាពនេះ។ គណៈអភិបាលណែនាំការិយាល័យចំណុះសាលាក្រុង ពិសេសការិយាល័យអភិវឌ្ឍន៍ក្រុង និងការិយាល័យគ្រប់គ្រងសំណល់រឹង សហការជាមួយសង្កាត់ទាំងអស់ក្នុងក្រុង លើការប្រមូលព័ត៌មាន និងបញ្ហានានាពីប្រជាពលរដ្ឋ និងសំណូមពរពាក់ព័ន្ធបញ្ហានៃការចោលសំរាម វិធានការនានាក្នុងការទប់ស្កាត់ការបោះចោលសំរាមតាមទីសាធារណៈ។ ការិយាល័យអភិវឌ្ឍន៍ក្រុង និងការិយាល័យគ្រប់គ្រងសំណល់រឹង បានសហការរៀបចំសេចក្តីព្រាងផែនការសកម្មភាពនិងថវិកាពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាមនិងកាកសំណល់ និងសេចក្តីព្រាងដីកាសម្រាប់ដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។ រដ្ឋបាលក្រុង ដោយមានការជំរុញនិងពិនិត្យផ្តល់យោបល់ពីក្រុមប្រឹក្សា បានធ្វើការផ្សព្វផ្សាយដីកាស្តីពីការគ្រប់គ្រងសំរាម សំណល់រឹង ហើយរួមទាំងវិធានការចំពោះអ្នកដែលមិនអនុវត្តតាមដីកា។ ការផ្សព្វផ្សាយត្រូវបានអនុវត្តនៅតាមសង្កាត់ តាមរយៈកិច្ចប្រជុំ ឬវេទិកានានាជាមួយប្រជាពលរដ្ឋ ការបិតផ្សាយដីកានៅតាមសង្កាត់ ដោយមានការចូលរួមពីក្រុម

ប្រឹក្សា ការិយាល័យចំណុះសាលាក្រុង និងការិយាល័យជំនាញពាក់ព័ន្ធនានា ព្រមទាំងអង្គការនានាដែលកំពុងធ្វើសកម្មភាពក្នុងក្រុង ការផលិតផ្ទាំងប៉ាណូអប់រំដែលដាក់នៅតាមដងផ្លូវ ការអប់រំតាមសាលារៀន ការដាក់ធុងសំរាមនៅតាមទីសាធារណៈ។ លទ្ធផលអនុវត្តមុខងារនេះ ត្រូវបានរាយការណ៍ជូនក្រុមប្រឹក្សាក្រុង រៀងរាល់កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សា។

## ៣. បទពិសោធន៍ និងបញ្ហាប្រឈម

ដោយការអនុវត្តនូវមុខងារនេះ ក្រុមប្រឹក្សាក្រុង និងអ្នកពាក់ព័ន្ធនានាទទួលបានមេរៀនបទពិសោធន៍ល្អៗរួមមាន៖ ក្រុមប្រឹក្សាមានការយល់ដឹងកាន់តែប្រសើរអំពីនីតិវិធីនៃការរៀបចំ ការពិគ្រោះយោបល់ ការអនុម័ត និងអនុវត្តដីកាដែលក្នុងនោះរដ្ឋបាលក្រុងបានចំណាយរយៈពេលជិត៣ខែ ក្នុងការរៀបចំដីកានេះ។ ការងារគ្រប់គ្រងសំរាម សំណល់នៅតាមទីសាធារណៈ និងនៅតាមលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ ទាមទារនូវការផ្សព្វផ្សាយអប់រំ និងអនុវត្តវិធានការម៉ឺងម៉ាត់និងជាប្រចាំ ពិសេសសង្កាត់ត្រូវចូលរួមពង្រឹងការអប់រំ និងអនុវត្តវិធានការដាក់ស្លែង និងស្នើសុំអន្តរាគមន៍សម្រាប់ដោះស្រាយបញ្ហានេះ។ ដំណើរការផ្តល់សេវាប្រមូលសំរាម គឺត្រូវការចាំបាច់ការចូលរួមរបស់វិស័យឯកជនក្នុងការប្រមូលសំរាម ព្រោះរដ្ឋបាលក្រុងពុំមានធនធាន មធ្យោបាយផ្សេងសម្រាប់អនុវត្តបាន។

ទន្ទឹមនឹងនេះ រដ្ឋបាលក្រុងបានបញ្ហាប្រឈមមួយចំនួនដូចជា ខ្វះការចូលរួមពីប្រជាពលរដ្ឋក្នុងការទុកដាក់សំរាមឱ្យបានសមស្រប និងការប្រើប្រាស់ធុងសំរាម រដ្ឋបាលក្រុងខ្វះខាតថវិកាក្នុងការផ្សព្វផ្សាយពីដីកាឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ រដ្ឋបាលក្រុងមានការព្រួយបារម្ភក្នុងការចេញដីកាដែលមានការផាកពិន័យ ប្រសិនបើនរណាម្នាក់មិនអនុវត្តតាម ដោយសារនៅមិនទាន់មានភាពច្បាស់ពីការផាកពិន័យ តើលុយដែលបានពីការផាកពិន័យគួរយកទៅណា តើនរណាជាអ្នកមានសមត្ថកិច្ច និងទទួលខុសត្រូវក្នុងការផាកពិន័យ?

## ៤. សក្តានុពលក្នុងការពង្រីកការអនុវត្តទៅទីកន្លែងផ្សេងទៀត

បច្ចុប្បន្នមុខងារគ្រប់គ្រងសំរាម សំណល់រឹងនៅតាមទីប្រជុំជនកំពុងក្លាយជាមុខងារចម្បងមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេសបន្ទាប់ពីមុខងារនេះត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ហេតុនេះ ក្លាយជាមុខងារជាកាតព្វកិច្ចដែលរដ្ឋបាលក្រុង ស្រុកត្រូវអនុវត្ត។ ក្នុងការអនុវត្ត រដ្ឋបាលក្រុងត្រូវតែមានសិទ្ធិអំណាចក្នុងការវិភាជថវិកាប្រចាំរបស់ខ្លួនសម្រាប់គាំទ្រ ការអនុវត្តការផ្តល់សេវាបែបនេះ។ រដ្ឋបាលក្រុង ស្រុកដែលត្រូវធ្វើការងារនេះ ត្រូវមានវិធានការម៉ឺងម៉ាត់ចំពោះអ្នកចោលសំរាមពាលវាលពាសកាល បើមិនដូច្នេះ ការគ្រប់គ្រងសំរាមនឹងមិនបានជោគជ័យ។

<u>**ព័ត៌មានទំនាក់ទំនង**</u>


- **នាយករដ្ឋបាលសាលាក្រុង៖ លោក ថោង នី**
- **លេខទូរស័ព្ទ៖ ០១២ ៨៩៩ ៦០៧**

# ៤. ការរៀបចំសណ្តាប់ធ្នាប់សាធារណៈនៅផ្សារបរវេល ស្រុកបវេល ខេត្តបាត់ដំបង

## ១. សង្ខេបអំពីស្ថានភាពបញ្ហា

ដោយសារកំណើនអាជីវករ និងសកម្មភាពលក់ដូរកាន់តែកើនឡើងបានធ្វើឱ្យមានការលក់ដូររីករាលដាលនៅតាមដងផ្លូវ ដែលធ្វើឱ្យគ្មានសណ្តាប់ធ្នាប់នៅទីប្រជុំជនផ្សារបវេល មានការកកស្ទះចរាចរណ៍ជារៀងរាល់ថ្ងៃ ជាពិសេស នៅពេលព្រឹកព្រលឹម។ បញ្ហាទាំងនេះកើតឡើងដោយសារអាជីវករដែលមានលំនៅឋានជាប់នឹងផ្លូវជាតិត្រង់ចំណុចទីប្រជុំជនផ្សារ ដោយពួកគាត់ពង្រីកទីតាំងនៃការលក់ដូររបស់គាត់នៅខាងមុខផ្ទះ ឬជួលទៅឱ្យអ្នកលក់ដូរផ្សេងទៀតដែលមិនមានទីតាំងលក់ដូរច្បាស់លាស់ និងដោយសារប្រជាពលរដ្ឋដែលលក់ដូរកសិផលមិនអចិន្ត្រៃយ៍ (លក់មួយព្រឹកៗ ឬកសិផលតាមរដូវកាល)។ ការចាក់កាកសំណល់ផ្សេងៗ ចោលពាសវាលពាសកាល និងចោលជាគំនរនៅផ្នែកខាងមុខផ្សារ ក៏បានបង្កជាក្លិនមិនល្អ ប៉ះពាល់សុខភាពប្រជាពលរដ្ឋ ប៉ះពាល់បរិស្ថាន សោភ័ណ្ឌភាពទីផ្សារ និងទីប្រជុំជនស្រុក។ លើសពីនោះ ការចតឬឈប់យានជំនិះពុំមានរបៀបរៀបរយនៅលើទ្រូងផ្លូវត្រង់ចំណុចទីប្រជុំជនផ្សារក៏ជាបញ្ហាមួយផងដែរ។ ដោយមានសំណូមពរពីប្រជាពលរដ្ឋដែលបានចូលរួមនៅក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សា និងតាមការពិនិត្យឃើញជាក់ស្តែង ក្រុមប្រឹក្សាស្រុកបានផ្តួចផ្តើមគំនិតដោះស្រាយ ដោយបានពិភាក្សានិងធ្វើសេចក្តីសម្រេចនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឱ្យមានការរៀបចំសណ្តាប់ធ្នាប់ផ្សារបវេល និងការរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវនៅក្នុងទីប្រជុំជនផ្សារឡើងវិញ។

## ២. ដំណើរការអនុវត្ត និងលទ្ធផល

ការអនុវត្តគម្រោងនេះ មានគោលបំណងដើម្បីរួមចំណែកលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន តាមរយៈការបង្កលក្ខណៈសម្រាប់អាជីវករ និងកសិករតូចតាចបានធ្វើការដោះដូរកសិផលរបស់ខ្លួន កែលម្អសណ្តាប់ធ្នាប់សាធារណៈនៅផ្សារបវេល លើកកម្ពស់បរិស្ថាន និងសោភ័ណភាពទីប្រជុំជនស្រុក។ ការកំណត់យកបញ្ហានេះអាទិភាពក្នុងការដោះស្រាយ ក្រុមប្រឹក្សាស្រុកក៏បានគិតគូរដោយផ្អែកលើធនធានរបស់រដ្ឋបាល សមត្ថភាព និងជាមុខងារមួយ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ស្រុក។ មុខងារនេះត្រូវបានចាត់ទុកជាអាទិភាពខ្ពស់របស់រដ្ឋបាលស្រុក និងត្រូវបានអនុវត្តនៅខែមករា ឆ្នាំ ២០១៨។ ដើម្បីអនុវត្តមុខងារនេះរដ្ឋបាលស្រុក ត្រូវមានការចូលរួមពីក្រុមប្រឹក្សាស្រុក គណៈអភិបាល និងក្រុមការងាររៀបចំសោភ័ណភាពទីប្រជុំជនស្រុកបវេល។ គណៈអភិបាលចាត់តាំងអភិបាលរងស្រុក១រូបជាអ្នកដឹកនាំក្រុមការងារ ដើម្បីចាត់ចែង និងសម្របសម្រួលសកម្មភាពនានា ដោយមានការគាំទ្រពីការិយាល័យចំណុះសាលាស្រុក និងការិយាល័យជំនាញមួយចំនួនចូលរួម។ ក្រុមការងារះ លោកអភិបាលស្រុកជាប្រធានក្រុមការងារនេះ តែលោកបានចាត់ឱ្យអភិបាលរង០១រូបជាអ្នកដឹកនាំក្រុមការងារនេះ ដោយមានសមាសភាពមកពីការិយាល័យចំណុះសាលាស្រុក ការិយាល័យជំនាញ

ពាក់ព័ន្ធមួយចំនួន តំណាងអាជីវករ និងអាជ្ញាធរមូលដ្ឋានផងដែរ ព្រមទាំងបានសហការជាមួយ នគរបាល និងកម្លាំងអាវុធហត្ថស្រុក។ ក្រុមការងារនេះជាអ្នកអនុវត្តផ្ទាល់ ដោយការរៀបចំផែនការ សកម្មភាព និងពេលវេលាលម្អិត ដូចជាប្រមូលទិន្នន័យចំនួនអាជីវករ ធ្វើការពិគ្រោះយោបល់ជាមួយ អាជីវករ អំពីការរៀបចំសណ្តាប់ធ្នាប់ផ្សារ និងផ្លូវជុំវិញផ្សារ ការចុះអប់រំផ្សព្វផ្សាយដោយផ្ទាល់ និងមាន ដាក់ចេញនូវសេចក្តីជូនដំណឹងផងដែរ។ ក្រៅពីនេះ ក្រុមការងារត្រូវរៀបចំរបាយការណ៍ត្រួតពិនិត្យការ អនុវត្តកិច្ចសន្យា របាយការណ៍រីកចំរើននៃជំហាននិមួយៗសម្រាប់រាយការណ៍ជូនគណៈអភិបាល និង ក្រុមប្រឹក្សាស្រុកប្រចាំខែ និងតាមការស្នើសុំ។ ការអនុវត្តមុខងារនេះមានការគាំទ្រថវិកាពីគម្រោង EU-DAR និងថវិកាបដិភាគរបស់រដ្ឋបាលស្រុកប្រហែល១០% ដែលជាគោលការណ៍ឯកភាពគ្នារវាងរដ្ឋបាល និងដៃគូសហប្រតិបត្តិការ។ ការរៀបចំសណ្តាប់ធ្នាប់សាធារណៈនៅទីផ្សារ ត្រូវការថវិកាសម្រាប់រៀបចំ ស្លាកសញ្ញា ផ្ទាំងរូបភាពនានាសម្រាប់ការអប់រំផ្សព្វផ្សាយ កិច្ចប្រជុំប្រចាំខែរបស់ក្រុមការងារ ការរៀបចំ វេទិកាអប់រំផ្សព្វផ្សាយ និងការផ្សព្វផ្សាយតាមរយៈគ្រឿងបំពងសម្លេងជាដើម។

ផ្អែកទៅតាមសកម្មភាព ដែលបានអនុវត្តខាងលើនេះ គម្រោងបានពង្រឹងសមត្ថភាពដល់អ្នក ពាក់ព័ន្ធសំខាន់ៗ ដែលចូលរួមគ្រប់ដំណាក់កាលនៃគម្រោង ដោយទទួលបាននូវលទ្ធផលសម្រេច បានដូចខាងក្រោម៖ អាជីវករ និងប្រជាពលរដ្ឋ មានការយល់ដឹងច្រើនពីបញ្ហាអនាម័យ ការលក់ដូរ ប្រកបដោយសោភ័ណភាព និងការចតឬឈប់យានជំនិះប្រកបដោយរបៀបរៀបរយល្អ ប្រជាពលរដ្ឋ និងអាជីវករដែលរស់នៅតាមបណ្តោយផ្លូវជាតិមុខផ្សារបវេល ភាគច្រើនបានយល់ព្រមកាត់សំយាប ដាក់តាំងទំនិញផ្សេងៗ និងរៀបចំកែសម្រួលការចាក់បេតុងស្របតាមសេចក្តីណែនាំរបស់រដ្ឋបាលស្រុក។ អ្នកលក់ដូរចល័ត និងអ្នកលក់ដូរលើចិញ្ចើមផ្លូវ បានធ្វើការលក់ដូរផុតពីចិញ្ចើមផ្លូវជាតិ និងមានរបៀប រៀបរយល្អ។ ការប្រមូលសំរាមរបស់ក្រុមហ៊ុនមានភាពទៀងទាត់ និងទាន់ពេលវេលា ដែលធ្វើឱ្យអនាម័យ នៅក្នុងផ្សារល្អប្រសើរជាងមុន ហើយការកកស្ទះចរាចរណ៍ក្នុងពេលព្រឹកត្រូវបានកាត់បន្ថយ

## ៣. បទពិសោធន៍ និងបញ្ហាប្រឈម

**មេរៀនបទពិសោធន៍ទទួលបានរួមមាន៖** (១)បញ្ហាសណ្តាប់ធ្នាប់នៃការលក់ដូរនៅតាមដងផ្លូវ ទាមទារការដោះស្រាយបែបទន់ភ្លន់និងបត់បែន ព្រោះបើអនុវត្តតឹងរ៉ឹងពេកនឹងប៉ះពាល់ដល់អាជីវករ ឬ កសិករខ្នាតតូចដែលពុំមានលទ្ធភាពទិញតូបអចិន្ត្រៃយ៍ ដែលពួកគាត់បានរួមចំណែកលើកស្ទួយសេដ្ឋ កិច្ចមូលដ្ឋាន(២)ការអនុវត្តមុខងារនេះ មានការគាំទ្រថវិកាពីគម្រោង EU-DAR ហេតុនេះការរៀបចំ សំណើគម្រោងដើម្បីទទួលបានថវិកាចាំបាច់ត្រូវតែអនុវត្តតាមជំហាន និងនីតិវិធីណែនាំស្តីពីការអនុវត្ត មុខងារជាជម្រើសរបស់ក្រុមប្រឹក្សា ដែលទាមទារពេលវេលាយូរ ប៉ុន្តែបានបង្ហាញពីតម្លាភាព និងមាន ការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ។ (៣)ត្រូវបង្កើតឱ្យមានក្រុមការងារមួយដែលមានការចូលរួមពីគ្រប់អ្នក ពាក់ព័ន្ធដើម្បីដោះស្រាយ។ (៤)ត្រូវចេញសេចក្តីណែនាំស្តីពីការរៀបចំសណ្តាប់ធ្នាប់ទីប្រជុំជនផ្សារ។ និង(៥)ក្រុមការងារនេះត្រូវធ្វើការផ្សព្វផ្សាយសេចក្តីណែនាំនេះឱ្យបានទូលំទូលាយ ព្រមទាំងរៀបចំ កិច្ចប្រជុំ និងចុះអប់រំជាទៀងទាត់។

**បញ្ហាប្រឈម៖** (១)បញ្ហាសណ្តាប់ធ្នាប់និងបរិស្ថានដែលពាក់ព័ន្ធនឹងការប្រមូលសំរាម រដ្ឋបាលស្រុកមិនមានអំណាចក្នុងការធ្វើការជាមួយអ្នកផ្តល់សេវាទាំងនោះ ឬត្រួតពិនិត្យមើលថាតើអ្នកផ្តល់សេវាទាំងនោះបានអនុវត្តតាមកិច្ចសន្យាឬទេ ព្រោះរដ្ឋបាលខេត្តជាអ្នកចេញអាជ្ញាប័ណ្ណដល់អ្នកផ្តល់សេវាប្រមូលសំរាមនៅផ្សារ។ (២)រដ្ឋបាលមានការលំបាកក្នុងការអនុវត្តវិធានការតឹងរ៉ឹងចំពោះអាជីវករ ឬកសិករខ្នាតតូចដែលពុំមានលទ្ធភាពទិញតូបអចិន្ត្រៃយ៍។ (៣) ផ្សារតូចចង្អៀត ធ្វើឱ្យរដ្ឋបាលស្រុកពិបាកក្នុងការសម្របសម្រួល និងរៀបចំសណ្តាប់ធ្នាប់ផ្សារនេះ។

## ៤. សក្តានុពលក្នុងការពង្រីកការអនុវត្តទៅទីកន្លែងផ្សេងទៀត

ដោយសារកំណើនប្រជាពលរដ្ឋ សកម្មភាពភាពសេដ្ឋកិច្ចតាមទីប្រជុំជន និងការកើនឡើងទីប្រជុំជន យ៉ាងឆាប់រហ័សស្ទើរគ្រប់ស្រុកទូទាំងប្រទេស ហេតុនេះផ្សារនៅតាមទីប្រជុំជនទាំងនោះត្រូវប្រឈមនឹងកង្វះហេដ្ឋារចនាសម្ព័ន្ធក្នុងផ្សារ ការគ្រប់គ្រងកាកសំណល់មិនបានល្អ ជាទូទៅអ្នកលក់ដូរតូចតាចដែលពុំមានលទ្ធភាពទិញស្តង់លក់ជាអចិន្ត្រៃយ៍ ត្រូវបង្ខំចិត្តលក់ដូរនៅតាមចិញ្ចើមថ្នល់នៅតាមទីប្រជុំជន។ ស្ថានភាពបែបនេះ តម្រូវឱ្យរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ពាក់ព័ន្ធត្រូវយកចិត្តទុកដាក់លើការរៀបចំផ្សារ ឬទីតាំងលក់ដូរឱ្យបានសមរម្យ។ ទោះបីតម្រូវការប្រើប្រាស់ធនធានហិរញ្ញវត្ថុជាកត្តាសំខាន់បំផុតក៏ដោយ ប៉ុន្តែរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ក៏ត្រូវយកចិត្តទុកដាក់លៃលករក្សាទុកទីតាំងសាធារណៈសម្រាប់រៀបចំផ្សារ ឬទីតាំងដោះដូរទំនិញផ្សេងៗពិសេសលើកកម្ពស់ការចូលរួមរបស់អាជីវករ និងកសិករខ្នាតតូច ដែលនឹងជួយលើកកម្ពស់សេដ្ឋកិច្ចមូលដ្ឋាន។

<u>ព័ត៌មានទំនាក់ទំនង</u>


- **អភិបាលរងស្រុក៖ ឈួត សាលី**
- **លេខទូរស័ព្ទ៖ ០១២ ៦៩៨ ០១៨**

# ៥. ការរៀបចំទីតាំងលក់ដូរដើម្បីបញ្ចៀសការលក់ដូរនៅតាមដងផ្លូវ ស្រុកឯកភ្នំ ខេត្តបាត់ដំបង

## ១. សង្ខេបអំពីស្ថានភាពបញ្ហា

អាជីវករមួយចំនួនធំនៅតាមផ្សារទីប្រជុំជនស្រុក បានប្រើប្រាស់ដងផ្លូវ និងទីសាធារណៈ ជាកន្លែងលក់ដូរ និងបោះចោលសំរាម កាកសំណល់ផ្សេងៗ ដែលបង្កឱ្យគ្មានអនាម័យ សោភ័ណភាព និងសណ្តាប់ធ្នាប់មិនល្អ ព្រមទាំងធ្វើឱ្យមានការកកស្ទះចរាចរ និងអាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់អ្នកធ្វើដំណើរឆ្លងកាត់ថែមទៀត។ ដោយសារតែមូលហេតុទាំងអស់នេះ ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ សមាជិកក្រុមប្រឹក្សាស្រុក និងសមាជិកក្រុមប្រឹក្សាឃុំ បានសំណូមពរជាច្រើនលើកច្រើនសារមកក្រុមប្រឹក្សា និងរដ្ឋបាលស្រុក ដើម្បីរៀបចំសណ្តាប់ធ្នាប់ផ្សារនេះឡើងវិញសំដៅលើកកម្ពស់សកម្មភាពសេដ្ឋកិច្ច ធានាសុវត្ថិភាពការធ្វើដំណើរឆ្លងកាត់ និងកែលម្អសោភ័ណភាព ព្រមទាំងបរិស្ថានដល់ប្រជាពលរដ្ឋដែលកំពុងរស់នៅជិតទីតាំងផ្សារ។ ដោយពិនិត្យឃើញថាបញ្ហាខាងលើនេះពិតជាមានផលប៉ះពាល់ធ្ងន់ធ្ងរ ក្រុមប្រឹក្សាស្រុកបានសម្រេចជ្រើសរើសបញ្ហានេះជាបញ្ហាអាទិភាពក្នុងចំណោមបញ្ហាដទៃផ្សេងទៀតមកដោះស្រាយតាមសំណូមពររបស់ប្រជាពលរដ្ឋ។ សកម្មភាពនេះត្រូវបានអនុវត្តក្នុងអំឡុងខែមករា ដល់ខែមីនា ឆ្នាំ២០១២។

## ២. ដំណើរការអនុវត្ត និងលទ្ធផល

គណៈអភិបាលបានសម្របសម្រួលណែនាំ ក្នុងការបង្កើតក្រុមការងារដែលសមាសភាពរួមមាន៖ នាយករងរដ្ឋបាលស្រុក តំណាងការិយាល័យអន្តរវិស័យ ការិយាល័យបរិស្ថាន ការិយាល័យភូមិបាល អធិការដ្ឋាននគរបាលស្រុក និងរដ្ឋបាលឃុំពាក់ព័ន្ធ។ ក្រុមការងារបានរៀបចំផែនការការងារពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ និងអាជីវករ និងប្រមូលព័ត៌មានចាំបាច់នានា ដើម្បីរៀបចំកន្លែងលក់ដូរនៅទីតាំងថ្មី សម្រាប់អាជីវករ និងអ្នកលក់ដូរផ្សេងៗទៀតប្រមាណជាង១០០តូប ដែលបានលក់ដូរនៅមុខផ្ទះ លក់តាមកញ្ច្រែងល្អី នៅតាមដងផ្លូវ។ ដោយសារការអនុវត្តមុខងារនេះមានលក្ខណៈជាបទបញ្ញាទូទៅ ដែលប៉ះពាល់ដល់សាធារណជន និងការដាក់ចេញនូវវិធានការនានា ក្រុមប្រឹក្សាបានណែនាំឱ្យគណៈអភិបាលរៀបចំសេចក្តីព្រាងដីកាស្តីពីការរៀបចំទីតាំងលក់ដូរ ដើម្បីបញ្ចៀសការលក់ដូរនៅតាមដងផ្លូវ ដោយពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងដាក់ជូនគណៈអភិបាល និងក្រុមប្រឹក្សាពិភាក្សាអនុម័ត។ តាមរយៈដីការបស់ក្រុមប្រឹក្សា គណៈអភិបាលបានណែនាំក្រុមការងារឱ្យធ្វើការពិភាក្សាជាមួយរដ្ឋបាលឃុំ ការិយាល័យជំនាញ ដើម្បីដោះស្រាយការដោះដូរទីតាំងលក់ដូរពីទីតាំងចាស់ទៅទីតាំងថ្មី។ ក្រុមការងារនេះដែលមានការិយាល័យបរិស្ថានជាសមាជិកបានសហការជាមួយរដ្ឋបាលឃុំ ក្នុងការចុះអប់រំដល់អាជីវករអំពីគ្រោះថ្នាក់ដែលបង្កដោយការបោះចោលសំរាម កាកសំណល់ និងអំពីរបៀបវេចខ្ចប់សំរាមឱ្យបានត្រឹមត្រូវ។ ជាមួយគ្នានេះ កងកម្លាំងនគរបាលស្រុកបាន

ចូលរួមក្នុងការថែរក្សាសណ្តាប់ធ្នាប់ ចរាចរតាមដងផ្លូវ និងជូនដំណឹងអំពីវិធានការនានាក្នុងការផ្លាស់ប្តូរទីតាំងផ្សារ និងពង្រឹងការអនុវត្តវិធានការដែលមានចែងនៅក្នុងដីការបស់ក្រុមប្រឹក្សាស្រុក។

គណៈអភិបាលបានសម្របសម្រួលជំរុញជាប្រចាំនូវការសហការជាមួយអាជ្ញាធរឃុំ នគរបាល និងការិយាល័យជំនាញពាក់ព័ន្ធ តាមរយៈកិច្ចប្រជុំរបស់គណៈបញ្ជាការឯកភាពស្រុក ព្រមទាំងបានរាយការណ៍ជូនរដ្ឋបាលខេត្តអំពីវិធានការនានាដែលស្រុកអនុវត្ត និងស្នើសុំអន្តរាគមន៍លើបញ្ហាប្រឈមនានាក្នុងករណីហួសពីដែនសមត្ថកិច្ចស្រុកដោះស្រាយ ព្រមទាំងពិភាក្សាជាមួយអភិបាលស្រុកផ្សេងទៀតក្នុងការផ្លាស់ប្តូរបទពិសោធន៍នៃដំណោះស្រាយបញ្ហាដែលស្រុកមួយចំនួនធ្លាប់បានអនុវត្តកន្លងមក។

ជាលទ្ធផលនៃការអនុវត្តមុខងារនេះ សង្កេតឃើញថាសណ្តាប់ធ្នាប់ និងបរិស្ថាននៅតាមដងផ្លូវបានល្អប្រសើរជាងមុន និងកាត់បន្ថយបានការលក់ដូរនៅតាមដងផ្លូវ ដោយក្រុមអាជីវករមួយចំនួនធំបានផ្លាស់ប្តូរទីតាំងលក់ដូររបស់ពួកគាត់ទៅទីតាំងថ្មី ហើយប្រជាពលរដ្ឋភាគច្រើនដែលធ្វើដំណើរតាមផ្លូវបានបង្ហាញពីការពេញចិត្ត និងគាំទ្រនូវការអនុវត្តវិធានការរបស់រដ្ឋបាលស្រុកផងដែរ។ ទីតាំងលក់ដូរថ្មីត្រូវបានរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធ ដូចជាលូបង្ហូរកាកសំណល់ និងទីតាំងស្តុកកាកសំណល់ស្របតាមបែបបទ និងស្តង់ដារ។

### ៣. បទពិសោធន៍ និងបញ្ហាប្រឈម

ក្នុងការអនុវត្តមុខងារខាងលើនេះ រដ្ឋបាលស្រុក និងអ្នកពាក់ព័ន្ធនានាទទួលបានបទពិសោធន៍ដូចជា៖ រដ្ឋបាលស្រុកបានបង្ហាញពីការយកចិត្តទុកដាក់នូវការដោះស្រាយនូវកង្វល់ បញ្ហានិងសំណូមពររបស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា។ ការសម្របសម្រួល និងការកៀរគរការចូលរួមពីសំណាក់ប្រជាពលរដ្ឋនិងអ្នកពាក់ព័ន្ធនានា ព្រមទាំងកិច្ចសហប្រតិបត្តិការជាមួយវិស័យជំនាញនានា និងការផ្លាស់ប្តូរបទពិសោធន៍ជាមួយរដ្ឋបាលស្រុកផ្សេងទៀត បានជំរុញឱ្យការដោះស្រាយបញ្ហាខាងលើទទួលបានជោគជ័យ។ ទោះជាយ៉ាងក៏ដោយ រដ្ឋបាលស្រុកបានជួបប្រទះនូវបញ្ហាប្រឈមនានាមានដូចជា៖ ខ្វះថវិកា ខ្វះដីសាធារណៈសម្រាប់រៀបចំទីតាំងផ្សារអចិន្ត្រៃយ៍ ដែលបញ្ហាទាំងនេះបានធ្វើឱ្យប្រជាពលរដ្ឋខ្លះមិនចង់ចូលរួម និងមិនចង់ផ្លាស់ប្តូរទីតាំង ទោះបីមានវិធានការមួយចំនួនក៏ដោយ។

### ៤. សក្តានុពលក្នុងការពង្រីកការអនុវត្តទៅទីកន្លែងផ្សេងទៀត

ការអនុវត្តមុខងារនេះ ជាបទពិសោធន៍សម្រាប់ចែករំលែកទៅរដ្ឋបាលថ្នាក់ក្រោមជាតិដទៃទៀត ជាពិសេសរដ្ឋបាលក្រុង ស្រុកដែលជួបប្រទះការលក់ដូរនៅតាមដងផ្លូវ គួរគិតគូរត្រៀមដីសាធារណៈ និងធនធានសមស្របរបស់ខ្លួនសម្រាប់រៀបចំទីតាំងផ្សារអចិន្ត្រៃយ៍ និងចាត់វិធានការចាំបាច់នានាឱ្យបានតឹងរឹង ព្រមទាំងធ្វើការតាមដាន ត្រួតពិនិត្យជាប្រចាំក្នុងការអនុវត្តមុខងារនេះ ដើម្បីជានានិរន្តរភាព។

<u>ព័ត៌មានទំនាក់ទំនង</u>

- **នាយករដ្ឋបាលសាលាស្រុក៖ សម ជាតិ**
- **លេខទូរស័ព្ទ៖ ០១៥ ២១១ ៥៦៦**

# ៦. ការបង្កើតមត្តេយ្យសិក្សាសហគមន៍

# ស្រុកកំរៀង ខេត្តបាត់ដំបង

## ១. សង្ខេបអំពីស្ថានភាពបញ្ហា

ប្រជាពលរដ្ឋនៅស្រុកកំរៀង នៃខេត្តបាត់ដំបង ភាគច្រើនជាអ្នកចំណាកស្រុកមកពីបណ្តាខេត្តតំបន់ភាគកណ្តាលមករស់នៅ និងប្រកបរបរធ្វើចំការតាមរដូវកាល ដោយពួកគាត់យកទាំងកូនតូចៗមកជាមួយ ហើយកុមារតូចៗទាំងនោះពុំមានឱកាសចូលរៀន ព្រោះនៅតំបន់នោះមិនទាន់មានសាលាមត្តេយ្យសិក្សានៅឡើយ។ ប្រជាពលរដ្ឋភាគច្រើនបានលើកបញ្ហានេះជាច្រើនលើកច្រើនសារទៅក្រុមប្រឹក្សាឃុំ តាមរយៈជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ហើយបញ្ហានេះបានដាក់ទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារស្រុក (គ.ក.ស.ក)។ ដោយយល់ឃើញថា បញ្ហានេះជាបញ្ហាអាទិភាពនៅក្នុងមូលដ្ឋាន គ.ក.ស.ក ក៏បានលើកបញ្ហានេះឡើងក្នុងកិច្ចប្រជុំក្រុមប្រឹក្សាស្រុក ដើម្បីពិនិត្យ និងសម្រេចលើការបង្កើតមត្តេយ្យសិក្សាសហគមន៍។ រដ្ឋបាលស្រុក បានចាប់ផ្តើមសម្របសម្រួលការអនុវត្តសកម្មភាពនេះ ចាប់ផ្តើមពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨។

## ២. ដំណើរការអនុវត្ត និងលទ្ធផល

បន្ទាប់ពីទទួលបានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា រដ្ឋបាលស្រុកបានរៀបចំផែនការសកម្មភាពសម្រាប់អនុវត្ត ដើម្បីឆ្លើយតបសំណូមពររបស់ប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំ។ អភិបាលស្រុកបានចាប់ផ្តើមអនុវត្តសកម្មភាព និងការអន្តរាគមន៍នានាដូចជា ណែនាំដល់ប្រធាន គ.ក.ស.ក និងអភិបាលរងស្រុកជាស្ត្រី ដើម្បីទំនាក់ទំនង និងសហការជាមួយការិយាល័យចំណុះរដ្ឋបាលស្រុក ការិយាល័យជំនាញ និងរដ្ឋបាលឃុំពាក់ព័ន្ធក្នុងការរៀបចំឱ្យមានមត្តេយ្យសិក្សាសហគមន៍នៅតាមឃុំមួយចំនួន។ បន្ថែមពីនេះទៀត ប្រធាន គ.ក.ស.ក បានទំនាក់ទំនងជាមួយក្រុមហ៊ុន និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីស្វែងរកការគាំទ្របច្ចេកទេស និងធនធានដល់ការអនុវត្តមុខងារនេះ។ បន្ទាប់ពីទទួលបានការគាំទ្រធនធាន និងបច្ចេកទេសនានា ពី "**អង្គការឧបត្ថម្ភកម្ពុជា**" និងសប្បុរសជនជប៉ុន ប្រធានគ.ក.ស.ក និងអភិបាលរងជាស្ត្រីបានចុះផ្សព្វផ្សាយអំពីគម្រោងសាងសង់ ទីតាំង និងសិក្សាពីបញ្ហាប្រឈមនានាដែលអាចកើតមានឡើង ព្រមទាំងស្វែងរកដំណោះស្រាយ។ រដ្ឋបាលស្រុកបានសម្របសម្រួលជាមួយរដ្ឋបាលឃុំពាក់ព័ន្ធ ដើម្បីប្រើប្រាស់មូលនិធិឃុំសម្រាប់ផ្តល់ប្រាក់ឧបត្ថម្ភដល់គ្រូមត្តេយ្យសិក្សាសហគមន៍ទាំងអស់។ ការិយាល័យអប់រំ យុវជន និងកីឡាស្រុក បានផ្តល់ការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាសហគមន៍ សម្ភារៈសិក្សា បច្ចេកទេស រៀបចំកម្មវិធីសិក្សា តាមដាន និងត្រួតពិនិត្យជាប្រចាំលើការងារមត្តេយ្យសិក្សាសហគមន៍។

ជាលទ្ធផល រដ្ឋបាលស្រុកបានសម្របសម្រួលបង្កើតសាលាមត្តេយ្យសិក្សាសហគមន៍ចំនួន៥ ដែលមានកុមារតូចៗចូលរៀនចំនួនប្រហែល២០០នាក់ ក្រោមជំនួយរបស់អង្គការឧបត្ថម្ភកម្ពុជា និងសប្បុរសជនជនជាតិជប៉ុន ដោយបានសាងសង់ជាអគារ ដោយបំពាក់សម្ភារៈសិក្សា និងឧបករណ៍សម្រាប់ដំណើរការដល់សាលាមត្តេយ្យសិក្សាសហគមន៍ផងដែរ។ ប្រជាពលរដ្ឋមានការពេញចិត្តនឹងការបង្កើតឱ្យមានសាលាមត្តេយ្យសិក្សាសហគមន៍ ដោយបានសម្រាលបន្ទុកការងាររបស់ពួកគាត់ក្នុងការនាំកូនទៅជាមួយនៅកន្លែងការងារ និងមានពេលច្រើនក្នុងការរកប្រាក់ចំណូល។

## ៣. បទពិសោធន៍ និងបញ្ហាប្រឈម

តាមរយៈកិច្ចខិតខំប្រឹងប្រែងអនុវត្តមុខងារនេះ រដ្ឋបាលស្រុក និងអ្នកពាក់ព័ន្ធនានាបានទទួលបទពិសោធន៍ដូចជា៖ (១) បង្កើនសមត្ថភាពក្នុងការកៀគរធនធាន និងបច្ចេកទេសពីអង្គការសប្បុរសជន និងអ្នកពាក់ព័ន្ធនានា (២) បង្កើនសមត្ថភាពក្នុងការសម្របសម្រួលជាមួយការិយាល័យជំនាញ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត (៣) ការលើកកម្ពស់កិច្ចសហការ និងការចូលរួមចំណែកធនធានរវាងរដ្ឋបាលស្រុក និងរដ្ឋបាលឃុំ និង (៤) មានការចូលរួមពីអង្គការសង្គមស៊ីវិល និងមាតាបិតាសិស្សក្នុងការអនុវត្តមុខងារនេះ។

ទោះបីយ៉ាងណាក៏ដោយ រដ្ឋបាលស្រុកបានជួបនូវបញ្ហាប្រឈមមួយចំនួនដូចជា មូលនិធិស្រុកមានចំនួនតិចតួចសម្រាប់ជួយគាំទ្រដល់ឃុំក្នុងការសាងសង់អាគារមត្តេយ្យសិក្សាសហគមន៍ និងការគាំទ្រផ្សេងៗដល់រដ្ឋបាលឃុំ។ ទន្ទឹមនឹងនេះរដ្ឋបាលឃុំពុំមានដីសាធារណៈរបស់ឃុំសម្រាប់សាងសង់សាលាមត្តេយ្យសិក្សាសហគមន៍ ព្រមជាមួយគ្នានេះរដ្ឋបាលឃុំមានការលំបាកស្វែងរកគ្រូបង្រៀនស្ម័គ្រចិត្តព្រោះប្រាក់ឧបត្ថម្ភមានចំនួនតិចតួច។

## ៤. សក្តានុពលក្នុងការពង្រីកការអនុវត្តទៅទីកន្លែងផ្សេងទៀត

ការអនុវត្តមុខងារដូចខាងលើនេះ មានសក្តានុពលក្នុងការអនុវត្តនៅតាមតំបន់ដែលពុំសូវមានសាលាមត្តេយ្យសិក្សារដ្ឋគ្រប់គ្រាន់ ឬសាលារៀននៅឆ្ងាយពីសហគមន៍។ ដើម្បីគាំទ្រដល់រដ្ឋបាលឃុំក្នុងគ្រប់គ្រងចាត់ចែងអនុវត្តមុខងារដូចខាងលើនេះ រដ្ឋបាលស្រុកគួរពិគ្រោះយោបល់ជាមួយរដ្ឋបាលឃុំក្នុងការត្រៀមថវិកា និងទីតាំងសម្រាប់បង្កើតមត្តេយ្យសិក្សាសហគមន៍។ ក្រៅពីនេះ រដ្ឋបាលស្រុកគួរមានកញ្ចប់ថវិកាសម្រាប់ចំណាយលើការងារសម្របសម្រួល និងផ្តល់ការគាំទ្របច្ចេកទេសផ្សេងៗដល់រដ្ឋបាលឃុំ។

<u>ព័ត៌មានទំនាក់ទំនង</u>

- **នាយករដ្ឋបាលសាលាស្រុក៖ លោក ពេជ្រ ឃឹម**
- **លេខទូរស័ព្ទ៖ ០៨៩ ៥៤០ ១៩០**

## ៧. ការដោះស្រាយផលប៉ះពាល់ពីការបង្ហូរកាកសំណល់ និងក្លិនស្អុយពីកសិដ្ឋានចិញ្ចឹមជ្រូក ស្រុកកៀនស្វាយ ខេត្តកណ្ដាល

### ១. សង្ខេបអំពីស្ថានភាពបញ្ហា

ប្រជាពលរដ្ឋចំនួន០៥ភូមិនៅក្នុងឃុំកំពង់ស្វាយនៃស្រុកកៀនស្វាយបានប្រឈមនឹងបញ្ហាការបង្ហូរកាកសំណល់ពីកសិដ្ឋានចិញ្ចឹមជ្រូកទៅក្នុងប្រព័ន្ធស្រោចស្រព ដែលធ្វើឱ្យកសិករមិនអាចប្រើប្រាស់ទឹកសម្រាប់ស្រោចស្រពដំណាំស្រូវបាន។ ប្រជាពលរដ្ឋបានលើកបញ្ហានេះជូនរដ្ឋបាលស្រុកតាមរយៈការដាក់បណ្ដឹងផ្ទាល់ដល់សមាជិកក្រុមប្រឹក្សាស្រុក អាជ្ញាធរភូមិ ឃុំ ដើម្បីជួយដោះស្រាយបញ្ហាដែលបានកើតឡើង។ ក្រោយពីទទួលបានបណ្ដឹងតវ៉ាពីប្រជាពលរដ្ឋ ដែលមានដីស្រែទទួលរងប៉ះពាល់ធ្ងន់ធ្ងរដោយការបង្ហូរកាកសំណល់ពីកសិដ្ឋានចិញ្ចឹមជ្រូក ក្រុមប្រឹក្សា និងរដ្ឋបាលស្រុកបានទទួលយកបញ្ហានេះមកពិភាក្សានៅក្នុងកិច្ចប្រជុំវិសាមញ្ញ និងកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សា។ បញ្ហានេះត្រូវបានចាត់ជាអាទិភាពក្នុងចំណោមបញ្ហាជាច្រើនផ្សេងទៀត របស់រដ្ឋបាលស្រុកកៀនស្វាយដោយសារមានផលប៉ះពាល់ដល់បរិស្ថាន សុខភាពមនុស្ស សត្វ និងខូចខាតដំណាំដែលធ្វើឱ្យខាតបង់សេដ្ឋកិច្ចគ្រួសារ។ ការដោះស្រាយបញ្ហានេះ ត្រូវបានអនុវត្តពីខែមេសា ឆ្នាំ២០១៧ ដល់ខែកុម្ភៈ ឆ្នាំ២០១៨។

### ២. ដំណើរការអនុវត្ត និងលទ្ធផល

ក្រោយពីសម្រេចជ្រើសរើសយកបញ្ហាខាងលើជាអាទិភាព ក្រុមប្រឹក្សាស្រុកបានសម្រេចបង្កើតក្រុមការងារមួយ ដើម្បីសិក្សាប្រមូលព័ត៌មានបន្ថែម វាយតម្លៃពីកម្រិតធ្ងន់ធ្ងរនៃបញ្ហា សម្របសម្រួលដោះស្រាយ និងតាមដានការស្ដារប្រឡាយស្រោចស្រពឱ្យបានដូចស្ថានភាពដើមវិញ។ ក្រុមការងារបានដឹកនាំដោយអភិបាលរងស្រុក១រូប និងមានការចូលរួមពីសមាជិកក្រុមប្រឹក្សាស្រុក ការិយាល័យអន្តរវិស័យ ការិយាល័យបរិស្ថាន ការិយាល័យកសិកម្ម និងការិយាល័យធនធានទឹក ព្រមទាំងតំណាងរដ្ឋបាលឃុំដែលរងផលប៉ះពាល់។ ក្រុមការងារបានលើកឡើងនូវវិធានការ ផែនការសកម្មភាព ពេលវេលាដើម្បីអនុវត្តសកម្មភាពទាំងនេះ ដោយមានការិយាល័យជំនាញពាក់ព័ន្ធចូលរួម ក្នុងការផ្ដល់យោបល់លើដំណោះស្រាយនៃបញ្ហាតាមវិស័យដែលខ្លួនទទួលខុសត្រូវ។

បន្ទាប់មក ក្រុមការងារបានសម្របសម្រួលជាមួយម្ចាស់កសិដ្ឋានអំពីពេលវេលាសម្រាប់អនុវត្តសកម្មភាពដូចជា កំណត់ពេលវេលាប្រជុំជាមួយម្ចាស់កសិដ្ឋាន និងអ្នកភូមិ ដើម្បីធ្វើកិច្ចព្រមព្រៀងក្នុងការកំណត់ពេលវេលាស្ដារប្រឡាយ កាយយកកាកសំណល់ចេញ និងបញ្ឈប់ការបង្ហូរ។ ក្នុងអំឡុងពេលអនុវត្តសកម្មភាពស្ដារប្រឡាយស្រោចស្រពនេះ ម្ចាស់កសិដ្ឋានមិនបានអនុវត្តតាមអ្វីដែលបានកំណត់ជាមួយក្រុមការងារទេ ដូច្នេះ រដ្ឋបាលស្រុក ដោយមានការចូលរួមពីការិយាល័យជំនាញ បានកំណត់ឱ្យម្ចាស់កសិដ្ឋានធ្វើកិច្ចសន្យាជាលាយល័ក្ខអក្សរ បញ្ឈប់ការបង្ហូរកាកសំណល់ពីកសិដ្ឋានចូលទៅក្នុង

ប្រឡាយទឹក និងរាំងចំណាយលើការស្តារ ការជួសជុល និងការសំអាតប្រឡាយដែលរងផលប៉ះពាល់ពីការបង្ហូរកាកសំណល់។ កិច្ចសន្យានេះគឺជាមូលដ្ឋានសម្រាប់ក្រុមការងារក្នុងការតាមដាន និងត្រួតពិនិត្យលើការអនុវត្តការងាររបស់កសិដ្ឋានចិញ្ចឹមជ្រូកខាងលើ។

ក្នុងការអនុវត្តកិច្ចសន្យានេះ ម្ចាស់កសិដ្ឋានចិញ្ចឹមជ្រូកបានធ្វើការស្តារយកកាកសំណល់ចេញពីប្រឡាយស្រោចស្រពដែលរងប៉ះពាល់ប្រវែងជាង១ពាន់ម៉ែត្រឱ្យមានស្ថានភាពល្អប្រសើរ និងអាចប្រើប្រាស់បានវិញ ដោយមានការត្រួតពិនិត្យពីក្រុមការងាររបស់រដ្ឋបាលស្រុក។ ប្រជាពលរដ្ឋមានការពេញចិត្តចំពោះវិធានការ និងអន្តរាគមន៍របស់រដ្ឋបាលស្រុក ដោយសារការងារបានជួយសង្គ្រោះស្រូវ និងស្រែរបស់គាត់ពីការខូចខាតដោយកាកសំណល់ពីកសិដ្ឋានចិញ្ចឹមជ្រូក។ កិច្ចការនេះបង្ហាញអំពីការលើកកម្ពស់គណនេយ្យភាពរបស់រដ្ឋបាលស្រុកចំពោះប្រជាពលរដ្ឋ។

## ៣. បទពិសោធន៍ និងបញ្ហាប្រឈម

រដ្ឋបាលស្រុកបានទទួលនូវបទពិសោធន៍ដូចជា៖ (១). វិធីសាស្ត្រក្នុងការចាត់អាទិភាពនៃបញ្ហាដែលបានកើតឡើងតាមកម្រិតស្ថានភាព (២). មានការចូលរួមរបស់ប្រជាពលរដ្ឋ និងការចូលរួមរបស់អង្គភាពជំនាញ ដើម្បីដោះស្រាយបញ្ហាដែលបានកើតឡើង (៣). ការយកចិត្តទុកដាក់ និងតាំងចិត្តខ្ពស់ក្នុងការឆ្លើយតបចំពោះសំណូមពររបស់ប្រជាពលរដ្ឋរងគ្រោះបានទាន់ពេលវេលា (៤). ការដោះស្រាយបញ្ហាប្រកបដោយតម្លាភាព និងប្រសិទ្ធភាព បើទោះបីជារដ្ឋបាលស្រុកមាន ឬគ្មានថវិកាក៏ដោយ។

ទោះបីជាយ៉ាងណាក៏ដោយ រដ្ឋបាលស្រុកបានជួបប្រទះបញ្ហាប្រឈមមួយចំនួនរួមមាន៖ (១). រដ្ឋបាល ស្រុកពុំមានគ្រោងថវិកាប្រចាំឆ្នាំសម្រាប់ដោះស្រាយបញ្ហាកើតឡើងជាយថាហេតុ ដែលធ្វើឱ្យរដ្ឋបាលស្រុកខ្វះថវិកាគាំទ្រការអនុវត្តសកម្មភាព និងពុំមានប្រាក់ឧបត្ថម្ភដល់បុគ្គលិកដែលអនុវត្តការត្រួតពិនិត្យសកម្មភាព (២). ការដោះស្រាយបញ្ហានានាជាមួយវិស័យឯកជនមានការលំបាក ជាក់ស្តែងដូចជាការដោះស្រាយបញ្ហាជាមួយកសិដ្ឋានចិញ្ចឹមជ្រូកខាងលើ ដោយសារគាត់មានការអនុញ្ញាតអាជីវកម្មពីមន្ទីរជំនាញ និងអាជ្ញាធរថ្នាក់ខេត្ត ដែលតម្រូវឱ្យមានការអន្តរាគមន៍គាំទ្រពីមន្ទីរជំនាញ និងសមត្ថកិច្ចពាក់ព័ន្ធ ដែលធ្វើឱ្យរដ្ឋបាលស្រុកមានការលំបាកសម្របសម្រួលដោះស្រាយបញ្ហាជាមួយម្ចាស់កសិដ្ឋានជាច្រើនលើកច្រើនសារ។

## ៤. សក្តានុពលក្នុងការពង្រីកការអនុវត្តទៅទីកន្លែងផ្សេងទៀត

ការអនុវត្តបានជោគជ័យ គឺអាស្រ័យលើយន្តការសម្របសម្រួល និងការចូលរួមរបស់អង្គភាពជំនាញពាក់ព័ន្ធ។ ទោះបីមានកិច្ចសន្យាជាលាយល័ក្ខអក្សរជាមួយកសិដ្ឋានចិញ្ចឹមជ្រូកក៏ដោយរដ្ឋបាលស្រុកចាំបាច់ត្រូវពង្រឹងយន្តការ និងមធ្យោបាយក្នុងការត្រួតពិនិត្យ និងតាមដានជាប្រចាំលើការអនុវត្តកិច្ចសន្យានេះ។

ក្រៅពីនេះ ការចូលរួមអន្តរាគមន៍របស់រដ្ឋបាលខេត្ត និងមន្ទីរជំនាញថ្នាក់ខេត្តគឺមានភាពចាំបាច់ ពីព្រោះស្ថានភាពបច្ចុប្បន្ន ស្ថាប័នថ្នាក់ជាតិ រដ្ឋបាលខេត្ត និងមន្ទីរជំនាញថ្នាក់ខេត្ត ជាអ្នកផ្តល់ការអនុញ្ញាតដល់សហគ្រាស និងក្រុមហ៊ុនឯកជនក្នុងការប្រកបអាជីវកម្ម ដែលធ្វើឱ្យរដ្ឋបាលស្រុកមានឥទ្ធិពលតិចតួចក្នុងការត្រួតពិនិត្យ ឬដាក់វិធានការណែនាំផ្សេងៗ។ ដើម្បីបង្កើនឱ្យមានប្រសិទ្ធភាពការងាររបស់រដ្ឋបាល ក្រុង ស្រុក រដ្ឋបាលក្រុង ស្រុក ចាំបាច់ត្រូវគិតគូរគ្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួនសម្រាប់ចំណាយជាយថាហេតុណាមួយកើតឡើងពាក់ព័ន្ធការអនុវត្តមុខងារជាអាណត្តិទូទៅ។

<u>ព័ត៌មានទំនាក់ទំនង</u>

- **នាយករដ្ឋបាលសាលាស្រុក៖ លោកស្រី ង៉ាម វាសនា**
- **លេខទូរស័ព្ទ៖ ០៧៧ ៩៨០ ៩៩០ / ០៨១ ៥០២ ៥០៣**

# ៨. ការលើកកម្ពស់ការយល់ដឹងអំពីការសម្អាតដៃនៅតាមសាលាបឋមសិក្សា ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង

## ១. សង្ខេបអំពីស្ថានភាពបញ្ហា

ក្រុមប្រឹក្សា និងរដ្ឋបាលស្រុកទទួលបានព័ត៌មានជាច្រើនពីឪពុកម្តាយសិស្ស គណៈកម្មការទ្រទ្រង់សាលា និងក្រុមប្រឹក្សាឃុំ ដោយលើកឡើងថាសាលាបឋមសិក្សាភាគច្រើនពុំមានទឹកស្អាតប្រើប្រាស់សម្រាប់សម្អាតដៃ និងបរិភោគ ព្រមទាំងបង្គន់ពុំមានអនាម័យជាដើម។ បញ្ហាពុំមានទឹកស្អាតនេះ បានបណ្តាលឱ្យសិស្សជាច្រើនមានជម្ងឺរាគរូសដែលធ្វើឱ្យប៉ះពាល់ដល់សុខភាព និងលទ្ធផលនៃការរៀនសូត្ររបស់សិស្សជាដើម។ ក្រុមប្រឹក្សាស្រុកបានណែនាំឱ្យរដ្ឋបាលស្រុក និងការិយាល័យអប់រំ យុវជន និងកីឡាស្រុក សហការគ្នាធ្វើការពិនិត្យ និងពិគ្រោះយោបល់ជាមួយគណៈគ្រប់គ្រងសាលាបឋមសិក្សាដែលពាក់ព័ន្ធ ដើម្បីស្វែងយល់លម្អិតលើបញ្ហានេះ។ ដោយពិនិត្យឃើញបញ្ហានេះពិតជាបានកើតឡើង ដូចព័ត៌មានដែលបានផ្តល់ដោយអ្នកពាក់ព័ន្ធខាងលើ រដ្ឋបាលស្រុកបានស្នើសុំយកបញ្ហានេះមកដាក់ក្នុងរបៀបវារៈក្នុងកិច្ចប្រជុំក្រុមប្រឹក្សា ដើម្បីពិនិត្យ និងកំណត់អាទិភាពនៃបញ្ហា។ ក្នុងកិច្ចប្រជុំក្រុមប្រឹក្សា រដ្ឋបាលស្រុកបានរាយការណ៍អំពីលទ្ធផលនៃការចុះសិក្សាលើបញ្ហាពុំមានទឹកស្អាតប្រើប្រាស់នៅតាមសាលាបឋមសិក្សា ហើយ បញ្ហានេះត្រូវបានអនុម័តដោយក្រុមប្រឹក្សាស្រុក ជាបញ្ហាអាទិភាពជាងបញ្ហាផ្សេងទៀត ដែលត្រូវការដោះស្រាយជាបន្ទាន់ និងមានលទ្ធភាព ធនធាន និងបច្ចេកទេសសម្រាប់ដោះស្រាយបញ្ហានេះបាន។ ក្រុមប្រឹក្សាស្រុកបានជ្រើសរើសយកសាលាបឋមសិក្សាចំនួន០២ ដែលមានសិស្សសរុបប្រមាណ៤០០នាក់ ដើម្បីអនុវត្ត "**ការលើកកម្ពស់ការយល់ដឹងអំពីការលាងសម្អាតដៃនៅតាមសាលាបឋមសិក្សា**" ដែលបានអនុវត្តចាប់ពីខែឧសភា ដល់ខែកក្កដា ឆ្នាំ២០១៨ ដោយមានការគាំទ្របច្ចេកទេស និងថវិការបស់គម្រោងសហភាពអ៊ឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល (EU-DAR/GIZ)។

## ២. ដំណើរការអនុវត្ត និងលទ្ធផល

ក្នុងការអនុវត្តមុខងារនេះ ក្រុមប្រឹក្សាបានណែនាំដល់អភិបាលស្រុកឱ្យរៀបចំបង្កើតក្រុមការងារអនុវត្តមុខងារខាងលើនេះ ដោយមានសមាសភាពមកពីការិយាល័យចំណុះរដ្ឋបាលស្រុក ការិយាល័យអប់រំ យុវជន និងកីឡាស្រុក និងមណ្ឌលសុខភាព។ ក្រុមការងារបានទំនាក់ទំនងជាមួយអង្គការសង្គមស៊ីវិលដែលមានបទពិសោធន៍អំពីការលាងសម្អាតដៃ ដើម្បីស្នើសុំការគាំទ្របច្ចេកទេសក្នុងការសាងសង់ឧបករណ៍សម្រាប់លាងសម្អាតដៃនៅតាមសាលារៀន ព្រមទាំងបង្ហាត់បង្រៀនសិស្សពីរបៀបលាងដៃ និងវិធីរក្សាអនាម័យជៀសវាងការចម្លងមេរោគផ្សេងៗ។

បន្ទាប់មក ក្រុមការងារបានរៀបចំសេចក្តីព្រាងសំណើគម្រោង (ផែនការសកម្មភាព ថវិកា ពេលវេលា និងអ្នកទទួលផល) ដាក់ជូនគណៈអភិបាលពិនិត្យ និងឯកភាពមុនពេលដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។ ក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សា សំណើគម្រោងនេះត្រូវបានដាក់ជូនទៅគម្រោង EU-DAR/GIZ ដើម្បីស្នើសុំថវិកាសម្រាប់អនុវត្ត។ នៅពេលទទួលបានការឯកភាពផ្តល់ថវិកាពីគម្រោង EU-DAR/GIZ រដ្ឋបាលស្រុកបានធ្វើការប្រកាសដេញថ្លៃសាងសង់ឧបករណ៍លាងសម្អាតដៃជាសាធារណៈ តាមនីតិវិធីលទ្ធកម្មគម្រោងរបស់ក្រុង ស្រុក។

ក្នុងអំឡុងពេលអនុវត្តការងារសាងសង់ឧបករណ៍លាងសម្អាតដៃនេះ ប្រធានក្រុមប្រឹក្សា និងគណៈអភិបាលបានសម្របសម្រួលដោះស្រាយបញ្ហាផ្សេងៗដូចជា ដឹកនាំ និងចាត់ចែងការងារលទ្ធកម្ម ណែនាំការអនុវត្តកិច្ចសន្យាសាងសង់ និងពិនិត្យមើលរបាយការណ៍របស់ក្រុមការងារ មុននឹងដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាប្រចាំខែ ឬកិច្ចប្រជុំនានាតាមការចាំបាច់។ រដ្ឋបាលស្រុកបានសាងសង់អាងទឹក ប្រព័ន្ធទុយោទឹក និងឧបករណ៍លាងដៃនៅក្នុងសាលាបឋមសិក្សាចំនួន២ ដោយមានការគាំទ្រការណែនាំគោលការណ៍បច្ចេកទេស និងស្តង់ដារនៃការតម្លើងឧបករណ៍សម្ភារៈពីការិយាល័យអប់រំ យុវជន និងកីឡានិងមណ្ឌលសុខភាព។ ការអនុវត្តមុខងារនេះ ត្រូវបានគ្រោងចំណាយថវិកាប្រមាណ៥.៦០០ ដុល្លារ ដែលបានរួមចំណែកពីថវិកាឧបត្ថម្ភធនរបស់កម្មវិធី EU-DAR/DAR ចំនួន៩០% និងថវិការបស់រដ្ឋបាលស្រុកចំនួន១០% ព្រមទាំងមានការចូលរួមពីសហគមន៍នូវកម្លាំងពលកម្ម និងសម្ភារៈប្រើប្រាស់ដូចជា សាប៊ូ កន្សែង។ល។ ជាមួយគ្នានេះ អង្គការ World Vision បានចូលរួមចំណែកគាំទ្រដល់សាលាបឋមសិក្សាទាំង២ ដោយបានផ្តល់នូវសម្ភារៈ និងឧបករណ៍មួយចំនួនសម្រាប់សិស្ស និងបានចូលរួមក្នុងការបង្រៀនដល់សិស្សអំពីការលាងសម្អាតដៃ ព្រមទាំងបង្ហាត់បង្រៀនដល់គណៈគ្រប់គ្រងសាលាអំពីការគ្រប់គ្រងការប្រើប្រាស់ ថែទាំប្រព័ន្ធ និងឧបករណ៍លាងសម្អាតដៃ។ លើសពីនេះទៀត អភិបាលស្រុកក៏បានទំនាក់ទំនងជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត តាមរយៈការិយាល័យអប់រំ យុវជន និងកីឡាស្រុក និងទីប្រឹក្សាអភិបាលកិច្ចមូលដ្ឋានរបស់ EU-DAR/GIZ ស្វែងរកគាំទ្រដល់ការធ្វើទស្សនកិច្ចសិក្សាអំពីការអនុវត្តកម្មវិធីការលាងសម្អាតដៃ នៅសាលាបឋមសិក្សាមួយក្នុងខេត្តកំពត ដើម្បីសិក្សាពីបទពិសោធន៍នៃការអនុវត្តមុខងារលាងសម្អាតដៃមកអនុវត្តនៅក្នុងស្រុករបស់ខ្លួន។

ជាលទ្ធផល ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ មាតាបិតា អាណាព្យាបាល និងសិស្សានុសិស្សមានភាពសប្បាយចិត្ត និងពេញចិត្ត ចំពោះក្រុមប្រឹក្សា និងរដ្ឋបាលស្រុកដែលបានខិតខំប្រឹងប្រែងបង្កើតឱ្យមានឧបករណ៍លាងសម្អាតដៃនៅតាមសាលារៀននេះ ហើយមាតាបិតា និងអាណាព្យាបាលសិស្សក៏តែងតែចូលរួមវិភាគទានជាសម្ភារៈ (សាប៊ូ កន្សែងជាដើម) កំលាំងពលកម្ម ដើម្បីថែទាំ និងជួលជុលប្រព័ន្ធ និងឧបករណ៍លាងសម្អាតដៃនេះជាប្រចាំដែរ។

## ៣. បទពិសោធន៍ និងបញ្ហាប្រឈម

តាមរយៈការអនុវត្តមុខងារនេះ រដ្ឋបាលស្រុកទទួលបាននូវបទពិសោធន៍ល្អៗរួមមាន៖ (១). ការបង្កើនចំណេះដឹង និងបទពិសោធន៍ពីខេត្តដទៃទៀត តាមរយៈទស្សនកិច្ចសិក្សានៅតាមសាលា

បឋមសិក្សាក្នុងខេត្តកំពតដែលបានកំពុងអនុវត្តគម្រោងដូចគ្នានេះ (២). សមត្ថភាពរបស់ក្រុមប្រឹក្សា និងរដ្ឋបាលស្រុកក្នុងការកៀរគរធនធាន និងជំនួយបច្ចេកទេសពីអង្គការសង្គមស៊ីវិល សហគមន៍ និងអ្នកពាក់ព័ន្ធនានា (៣). កិច្ចសហការរបស់ការិយាល័យជំនាញក្នុងការចូលរួមអនុវត្តមុខងារនេះ (៤). ការចូលរួមសហការរបស់គណៈគ្រប់គ្រងសាលា និងបដិភាគជាសម្ភារៈ និងកម្លាំងពលកម្មរបស់សហគមន៍ មាតាបិតា អាណាព្យាបាល និងសិស្សានុសិស្ស។

ទន្ទឹមនឹងនេះ រដ្ឋបាលស្រុកបានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនរួមមាន៖ រដ្ឋបាលស្រុកខ្វះបុគ្គលិក និងថវិកាសម្រាប់អនុវត្តមុខងារបែបនេះនៅពេលដែលមានសំណើរពីសាលាបឋមសិក្សាជាច្រើន ក្រៅពីនេះសាលារៀនមួយចំនួនពុំមានប្រភពទឹកស្អាតសម្រាប់ប្រើប្រាស់ និងពុំមានថវិកាសម្រាប់ការថែទាំឧបករណ៍សម្ភារៈក្រោយពេលសាងសង់រួច។ ម៉្យាងទៀត ដំណើរការរៀបចំ និងអនុវត្តមុខងារនេះ ត្រូវចំណាយពេលវេលាយូរប្រហែល(៦ទៅ៨ខែ)។

## ៤. សក្តានុពលក្នុងការពង្រីកការអនុវត្តទៅទីកន្លែងផ្សេងទៀត

ការអនុវត្តមុខងារនេះមានសក្តានុពលខ្លាំងក្នុងការពង្រីក ទៅតាមសាលាបឋមសិក្សានៅជនបទដែលមានសិស្សតូចៗ និងសហគមន៍ដែលនៅឆ្ងាយពីមណ្ឌលសុខភាព។ រដ្ឋបាលស្រុកដែលចង់អនុវត្តមុខងារនេះត្រូវពិភាក្សាជាមួយគណៈគ្រប់គ្រងសាលា គណៈកម្មការទ្រទ្រង់សាលា សហគមន៍ និងអង្គការសង្គមស៊ីវិល ដើម្បីកៀរគរធនធានថវិកា សម្ភារៈ និងកម្លាំងពលកម្មសម្រាប់ការសាងសង់ថែទាំ និងជួសជុលប្រព័ន្ធ និងឧបករណ៍លាងសម្អាតដៃជាប្រចាំ។ ក្រុមប្រឹក្សា និងរដ្ឋបាលស្រុកត្រូវតែចាត់តាំងឱ្យមានអ្នកទទួលបន្ទុកក្នុងការត្រួតពិនិត្យ និងតាមដានការគ្រប់គ្រង ការប្រើប្រាស់ និងថែទាំឧបករណ៍លាងសម្អាតដៃជាមួយគណៈគ្រប់គ្រងសាលាបឋមសិក្សាជាប្រចាំ។ ក្រៅពីនេះ ត្រូវមានការផ្សារភ្ជាប់រវាងការអប់រំណែនាំដល់សិស្សានុសិស្ស ប្រជាពលរដ្ឋ មាតាបិតា និងអាណាព្យាបាលសិស្សតាមរយៈមណ្ឌលសុខភាព ក្រុមប្រឹក្សាឃុំ និងសាលារៀន។ ក្រុមប្រឹក្សា និងគណៈអភិបាលស្រុក គួរពិចារណាដាក់បញ្ចូលមុខងារ ប្រភេទជាសេវាសង្គមទៅក្នុងផែនការថវិកាប្រចាំឆ្នាំរបស់ខ្លួន។

**<u>ព័ត៌មានទំនាក់ទំនង</u>**

- **នាយករដ្ឋបាលរដ្ឋបាល៖ ម៉ៅ សុចាន់**
- **លេខទូរស័ព្ទ៖ ០៨៨ ៣១១ ១៤១១**

# ៩. រៀបចំយុទ្ធនាការយល់ដឹងពីការគ្រប់គ្រងសំរាម សំណល់រឹង ស្រុក លើកដែក ខេត្តកណ្តាល

## ១. សង្ខេបអំពីស្ថានភាពបញ្ហា

បញ្ហាសំរាម សំណល់រឹងតាមផ្ទះ ពិសេសនៅតំបន់ទីប្រជុំជន បានកំពុងក្លាយជាអាទិភាពខ្ពស់របស់រដ្ឋបាលក្រុង ស្រុក ដែលត្រូវដោះស្រាយ។ ស្រុកលើកដែក (ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ១ ភ្ជាប់ពីរាជធានីភ្នំពេញទៅកាន់ប្រទេសវៀតណាម) ក៏កំពុងជួបប្រទះបញ្ហាសំរាមក្នុងស្ថានភាពធ្ងន់ធ្ងរ ដោយសារប្រជាពលរដ្ឋនិងអាជីវករមួយចំនួន បានបោះចោលសំរាមពាសវាលពាសកាលនៅតាមដងក្នុងមូលដ្ឋាន និងតាមផ្លូវជាតិ ខ្វះការវេចខ្ចប់សំរាមបានត្រឹមត្រូវ ដែលបង្កក្លិនកខ្វក់ ប៉ះពាល់សុខភាពប្រជាពលរដ្ឋ បរិស្ថាន និងសោភ័ណភាពនៅតាមដងផ្លូវជាតិ ដែលមានទេសចរណ៍អន្តរជាតិធ្វើដំណើរច្រើន។ រដ្ឋបាលស្រុកតែងទទួលរងការរិះគន់ពីប្រជាពលរដ្ឋ សមាជិកក្រុមប្រឹក្សាស្រុក និងឃុំ ថ្នាក់ដឹកនាំខេត្ត អំពីការខ្វះចន្លោះនៃការគ្រប់គ្រងសំរាម ហើយតែងបានលើកសំណូមពរតាមរយៈវេទិកា ឬកិច្ចប្រជុំនានា ដោយស្នើសុំឱ្យរដ្ឋបាលស្រុក យកចិត្តទុកដាក់ដោះស្រាយ លើការគ្រប់គ្រងសំរាមឱ្យបានល្អ។ ដោយមានសំណូមពរជាច្រើន ក្រុមប្រឹក្សាស្រុកបានដាក់បញ្ចូលបញ្ហានេះទៅក្នុងកិច្ចប្រជុំរបស់ខ្លួនដោយពិភាក្សាជាមួយគណៈអភិបាល និងការិយាល័យជំនាញពាក់ព័ន្ធ ព្រមទាំងបានអនុម័តយកបញ្ហាសំរាមជាអាទិភាពដែលត្រូវដោះស្រាយ។ រដ្ឋបាលស្រុក បានសម្រេចយកការធ្វើយុទ្ធនាការយល់ដឹងដល់ប្រជាពលរដ្ឋអំពីការគ្រប់គ្រងសំរាម សំណល់រឹង។ សកម្មភាពនេះ ត្រូវបានអនុវត្តចាប់ផ្តើមពីខែកុម្ភៈ ដល់ខែកក្កដា ឆ្នាំ២០១៨ នៅទូទាំងស្រុក ពិសេសប្រជាពលរដ្ឋនៅក្នុង៣ឃុំ ដែលរស់នៅតាមដងផ្លូវជាតិលេខ១។

## ២. ដំណើរការអនុវត្ត និងលទ្ធផល

ក្រុមប្រឹក្សាបានណែនាំគណៈអភិបាលបង្កើតគណៈកម្មការចម្រុះ ដឹកនាំដោយអភិបាលរង១រូប ហើយសមាសភាពរួមមាននាយករងរដ្ឋបាលស្រុក ការិយាល័យអន្តរវិស័យ ការិយាល័យបរិស្ថាន និងមេឃុំពាក់ព័ន្ធ។ គណៈកម្មការចម្រុះ បានប្រមូលព័ត៌មានពីចំនួនប្រជាពលរដ្ឋ ពិគ្រោះយោបល់អំពីកម្រៃសេវាប្រមូលសំរាម ការកំណត់ទីលានចោលសំរាម វិធានការនានាក្នុងការគ្រប់គ្រងសំរាមតាមរយៈកិច្ចប្រជុំច្រើន។ ព្រមជាមួយគ្នានេះ អភិបាលបានណែនាំការិយាល័យពាក់ព័ន្ធ សិក្សាស្រាវជ្រាវរកលិខិតបទដ្ឋានពាក់ព័ន្ធ ទំនាក់ទំនងជាមួយរដ្ឋបាលខេត្ត និងមន្ទីរបរិស្ថានខេត្ត ដើម្បីស្នើសុំការគាំទ្របច្ចេកទេស។ បន្ទាប់ពីប្រមូលបានព័ត៌មានចាំបាច់នានា គណៈកម្មការបានរៀបចំសេចក្តីព្រាងសំណើគម្រោង (សកម្មភាព ថវិកា ពេលវេលា អ្នកទទួលផល...) ដើម្បីដាក់ជូនគណៈអភិបាលពិនិត្យ ឯកភាព មុនពេលដាក់ជូនក្រុមប្រឹក្សាសម្រាប់ពិភាក្សា និងអនុម័ត។ ក្រោយអនុម័តរួច សំណើគម្រោងនេះត្រូវបានដាក់ជូនទៅគម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល

(EU-DAR/GIZ) ស្នើសុំថវិកាសម្រាប់អនុវត្ត ដែលក្នុងនោះគម្រោង EU-DAR/GIZ បានគាំទ្រចំនួន ៥.០០០ដុល្លារ ហើយរដ្ឋបាលស្រុកបានរួមចំណែក១០%ប្រមាណ៥០០ដុល្លា។

ក្នុងពេលអនុវត្តសកម្មភាព គណៈកម្មការនេះធ្វើការយ៉ាងជិតស្និតជាមួយប្រជាពលរដ្ឋ អាជីវករ សិស្សសាលា ដោយរៀបចំជាយុទ្ធនាការនៅតាមភូមិ និងទីប្រជុំជននានា ដើម្បីផ្សព្វផ្សាយពីយល់ដឹងពីបរិស្ថាន ការវេចខ្ចប់សំរាមតាមផ្ទះ ការចូលរួមបង់កម្រៃសេវាប្រមូលសំរាម និងចូលរួមអនុវត្តតាមការណែនាំផ្សេងក្នុងការចោលសំរាម។ គណៈកម្មការគ្រប់គ្រងសំរាមបានតែងតាំងប្រធានការិយាល័យអន្តរវិស័យ និងប្រធានការិយាល័យបរិស្ថានដើម្បីត្រួតពិនិត្យតាមដានអំពីគុណភាពនៃការផ្តល់សេវា។ ហើយនៅពេលអនុវត្ត គណៈកម្មការបានសហការជាមួយអាវុធហត្ថ និងអធិការនគរបាលស្រុក ចូលរួមផងដែរ។ ក្នុងពេលអនុវត្តគណៈកម្មការ បានរៀបចំរបាយការណ៍វឌ្ឍនភាព និងបញ្ហាប្រឈមនានានៃការអនុវត្តសកម្មភាព ជូនគណៈអភិបាល និងក្រុមប្រឹក្សាក្នុងកិច្ចប្រជុំរបស់ខ្លួន ពិនិត្យនិងផ្តល់យោបល់ ឬអន្តរាគមន៍ផ្សេង។

តាមរយៈការអនុវត្តមុខងារនេះ រដ្ឋបាលស្រុកបានធ្វើការផ្សព្វផ្សាយអប់រំអំពីផលប៉ះពាល់នៃការបោះចោលសំរាម និងការប៉ះពាល់ចំពោះសោភ័ណភាពនៅតាមផ្លូវជាតិ។ ការផ្សព្វផ្សាយនេះត្រូវបានធ្វើតាមរយៈឧឃោសនសព្ទតាមភូមិ ការផលិតផ្ទាំងប៉ាណូអប់រំ ដែលដាក់នៅតាមដងផ្លូវ ការអប់រំតាមសាលារៀន។ ប្រជាពលរដ្ឋបានចូលរួមសហការយ៉ាងជិតស្និតតាំងពីការចាប់ផ្តើមដំបូងតាមរយៈកិច្ចប្រជុំនានា យុទ្ធនាការយល់ដឹងពីបរិស្ថាន ការចូលរួមបង់កម្រៃសេវាប្រមូលសំរាម និងចូលរួមអនុវត្តតាមការណែនាំផ្សេងក្នុងការចោលសំរាម។ ប្រជាពលរដ្ឋមានការពេញចិត្តដោយសារបានឃើញក្រុមប្រឹក្សា និងរដ្ឋបាលស្រុកទទួលយកនូវបញ្ហារបស់ពួកគាត់មកដោះស្រាយ។

## ៣. បទពិសោធន៍ និងបញ្ហាប្រឈម

តាមរយៈការអនុវត្តមុខងារនេះ រដ្ឋបាលស្រុក និងអ្នកពាក់ព័ន្ធនានាបានទទួលបទពិសោធន៍ជាច្រើនរួមមាន ការចូលរួមសហការយ៉ាងជិតស្និតរវាងប្រជាពលរដ្ឋ រដ្ឋបាលឃុំ និងមន្ត្រីនគរបាលដើម្បីពង្រឹងការអនុវត្តវិធានការ ឬការណែនាំលើការគ្រប់គ្រងសំរាម។ ដោយសាររដ្ឋបាលស្រុក និងការិយាល័យបរិស្ថានខ្វះបុគ្គលិក ហេតុនេះការបង្កើតក្រុមការងារ ឬគណៈកម្មការបានប្រមូលផ្តុំធនធានមនុស្សដើម្បីគាំទ្រការអនុវត្តមុខងារនានា។ ដំណើរការរៀបចំឯកសារគម្រោងស្នើថវិកា ត្រូវការចំណាយពេលច្រើនពេកដោយសារតម្រូវឱ្យមានការចូលរួមពាក់ព័ន្ធពីក្រុមប្រឹក្សា គណៈអភិបាល គណៈកម្មការចម្រុះ ព្រោះមុខងារនេះមានលក្ខណៈអន្តរវិស័យដែលត្រូវពាក់ព័ន្ធជាមួយអង្គភាពជាច្រើន។ ដំណើរការផ្តល់សេវាប្រមូលសំរាម គឺត្រូវការចាំបាច់ការចូលរួមរបស់វិស័យឯកជន ក្នុងការប្រមូលសំរាម ព្រោះរដ្ឋបាលស្រុកពុំមានធនធាន មធ្យោបាយផ្សេងៗសម្រាប់អនុវត្តបាន។

**ទន្ទឹមនឹងនេះរដ្ឋបាលស្រុកបានជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចជា** ខ្វះមន្ត្រីដែលមានជំនាញបរិស្ថាន ការិយាល័យបរិស្ថានស្រុកមានបុគ្គលិកតែម្នាក់ដែលពុំអាចរ៉ាប់រងការងារបច្ចេកទេស

បាន ខ្វះមធ្យោបាយ ធនធានឧបត្ថម្ភដល់មន្ត្រីបំពេញការងារនេះ។ រដ្ឋបាលស្រុក ពុំមានថវិកាគាំទ្រ យុទ្ធនាការអប់រំ នៅពេលដែលកម្មវិធី EU-DAR/GIZ បានបញ្ចប់ការងាររបស់ខ្លួន។ ចំណេះដឹងរបស់ប្រជាពលរដ្ឋក្នុងការគ្រប់គ្រងសំរាមនៅកម្រិតទាប។ ក្រៅពីនេះ រដ្ឋបាលស្រុកពិបាករកអ្នកម៉ៅការឯកជនសម្រាប់ប្រមូលសំរាម ព្រោះសេវាប្រមូលសំរាមមានលក្ខណៈស្មុគស្មាញ ហើយត្រូវការចំណាយលើមធ្យោបាយសម្ភារៈ ខ្វះទីលានចាក់សំរាម។

## ៤. សក្តានុពលក្នុងការពង្រីកការអនុវត្តទៅទីកន្លែងផ្សេងទៀត

បច្ចុប្បន្នមុខងារគ្រប់គ្រងសំរាម សំណល់រឹងនៅតាមទីប្រជុំជនកំពុងក្លាយជាមុខងារចម្បងមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេសបន្ទាប់ពីមុខងារនេះត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ដែលជាមុខងារជាកាតព្វកិច្ចហើយរដ្ឋបាលក្រុង ស្រុកត្រូវអនុវត្ត។ ក្នុងការអនុវត្ត រដ្ឋបាលស្រុកត្រូវតែមានសិទ្ធិអំណាចក្នុងការវិភាជថវិកាប្រចាំរបស់ខ្លួនសម្រាប់គាំទ្រការអនុវត្តការផ្តល់សេវាបែបនេះ។ រដ្ឋបាលក្រុង ស្រុក ត្រូវត្រៀមទីតាំងសម្រាប់ធ្វើជាទីលានចាក់សំរាម ឬរដ្ឋបាលក្រុង ស្រុកអាចពិភាក្សាជាមួយរដ្ឋបាលខេត្ត ឬរដ្ឋបាលក្រុង ស្រុកផ្សេងទៀតក្នុងប្រើប្រាស់ទីលានរួមគ្នា ម្យ៉ាងទៀតត្រូវមានវិធានការម៉ឺងម៉ាត់ចំពោះអ្នកចោលសំរាមពាលវាលពាសកាល បើមិនដូច្នេះ ការគ្រប់គ្រងសំរាមនឹងមិនបានជោគជ័យ។

<u>**ព័ត៌មានទំនាក់ទំនង**</u>

- **នាយករដ្ឋបាលស្រុក៖ លោក នួន វណ្ណាឈរ**
- **លេខទូរស័ព្ទ៖ ០៩៦៣៣៧២២៩៨**

## ១០. ការលើកកម្ពស់ការយល់ដឹងអំពីការផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ
## ស្រុក មោងឬស្សី ខេត្តបាត់ដំបង

### ១. សង្ខេបអំពីស្ថានភាពបញ្ហា

នៅក្នុងឆ្នាំ២០១៧ ក្រសួងមហាផ្ទៃបានសម្រេចឱ្យរដ្ឋបាលស្រុក រៀបចំដាក់ឱ្យដំណើរការការិយាល័យច្រកចេញចូលតែមួយក្នុងផ្តល់សេវារដ្ឋបាលផ្សេងៗរួមទាំងសេវាដែលធ្លាប់ផ្តល់ដោយមន្ទីរ ឬការិយាល័យជំនាញនានា។ ក្រោយពីដាក់ឱ្យដំណើរមួយរយៈពេលមក ការិយាល័យច្រកចេញចូលតែមួយ និងរដ្ឋបាលស្រុក យល់ឃើញថាប្រជាពលរដ្ឋ មិនទាន់យល់ដឹងអំពីតួនាទី ភារកិច្ច និងប្រភេទសេវារដ្ឋបាលអ្វីខ្លះដែលការិយាល័យនេះអាចផ្តល់បាន ហេតុនេះប្រជាពលរដ្ឋនៅតែទៅសុំសេវាទាំងនេះពីរដ្ឋបាលខេត្ត ឬមន្ទីរជំនាញខេត្ត។ ការស្នើសុំសេវារដ្ឋបាលពីសាលាខេត្ត ឬមន្ទីរជំនាញខេត្ត ប្រជាពលរដ្ឋត្រូវចំណាយពេលយូរ និងធនធានច្រើន។ ដោយមានសំណើ និងការផ្តួចផ្តើមពីសមាជិកក្រុមប្រឹក្សា និងគណៈអភិបាលស្រុក និងសមាជិកក្រុមប្រឹក្សាឃុំ ដើម្បីផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋបានដឹង អាស្រ័យហេតុនេះរដ្ឋបាលស្រុក ដោយមានការសម្រេចពីក្រុមប្រឹក្សាស្រុក បានអនុម័តយកការរៀបចំយុទ្ធនាការមួយចំនួនដើម្បីអប់រំលើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋ អំពីការបង្កើតការិយាល័យច្រកចេញចូលតែមួយជាអាទិភាព។ សកម្មភាពនៃការផ្សព្វផ្សាយអំពីដំណើរការរបស់ការិយាល័យច្រកចេញតែមួយនេះត្រូវអនុវត្តពីខែមីនា ដល់ខែឧសភា ឆ្នាំ២០១៨ ដោយផ្តោតលើប្រជាពលរដ្ឋនៅក្នុងឃុំចំនួន៤។

### ២. ដំណើរការអនុវត្ត និងលទ្ធផល

បន្ទាប់ពីការសម្រេចរបស់ក្រុមប្រឹក្សា ចាត់តាំងក្រុមការងារ ដែលដឹកនាំដោយអភិបាលរងស្រុក ១រូប ដោយមានសមាជិកមកពីការិយាល័យចំណុះសាលាស្រុក និងការិយាល័យជំនាញជុំវិញស្រុក។ ដោយមានការគាំទ្រពីការិយាល័យជំនាញពាក់ព័ន្ធ។ ក្រុមការងារបានធ្វើការជាមួយរដ្ឋបាលឃុំ សាលារៀន ផ្សារ ការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ ដើម្បីរៀបចំសំណើគម្រោងដោយការប្រមូលព័ត៌មានពាក់ព័ន្ធ ការកំណត់បញ្ហា និងសំណើវិធីសាស្ត្រផ្សព្វផ្សាយនានា ដើម្បីលើកកម្ពស់ការយល់ដឹង និងការផ្តល់ព័ត៌មានគ្រប់គ្រាន់ដល់ប្រជាពលរដ្ឋ។ ក្រុមការងារបានរៀបចំសេចក្តីព្រាងសំណើគម្រោង (សកម្មភាព ថវិកា ពេលវេលា អ្នកទទួលផល...) ដើម្បីដាក់ជូនគណៈអភិបាលពិនិត្យ ឯកភាព មុនពេលដាក់ជូនក្រុមប្រឹក្សាសម្រាប់ពិភាក្សា និងអនុម័ត។ ក្រោយអនុម័តរួច សំណើគម្រោងនេះត្រូវបានដាក់ជូនទៅ EU-DAR/GIZ ស្នើសុំថវិកាសម្រាប់អនុវត្ត ដែលក្នុងនោះគម្រោងEU-DAR/GIZ បានគាំទ្រចំនួន៤.៩៥០ដុល្លារ ហើយរដ្ឋបាលស្រុកបានរួមចំណែក ១០%ប្រមាណ៥០០ដុល្លា។ ដោយមានការគាំទ្រពីការិយាល័យជំនាញពាក់ព័ន្ធ ក្រុមការងារបានសហ

ការជាមួយការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ ដើម្បីអនុវត្តដំណើរការ យុទ្ធការ ការរៀបចំវេទិកា និងកម្មវិធីផ្សព្វផ្សាយផ្សេងៗតាមទីសាធារណៈអំពីដំណើរការរបស់ ការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ ដែលបានធ្វើនៅតាមឃុំ ទីប្រជុំជន។ យុទ្ធនាការអប់រំនេះ នឹងត្រូវធ្វើនៅតាមឃុំមួយចំនួន តាមរយៈរៀបចំកម្មវិធីនានាតាមទីសាធារណៈ ដោយប្រើប្រាស់ឧឃោសនសព្ទ ការប្រគុំតន្ត្រី ការរៀបចំវេទិកាដោយមានសំណួរ ចម្លើយ ដែលមាន ការចូលរួមពីគណៈអភិបាល សមាជិកក្រុមប្រឹក្សា និងការិយាល័យជំនាញពាក់ព័ន្ធ។ ទន្ទឹមនឹងនេះ រដ្ឋ បាលស្រុកបានស្នើសុំការគាំទ្រពីរដ្ឋបាលខេត្ត មន្ទីរជំនាញខេត្ត និងពេលខ្លះស្នើសុំការគាំទ្រឯកសារ សម្ភារៈ ពីនាយកដ្ឋានមុខងារ និងធនធានរបស់ក្រសួងមហាផ្ទៃ។

ជាលទ្ធផលនៃការអនុវត្តមុខងារនេះ គឺបានធ្វើឱ្យប្រជាពលរដ្ឋបានយល់ដឹងអំពីដំណើរការនិង តួនាទីរបស់ការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ ដែលជាការឆ្លើយតប ចំពោះតម្រូវការចាំបាច់ក្នុងការផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋ ក្នុងការទទួលបាននូវសេវាឆាប់ រហ័ស ចំណាយតិច រាក់ទាក់ តម្លាភាព។ បន្ទាប់ពីរដ្ឋបាលស្រុកបានរៀបចំយុទ្ធនាការផ្សព្វផ្សាយ ឱ្យ ប្រជាពលរដ្ឋយល់ដឹងអំពីដំណើរការការិយាល័ច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ តាមការសង្កេតឃើញ គឺមានប្រជាពលរដ្ឋកាន់តែច្រើនបានមកស្នើសុំទទួលសេវានៅការិយាល័យច្រក ចេញចូលតែមួយ ហើយពួកគាត់បានផ្តល់យោបល់វិជ្ជមានតាមរយៈការិយាល័យប្រជាពលរដ្ឋ។

## ៣. បទពិសោធន៍ និងបញ្ហាប្រឈម

ជារួមរដ្ឋបាលស្រុកបានទទួលបទពិសោធន៍ល្អៗជាច្រើនរួមមាន ការរៀបចំយុទ្ធនាការផ្សព្វផ្សាយ ដោយបើកចំហ និងមានលក្ខណៈទូលំទូលាយតាមរយៈការប្រគុំតន្ត្រី ការរៀបចំវេទិកាដោយមាន សំណួរ ចម្លើយ គឺទទួលបានលទ្ធផលល្អដោយមានការចូលរួមពីប្រជាពលរដ្ឋជាច្រើន។ ក្រុមប្រឹក្សា និងអ្នកពាក់ព័ន្ធនានា បានលើកឡើងថា ពួកគាត់នឹងខិតខំលើកទឹកចិត្តប្រជាពលរដ្ឋចូលរួមជាមួយ ការិយាល័យប្រជាពលរដ្ឋដាក់បណ្តឹងតវ៉ាប្រសិនមានបញ្ហាមិនប្រក្រតីកើតឡើង ដែលជាយន្តការថ្មីក្នុង ការលើកកម្ពស់ប្រសិទ្ធភាព និងគណនេយ្យភាពរបស់រដ្ឋបាលស្រុកក្នុងការផ្តល់សេវា។ ដោយមានបទ ពិសោធន៍ល្អ និងពិនិត្យឃើញថាសកម្មភាពនេះមានប្រសិទ្ធភាពក្នុងការបង្កើនការយល់ដឹងរបស់ប្រជា ពលរដ្ឋ រដ្ឋបាលស្រុកមានបញ្ចូលថវិកា៥០០ដុល្លាប្រចាំឆ្នាំសម្រាប់រៀបចំយុទ្ធនាការលើកកម្ពស់ការ យល់ដឹងអំពីដំណើរការផ្តល់សេវាតាមការិយាល័យទាំង២នេះ។ ការផ្តល់ថវិកាពីខាងក្រៅដោយ EU-DAR/GIZ និងការបង្កើតក្រុមការងារបានផ្តល់លទ្ធផលល្អ បានរួមចំណែកក្នុងការសម្រេចជោគជ័យនៃ ការអនុវត្ត។

**ទន្ទឹមនឹងនេះ រដ្ឋបាលស្រុកនៅតែជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចជា** រដ្ឋបាលពុំមាន បុគ្គលិកគ្រប់គ្រាន់ក្នុងការធ្វើយុទ្ធនាការជាប្រចាំ ហេតុនេះចាំបាច់ត្រូវប្រើប្រាស់មន្ត្រីមកពីការិយាល័យ ជំនាញពាក់ព័ន្ធនានា។ រដ្ឋបាលស្រុកខ្វះថវិកាសម្រាប់ផ្តល់ប្រាក់ឧបត្ថម្ភដល់បុគ្គលិកអនុវត្តគម្រោង។

### ៤. សក្តានុពលក្នុងការពង្រីកការអនុវត្តទៅទីកន្លែងផ្សេងទៀត

ការអនុវត្តនៃមុខងារនេះ អាចអនុវត្តនៅកន្លែងផ្សេងទៀតបានលុះត្រាតែមានការអនុញ្ញាតឱ្យបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ។ ប្រសិនបើរដ្ឋបាលស្រុក ពុំមានដៃគូគាំទ្រថវិកាក្នុងការអនុវត្តមុខងារនេះ រដ្ឋបាលត្រូវមានថវិការបស់ខ្លួនសមស្រប សម្រាប់ចំណាយលើការរៀបចំកម្មវិធីផ្សព្វផ្សាយ វេទិកា យុទ្ធនាការផ្សេងៗនៅតាមឃុំ តាមសាលារៀន តាមផ្សារ និងកន្លែងសាធារណៈផ្សេងៗ ព្រមទាំងថវិកាសម្រាប់ឧបត្ថម្ភដល់មន្ត្រីមកពីការិយាល័យជំនាញពាក់ព័ន្ធនានាដែល ត្រូវចូលរួមធ្វើការផ្សព្វផ្សាយអំពីបច្ចេកទេសនៃសេវាជំនាញជាក់លាក់របស់ខ្លួន។

<u>**ព័ត៌មានទំនាក់ទំនង**</u>

- **នាយករដ្ឋបាលសាលា៖ លោក ចឿន សុវណ្ណ**
- **លេខទូរស័ព្ទ៖០៩២ ៤៦៨ ៩៦៨**

# ១១. ការអភិវឌ្ឍន៍មត្តេយ្យសិក្សាសហគមន៍ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង

## ១. សង្ខេបអំពីស្ថានភាពបញ្ហា

ដោយសារស្រុកភ្នំព្រឹក ជាស្រុកដែលធ្លាប់ជាតំបន់ប្រយុទ្ធគ្នា បច្ចុប្បន្នតំបន់នេះមានប្រជាពលរដ្ឋចំណាកស្រុកជាច្រើនពីបណ្តាខេត្តភាគកណ្តាលមករស់នៅជាអចិន្ត្រៃយ៍ ឬប្រកបរបរការងារចំការតាមរដូវកាល ដោយមានទាំងកូនតូចៗមកជាមួយផង ដែលធ្វើឱ្យកុមារតូចៗទាំងនោះ ពុំមានឱកាសចូលរៀនសូត្រព្រោះគ្រួសារទាំងនោះបានយកកូនតូចៗទៅធ្វើការជាមួយនៅជិតព្រំដែនថៃ។ ម្យ៉ាងវិញទៀតនៅបណ្តាភូមិដាច់ស្រយាលទាំងនោះ មិនមានសាលារៀននៅក្នុងភូមិនៅឡើយ ដោយសារជាភូមិកើតថ្មី ឬភូមិដែលមានប្រជាពលរដ្ឋតិចតួច។ ដោយមានសំណូមពរជាច្រើនពីប្រជាពលរដ្ឋ តាមរយៈក្រុមប្រឹក្សាឃុំនិងគណៈកម្មាធិការទទួលបន្ទុកស្ត្រី និងកុមារឃុំ(គ.ក.ន.ក) ហើយបានបញ្ជូនសំណូមពរមកគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារស្រុក (គ.ក.ស.ក) ទើប គ.ក.ស.ក បានលើកឡើងក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្រុក ដើម្បីឱ្យរដ្ឋបាលស្រុកជួយសម្របសម្រួល កៀរគរការគាំទ្រដល់ការបង្កើតមត្តេយ្យសិក្សាសហគមន៍។ ដោយសារមានសំណូមពរ និងតម្រូវការជាក់ស្តែងជាច្រើន ក្រុមប្រឹក្សាស្រុកបានសម្រេចនៅក្នុងកិច្ចប្រជុំរបស់ខ្លួន ដោយកំណត់យកការបង្កើតចំនួនថ្នាក់មត្តេយ្យសិក្សាសហគមន៍ជាអាទិភាពមួយ ក្នុងគោលបំណងជួយគាំទ្រដល់រដ្ឋបាលឃុំ បង្កើនការផ្តល់ឱកាសដល់កុមារតូចៗបានចូលរៀនកាន់តែច្រើន ព្រមទាំងជួយសម្រាលបន្ទុកគ្រួសារទាំងនោះ។ រដ្ឋបាលស្រុក បានសម្របសម្រួលការអនុវត្តសកម្មភាពនេះ ចាប់ផ្តើមពីខែកក្កដា ដល់ខែកញ្ញា ឆ្នាំ២០១៧ ដែលបានបង្កើតមត្តេយ្យសិក្សាសហគមន៍ចំនួន៣៣ថ្នាក់នៅក្នុង៥ឃុំ។

## ២. ដំណើរការអនុវត្ត និងលទ្ធផល

ក្រុមប្រឹក្សា បានណែនាំប្រធានគ.ក.ស.ក និងអភិបាលរងជាស្ត្រី ធ្វើការសម្របសម្រួល និងពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានាមានដូចជា៖ សមាជិកគ.ក.ស.ក ការិយាល័យអប់រំស្រុក តំណាងគណៈកម្មាធិការទទួលបន្ទុកស្ត្រី និងកុមារឃុំពាក់ព័ន្ធ ដើម្បីសិក្សាអំពីលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធការបង្កើតថ្នាក់មត្តេយ្យសិក្សាសហគមន៍ អំពីលទ្ធភាពក្នុងការបង្កើតថ្នាក់មត្តេយ្យសិក្សាសហគមន៍ ព្រមទាំងធ្វើការសម្របសម្រួលជាមួយរដ្ឋបាលឃុំពាក់ព័ន្ធដើម្បីស្វែងរកទីតាំងសម្រាប់រៀបចំបង្កើតថ្នាក់មត្តេយ្យសិក្សាសហគមន៍។ ប្រធានគ.ក.ស.ក និងអភិបាលរងជាស្ត្រី ក៏បានពិគ្រោះយោបល់ផងដែរជាមួយប្រជាពលរដ្ឋ និងរដ្ឋបាលឃុំដើម្បីប្រមូលព័ត៌មាននានាពាក់ព័ន្ធនឹងចំនួនភូមិ ចំនួនគ្រួសារ ចំនួនកុមារ បញ្ហាប្រឈម លទ្ធភាពចូលរួមបដិភាគ ធនធាន សម្ភារៈផ្សេងៗរបស់សហគមន៍សម្រាប់ដំណើរការមត្តេយ្យសិក្សាសហគមន៍។ ទន្ទឹមនឹងនេះ ក្រុមប្រឹក្សាស្រុកបានផ្តល់យោបល់ឱ្យអភិបាលស្រុកពិភាក្សាជាមួយរដ្ឋបាលឃុំ ក្នុងការពិនិត្យមើលលទ្ធភាពបង្កើនប្រាក់ឧបត្ថម្ភដល់គ្រូមត្តេយ្យសិក្សាសហគមន៍ពីចំនួន២០០.០០០រៀលដល់ចំនួន ៣០០.០០០រៀល។ ជាមួយគ្នាផងដែរ

អភិបាលស្រុកបានធ្វើការសម្របសម្រួលជាមួយអង្គការសង្គមស៊ីវិលពាក់ព័ន្ធ ដើម្បីស្នើសុំការគាំទ្រ និងឧបត្ថម្ភដល់ដំណើរការមត្តេយ្យសិក្សាសហគមន៍។

ជាលទ្ធផលនៃការសម្របសម្រួលរបស់រដ្ឋបាលស្រុក ថ្នាក់មត្តេយ្យសិក្សាសហគមន៍ដែលមានសរុប៣៣ថ្នាក់ ត្រូវបានរៀបចំឡើងនៅក្នុងឃុំចំនួន៥ ដោយក្រុមប្រឹក្សាឃុំនីមួយៗបានផ្តល់ប្រាក់ឧបត្ថម្ភគ្រូមត្តេយ្យសិក្សា ចំណែកការិយាល័យអប់រំស្រុកបានផ្តល់បច្ចេកទេសបង្រៀនដល់គ្រូស្ម័គ្រចិត្ត ហើយរដ្ឋបាលស្រុកបានផ្តល់សម្ភារៈ និងឧបករណ៍សម្រាប់បង្រៀនដល់ថ្នាក់មត្តេយ្យទាំងនោះ។ ជារួមប្រជាពលរដ្ឋមានការពេញចិត្តនឹងការបង្កើតថ្នាក់មត្តេយ្យសិក្សាសហគមន៍ ព្រោះបានជួយសម្រាលបន្ទុកការងារពួកគាត់ក្នុងការនាំកូនទៅកន្លែងការងារនៅតាមចំការ ឬទៅប្រកបរបរផ្សេងនៅតាមព្រំដែនដែលពួកគាត់មានពេលច្រើនក្នុងការរកប្រាក់ចំណូល និងមានអារម្មណ៍សុវត្ថិភាពជាងមុនចំពោះកូនតូចៗពួកគាត់នៅសាលា។

## ៣. បទពិសោធន៍ និងបញ្ហាប្រឈម

ឆ្លងតាមការអនុវត្តកិច្ចការនេះ រដ្ឋបាលស្រុកទទួលបានបទពិសោធន៍ជាច្រើនរួមមាន៖(១) ភាពជោគជ័យនៃការអនុវត្តដោយ មានការសហការបានល្អរវាងរដ្ឋបាលស្រុក និងរដ្ឋបាលឃុំក្នុងការរៀបចំថ្នាក់មត្តេយ្យសិក្សាសហគមន៍ (២) ប្រជាពលរដ្ឋក្នុងមូលដ្ឋានបានចូលរួមក្នុងការផ្តល់សម្ភារៈសិក្សាមួយចំនួន និងទីតាំងសម្រាប់រៀបចំថ្នាក់មត្តេយ្យសិក្សាសហគមន៍។ (៣) ការឆ្លើយតបតាមតម្រូវការរបស់ប្រជាពលរដ្ឋ និងដំណើរការប្រកបដោយតម្លាភាព តែងទទួលបានការចូលរួមបដិភាគជាថវិកា និងសម្ភារៈពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា។ ទន្ទឹមនឹងនេះដែរការអនុវត្តការងារនេះក៏ជួបនូវបញ្ហាប្រឈមមួយចំនួនដូចជា មានការផ្លាស់ប្តូរគ្រូស្ម័គ្រចិត្តញឹកញាប់ ដោយសារប្រាក់ខែទាប ព្រមទាំងពិបាកស្វែងរកគ្រូស្ម័គ្រចិត្តដែលមានបទពិសោធន៍។ ម្យ៉ាងទៀត ឪពុកម្តាយមួយចំនួនដែលទៅធ្វើការឆ្ងាយៗរយៈពេលយូរនៅតែយកកូនតូចៗដែលត្រូវចូលរៀនទៅជាមួយ។

## ៤. សក្តានុពលក្នុងការពង្រីកការអនុវត្តទៅទីកន្លែងផ្សេងទៀត

ការអនុវត្តមុខងារដូចខាងលើនេះ មានសក្តានុពលដែលមានលទ្ធភាព ទទួលបានជោគជ័យពិសេសនៅតំបន់ដែលពុំសូវមានមត្តេយ្យសិក្សារដ្ឋ ឬសាលានៅឆ្ងាយពីសហគមន៍។ រដ្ឋបាលស្រុកអាចផ្តល់ការសម្របសម្រួល ការប្រឹក្សានិងការគាំទ្រដល់រដ្ឋបាលឃុំក្នុងការអនុវត្តមុខងារខាងលើ ហើយក្នុងករណីចាំបាច់រដ្ឋបាលស្រុក គួរគ្រោងកញ្ចប់ថវិការបស់ខ្លួនផ្ទាល់សម្រាប់ចំណាយលើការងារសម្របសម្រួល និងផ្តល់ការគាំទ្របច្ចេកទេសផ្សេងៗដល់រដ្ឋបាលឃុំ។

<u>**ព័ត៌មានទំនាក់ទំនង**</u>

- **នាយករដ្ឋបាលសាលាស្រុក៖ លោក រ៉ាត វិសាល**
- **លេខទូរស័ព្ទ៖ ០៩៧ ៥៥៥៤៥៥៤**

# ១២. ការលើកកម្ពស់អនាម័យ និងសុវត្ថិភាពចំណីអាហារនៅសាលារៀន
# ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង

## ១. សង្ខេបអំពីស្ថានភាពបញ្ហា

មានកុមារជាច្រើនដែលតែងតែមានជំងឺរាគរូស រិលមុខ និងក្អួតចង្អោរ ពេលត្រឡប់ពីសាលាទៅដល់ផ្ទះវិញ ឪពុកម្តាយសិស្សានុសិស្ស និងក្រុមប្រឹក្សាឃុំជាច្រើនបានលើកឡើងតាមរយៈវេទិកាសាធារណៈនានា តាមរយៈកិច្ចប្រជុំគ.ក.ន.ក និងកិច្ចប្រជុំគណៈគ្រប់គ្រងសាលា។ ដោយមានសំណូមពរជាច្រើនមកក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សានិងរដ្ឋបាលស្រុក បានលើកយកបញ្ហានេះមកពិភាក្សាក្នុងកិច្ចប្រជុំ និងបានសន្និដ្ឋានថាបញ្ហាខាងលើដែលកើតឡើងចំពោះសិស្សានុសិស្ស គឺអាចបណ្តាលពីការពុលអាហារ និងកង្វះអនាម័យនៅតាមសាលាដោយសារអាហារមានរុយរោម មិនមានការគ្របអាហារត្រឹមត្រូវ ការលក់ភេសជ្ជៈដែលប៉ះពាល់ដល់សុខភាព ខ្វះអនាម័យ ជាដើម។ ហេតុនេះក្រុមប្រឹក្សាក៏បានអនុម័តយកបញ្ហាអនាម័យ និងសុវត្ថិភាពចំណីអាហារនៅសាលារៀនជាអាទិភាពដែលត្រូវដោះស្រាយបន្ទាន់ព្រោះពាក់ព័ន្ធផ្ទាល់ចំពោះសុខភាពសិស្សានុសិស្ស ហើយដែលអាចប៉ះពាល់ដល់ការសិក្សារបស់សិស្ស និងប៉ះពាល់ជីវភាពសេដ្ឋកិច្ចគ្រួសារ។ ការអនុវត្តមុខងារនៃការលើកកម្ពស់អនាម័យ និងសុវត្ថិភាពចំណីអាហារនៅតាមសាលារៀននេះ បានចាប់ផ្តើមពីខែមករា ឆ្នាំ២០១៨ ។

## ២. ដំណើរការអនុវត្ត និងលទ្ធផល

បន្ទាប់ពីក្រុមប្រឹក្សាបានអនុម័តលើសំណើគម្រោងលើកកម្ពស់អនាម័យ និងសុវត្ថិភាពចំណីអាហារនៅតាមសាលារៀន ក្រុមប្រឹក្សាបានណែនាំអភិបាលរៀបចំបង្កើតក្រុមការងារជាជំនួយការឱ្យក្រុមប្រឹក្សា និងគណៈអភិបាលក្នុងការសិក្សា និងរៀបចំសំណើគម្រោង។ អភិបាលបានចាត់តាំងអភិបាលរងមួយរូប ជាប្រធានក្រុមការងារដែលមានសមាជិកក្រុមប្រឹក្សា០១រូប នាយករងរដ្ឋបាល០១រូប ការិយាល័យចំណុះសាលាស្រុក ការិយាល័យអប់រំ និងមណ្ឌលសុខភាព។ ក្រុមការងារ បានរៀបចំផែនការសកម្មភាពនានា ដើម្បីជ្រើសរើសសាលាដែលមានការប្រឈមខ្ពស់នឹងបញ្ហានេះ ប្រមូលព័ត៌មាន ចុះសិក្សាស្វែងយល់ពីបញ្ហាឱ្យច្បាស់បន្ថែមទៀតនៅតាមសាលារៀនគោលដៅដែលមានការប្រឈមខ្ពស់នឹងបញ្ហានេះ និងពិគ្រោះយោបល់ជាមួយពាក់ព័ន្ធនានារួមមាន៖ អ្នកលក់ដូរនៅតាមសាលារៀន នាយកសាលា ជនបង្គោលទទួលបន្ទុកស្ត្រី និងកុមារឃុំ គ្រូបង្រៀន សិស្ស និងឪពុកម្តាយសិស្ស។ បន្ទាប់ពីទទួលបានព័ត៌មាន និងមតិយោបល់ពីអ្នកពាក់ព័ន្ធនឹងបញ្ហាកើតឡើងនៅតាមសាលារៀន សំណើសំណូមពរ និងវិធានការនានាក្នុងការលើកកម្ពស់អនាម័យ និងសុវត្ថិភាពចំណីអាហារ ក្រុមការងារ បានរៀបចំសេចក្តីព្រាងសំណើគម្រោងសកម្មភាព ថវិកា និងបច្ចេកទេស ក្នុងការលើកកម្ពស់អនាម័យ និងសុវត្ថិភាពចំណីអាហារនៅតាមសាលារៀន សម្រាប់ដាក់ជូនគណៈអភិបាលពិនិត្យផ្តល់យោបល់ មុនពេលដាក់ឆ្លងកិច្ចប្រជុំក្រុមប្រឹក្សាដើម្បីពិនិត្យ និងអនុម័តមុនស្នើទៅគម្រោង EU-DAR ដើម្បីទទួលបានការគាំទ្រ។ ទន្ទឹមនឹងនេះ គម្រោង EU-DAR បានផ្តល់ការគាំទ្រការធ្វើទស្សន

កិច្ចសិក្សានៅសាលារៀនចំនួន២ ក្នុងខេត្តសៀមរាប ដែលមានបទពិសោធន៍ស្រដៀងគ្នាក្នុងការអនុវត្ត សកម្មភាពអនាម័យ និងសុវត្ថិភាពចំណីអាហារនៅតាមសាលារៀន។ ជាលទ្ធផលនៃការអនុវត្ត សកម្មភាពនេះ ក្រុមការងាររបស់រដ្ឋបាលស្រុកបានយល់ដឹងពីការអនុវត្តជាក់ស្តែងនៃការលើកកម្ពស់ អនាម័យ និងសុវត្ថិភាពចំណីអាហារនៅតាមសាលារៀនតាមរយៈទស្សនកិច្ចសិក្សា។ ក្រុមការងារបាន ធ្វើសហការជាមួយសាលារៀនគោលដៅពាក់ព័ន្ធ ដោយបានណែនាំ អប់រំដល់អ្នកលក់ដូរក្នុងសាលា រៀន អំពីរបៀបរបបទុកដាក់ វេចខ្ចប់ ដឹកជញ្ជូន និងរក្សាអនាម័យចំណីអាហារ។ គណៈគ្រប់គ្រង សាលារៀន បានរៀបចំអ្នកលក់ដូរមានកន្លែងសមរម្យ និងមានរបៀបរៀបរយ ការទុកដាក់សំរាម សំណល់ផ្សេងៗនៅក្នុងក្នុងបរិវេណសាលារៀនឱ្យបានត្រឹមត្រូវ និងបានណែនាំអ្នកលក់ដូរជាប្រចាំពី ការយកចិត្តទុកដាក់រក្សាអនាម័យចំណីអាហារ។ យោងតាមការសម្ភាសន៍ ជាពិសេសជាមួយឪពុក ម្តាយសិស្ស ពួកគាត់ពេញចិត្តខ្លាំងនឹងគម្រោងនេះ ទោះបីជាមិនទាន់បានអនុវត្តក៏ដោយ។

## ៣. បទពិសោធន៍ និងបញ្ហាប្រឈម

តាមរយៈការអនុវត្តមុខងារនេះ រដ្ឋបាលស្រុកទទួលបានបទពិសោធន៍នានារួមមាន៖ (១)ការ ចូលរួមយ៉ាងសកម្មពីអ្នកពាក់ព័ន្ធនឹងបញ្ហាដើម្បីដោះស្រាយបញ្ហា ជាកត្តានាំឱ្យមានភាពជោគជ័យ ដែលបានឆ្លើយតបនឹងតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋ។ (២)ការយល់ដឹងរបស់ក្រុមប្រឹក្សាអំពី ដំណើរការរៀបចំសំណើគម្រោង បានល្អប្រសើរពីព្រោះដំណើរការមានភាពលម្អិត និងការអនុវត្តតាម បែបផែននៃការចូលរួមពីអ្នកពាក់ព័ន្ធហើយតែងស្នើសុំការពិនិត្យនិងផ្តល់យោបល់ពីក្រុមប្រឹក្សា ហើយ ក៏ជានីតិវិធីដែលតម្រូវដោយគម្រោង EU-DAR/GIZ ផងដែរ។ ជាមួយគ្នានេះ ក្រុមប្រឹក្សាបានលើក ឡើងថា ប្រសិនបើការអនុវត្តគម្រោងផ្សេងទៀតអាចធ្វើបានបែបនេះ នោះក្រុមប្រឹក្សាស្រុកកាន់តែមាន ការយល់ដឹងអំពីបញ្ហារបស់ប្រជាពលរដ្ឋ និងរបៀបដោះស្រាយបញ្ហាទាំងនោះ។ (៣) ដោយមើល ឃើញអំពីលទ្ធផលល្អនៃការអនុវត្តមុខងារបែបនេះ ក្រុមប្រឹក្សាបានលើកឡើងថា សំណើគម្រោងនេះ នឹងត្រូវបញ្ចូលទៅក្នុងកម្មវិធីវិនិយោគសម្រាប់ឆ្នាំក្រោយ(២០១៩) ដើម្បីបន្តអនុវត្តគម្រោងនេះនៅ សាលាផ្សេងទៀត។

## ៤. សក្តានុពលក្នុងការពង្រីកការអនុវត្តទៅទីកន្លែងផ្សេងទៀត

អាចអនុវត្តនៅគ្រប់រដ្ឋបាលក្រុង ស្រុក ព្រោះបញ្ហានេះបានកំពុងកើតមានស្ទើរគ្រប់ទីកន្លែង។ រដ្ឋបាលក្រុង ស្រុក ចង់អនុវត្តគម្រោងប្រហាក់ប្រហែលនេះ គួរមានថវិការបស់ខ្លួន ហើយគួរមាន ទស្សនកិច្ចសិក្សាទៅស្រុកនានាដែលបានដោះស្រាយបញ្ហាស្រដៀងគ្នាបានជោគជ័យ។

<u>ព័ត៌មានទំនាក់ទំនង</u>

- **នាយករដ្ឋបាលសាលា៖ លោក សៀង ប៊ុនធឿន**
- **លេខទូរស័ព្ទ៖០១២ ៣៦ ០៦ ៩៩**

# ១៣. ការសម្របសម្រួលការគាំទ្រដល់ជនចាស់ជរានៅតាមសហគមន៍ ស្រុករុក្ខគិរី ខេត្តបាត់ដំបង

## ១. សង្ខេបអំពីស្ថានភាពបញ្ហា

ស្រុករុក្ខគិរី ជាស្រុកដាច់ស្រយាលមួយ ដែលទើបត្រូវបានបង្កើតក្រោយគេក្នុងចំណោមក្រុងស្រុកទាំង១៤នៃខេត្តបាត់ដំបង ហេតុនេះស្ថានភាពនៅមានការខ្វះខាតហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ខ្វះមធ្យោបាយផលិតកម្មកសិកម្ម សកម្មភាពសេដ្ឋកិច្ចមានតិចតួច ដូចជាផ្សារលក់ដូរ ការបង្កើតការងារ និងការលក់ដូរផ្សេងៗ។ ប្រជាពលរដ្ឋភាគច្រើនប្រកបរបរកសិកម្ម ហើយត្រូវប្រឈមនឹងហានិភ័យជាច្រើន ដូច្នេះប្រជាពលរដ្ឋមួយចំនួនបានធ្វើចំណាកស្រុកទៅធ្វើការនៅប្រទេសថៃ ដោយបន្សល់តែមនុស្សចាស់ និងក្មេងៗនៅតាមភូមិ។ អាស្រ័យហេតុនេះ មានប្រជាជនចាស់ជរាជាច្រើនខ្វះការគាំទ្រក្នុងជីវភាពរស់នៅប្រចាំថ្ងៃពីគ្រួសារ។ កុមារមួយចំនួនត្រូវបោះបង់សាលារៀនដោយសារខ្វះមធ្យោបាយសម្ភារៈ និងការហូបចុកប្រចាំថ្ងៃ។ ផ្អែកលើស្ថានភាពនេះ ប្រជាពលរដ្ឋ សមាជិកក្រុមប្រឹក្សាឃុំ និងសមាជិកក្រុមប្រឹក្សាស្រុក តែងលើកសំណើមករដ្ឋបាលស្រុកឱ្យជួយសម្របសម្រួល គៀរគរការគាំទ្រផ្សេងៗដល់ចាស់ជរាខ្វះទីពឹង ជនពិការ និងកុមារកំព្រាជួបប្រទះបញ្ហាជីវភាព។ ផ្អែកតាមសំណូមពរ និងស្ថានភាពជាក់ស្ដែង ក្រុមប្រឹក្សាស្រុកបានពិភាក្សា និងឯកភាពជាមួយគណៈអភិបាល សម្រេចជ្រើសរើសយកសកម្មភាព **"ការសម្របសម្រួលការឧបត្ថម្ភគាំទ្រដល់ជនចាស់ជរាគ្មានទីពឹងនៅតាមសហគមន៍"** ជាអាទិភាពព្រោះបញ្ហានេះពាក់ព័ន្ធដល់ការងារសង្គម ពិសេសមានផលប៉ះពាល់ដល់កុមារដែលខ្វះទីពឹងត្រូវបោះបង់ចោលសាលារៀន។ ការផ្ដួចផ្ដើមនេះ ត្រូវបានអនុវត្តតាំងពីឆ្នាំ២០១៦ និងបន្តអនុវត្តរហូតបច្ចុប្បន្ន។

## ២. ដំណើរការអនុវត្ត និងលទ្ធផល

បន្ទាប់ពីក្រុមប្រឹក្សា និងគណៈអភិបាលបានសម្រេចជ្រើសរើសយកសកម្មភាព "ការសម្របសម្រួលការឧបត្ថម្ភគាំទ្រដល់ជនចាស់ជរាគ្មានទីពឹងនៅតាមសហគមន៍" ជាអាទិភាព ក្រុមប្រឹក្សាបានពិគ្រោះយោបល់ និងបានណែនាំគណៈអភិបាលឱ្យសម្របសម្រួលជាមួយគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារស្រុក ដឹកនាំការអនុវត្តការងារនេះ។ គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រីនិងកុមារស្រុក ដែលមានការិយាល័យសង្គមកិច្ច និងការិយាល័យកិច្ចការនារី ការិយាល័យអប់រំ និងការិយាល័យអន្តរវិស័យ បានធ្វើការងារជាមួយអាជ្ញាធរភូមិ ឃុំ សាលារៀនបឋមសិក្សា និងអង្គការសង្គមស៊ីវិលដែលធ្វើការងារផ្នែកសង្គមកិច្ច ដើម្បីប្រមូលព័ត៌មានជាក់លាក់មួយចំនួនក្នុងការកំណត់អំពីចំនួនភូមិ ឃុំ គោលដៅ ចំនួនគ្រួសារក្រីក្រ ចំនួនកុមារដែលត្រូវចូលសាលា ចំនួនសិស្សដែលបោះបង់ការសិក្សា ចំនួនសាលារៀន ព្រមទាំងពិភាក្សាកំណត់សំណើដំណោះស្រាយអំពីការគាំទ្រដល់ជនចាស់ជរា ជួយគ្រួសារដែលមានកូនតូចៗត្រូវចូលសាលារៀន។ ព័ត៌មានចាំបាច់ទាំងអស់ដែលប្រមូលបានត្រូវបានដាក់ជូនគណៈអភិបាលស្រុកពិនិត្យផ្ដល់យោបល់ ហើយអភិបាលបានរាយការណ៍

និងស្នើសុំការឯកភាពពីក្រុមប្រឹក្សាស្រុក ក្នុងការចូលរួមជំរុញដល់ការអនុវត្តសកម្មភាពនៃការលើកកម្ពស់ការឧបត្ថម្ភគាំទ្រដល់ជនចាស់ជរា និងគ្រួសារក្រីក្រនៅតាមសហគមន៍។ បន្ទាប់ពីទទួលបានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ព័ត៌មានចាំបាច់នានាពាក់ព័ន្ធនឹងចំនួនភូមិ ឃុំគោលដៅ ចំនួនគ្រួសារក្រីក្រ ចំនួនកុមារដែលត្រូវចូលសាលា ចំនួនសិស្សដែលបោះបង់ការសិក្សា ចំនួនសាលារៀន ជាមួយនឹងសំណើដំណោះស្រាយផ្សេងៗ គណៈអភិបាល បានធ្វើទំនាក់ទំនង និងសម្របសម្រួលជាមួយរដ្ឋបាលខេត្ត មន្ទីរសង្គមកិច្ច មន្ទីរកិច្ចការនារីខេត្តស្នើសុំការគាំទ្រស្បៀងអាហារ សម្ភារៈធ្វើទីជម្រក សម្លៀកបំពាក់ សម្ភារៈសិក្សារបស់សិស្សជាដើម។

រាល់កិច្ចពិភាក្សា ដើម្បីដោះស្រាយបញ្ហាជនចាស់ជរា តែងត្រូវបានពិភាក្សានៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាដោយមានការចូលរួមពីគណៈអភិបាល ការិយាល័យជំនាញពាក់ព័ន្ធ រដ្ឋបាលឃុំ។ ប៉ុន្តែក្រុមប្រឹក្សាពុំពាក់ព័ន្ធការសម្រេចអំពីបញ្ហាថវិកានោះទេ ព្រោះរាល់ការផ្តល់ការឧបត្ថម្ភគឺអាស្រ័យដោយអង្គភាពខាងក្រៅ សប្បុរសជន និងអង្គការសង្គមស៊ីវិល។ ការឧបត្ថម្ភគាំទ្រជនចាស់ជរាត្រូវការថវិកាច្រើនប៉ុន្តែថវិកាទាំងនេះបានពីសប្បុរសជន ក្រុមការងារថ្នាក់ជាតិ អង្គការសង្គមស៊ីវិល និងទទួលបានពីមន្ទីរសង្គមកិច្ចខេត្ត។ ចំនួនថវិកា គឺអាស្រ័យលើអង្គភាពទាំងនោះជាអ្នកផ្តល់ ហើយរដ្ឋបាលស្រុកពុំពាក់ព័ន្ធការសម្រេចលើថវិកានោះទេ។ គណៈអភិបាល តាមដាន ជំរុញដល់គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រីនិងកុមារស្រុក លើការងារសម្របសម្រួលជាប្រចាំ ទំនាក់ទំនងជាមួយក្រុមការងារថ្នាក់ជាតិ អង្គភាពនៅថ្នាក់ខេត្ត សប្បុរសជន អង្គការសង្គមស៊ីវិល ព្រមទាំងសម្របសម្រួលកិច្ចប្រជុំជាមួយអ្នកពាក់ព័ន្ធ និងរាយការណ៍ជូនក្រុមប្រឹក្សានៅក្នុងកិច្ចប្រជុំប្រចាំខែ។ ក្រុមប្រឹក្សាបន្តការតាមដានការអនុវត្តសកម្មភាពនេះតាមរយៈរបាយការណ៍ និងក្នុងកិច្ចប្រជុំប្រចាំខែរបស់ខ្លួន។

ជាលទ្ធផលនៃការសម្របសម្រួលការងារនេះ រដ្ឋបាលស្រុកបានរួមចំណែកដល់ការកាត់បន្ថយការខ្វះផ្តល់នូវស្បៀងអាហារ សម្ភារៈសង់ទីជម្រកខ្លះៗ សម្លៀកបំពាក់ ដល់ជនចាស់ជរា ជនពិការ និងកុមារគ្មានទីពឹង កុមារដែលបោះបង់សាលារៀន បានចំនួនរាប់រយនាក់ក្នុងមួយឆ្នាំៗ។ ប្រជាពលរដ្ឋ និងក្រុមប្រឹក្សាស្រុក ឃុំ មានការពេញចិត្ត ដែលមានការផ្តល់ការគាំទ្របែបនេះដល់ចាស់ជរា ជនពិការ និងកុមារគ្មានទីពឹង កុមារដែលបោះបង់សាលារៀន ហើយក្រុមប្រឹក្សាយល់ថាសកម្មភាពទាំងនេះ បានចូលរួមលើកកម្ពស់គណនេយ្យរបស់ក្រុមប្រឹក្សាក្នុងការឆ្លើយតបតាមតម្រូវការរបស់ប្រជាពរលដ្ឋ។

## ៣. បទពិសោធន៍ និងបញ្ហាប្រឈម

តាមរយៈការសម្របសម្រួលសកម្មភាពនេះ រដ្ឋបាលស្រុកទទួលបាននូវបទពិសោធន៍មួយចំនួនរួមមាន៖ (១) ការជួយជនងាយរងគ្រោះដូចជាជនចាស់ជរា ជនពិការ និងកុមារគ្មានទីពឹង កុមារដែលបោះបង់សាលារៀន តែងទទួលបានការឧបត្ថម្ភគាំទ្រច្រើន ពីសប្បុរសជន អង្គការសង្គមស៊ីវិល និងឯកជន ប៉ុន្តែការជួយរបស់អ្នកឧបត្ថម្ភទាំងនោះតែងមានចំពោះក្រុមគោលដៅ ឬតាមភូមិឃុំជាក់លាក់របស់ខ្លួន ដែលករណីខ្លះអ្នកទាំងនោះមិនបានផ្តល់តាមក្រុមគោលដៅដែលរដ្ឋបាលបានស្នើសុំ។ (២) ដោយសារកិច្ចការជួយជនងាយរងគ្រោះទាំងនេះមានការគាំទ្រ និងប្រសិទ្ធភាពខ្ពស់ក្នុងការជួយកុមារដែលខ្វះទីពឹងមិនឱ្យបោះបង់ចោលសាលា ក្រុមប្រឹក្សានិងរដ្ឋបាលស្រុក បានផ្តល់អាទិភាពខ្ពស់

ក្នុងការបញ្ចូលថវិកាប្រចាំឆ្នាំរបស់ស្រុកនៅឆ្នាំខាងមុខ សម្រាប់ប្រើប្រាស់សម្រាប់សកម្មភាពនេះ។ រដ្ឋបាលស្រុកគ្រោងប្រើថវិការដ្ឋបាលស្រុកប្រហែល២០លានរៀលក្នុងឆ្នាំបន្ទាប់។ (៣)ស្រុកគ្រាន់តែដើរតួនាទីសម្របសម្រួល និងទំនាក់ទំនង និងផ្តល់ព័ត៌មានអំពីប្រជាពលរដ្ឋដែលត្រូវការជំនួយ ដោយទុកលទ្ធភាពឱ្យអង្គភាព សប្បុរសជនដែលមានបំណងចង់ជួយឧបត្ថម្ភ គាំទ្រអ្វីមួយដល់ជនចាស់ជរាអាចផ្តល់ឱ្យផ្ទាល់ឬ តាមរយៈរដ្ឋបាលស្រុក។

ទន្ទឹមនឹងនេះ រដ្ឋបាលស្រុកបានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនរួមមាន៖ រដ្ឋបាលស្រុកខ្វះថវិកា ខ្វះបុគ្គលិក ពុំមានប្រាក់ឧបត្ថម្ភដល់បុគ្គលិកចុះបំពេញការងារ។ តម្រូវការសម្រាប់គាំទ្រជនចាស់ជរា និងកុមារគ្មានទីពឹងមានចំនួនច្រើនពេកនៅតាមឃុំជាច្រើនដែលរដ្ឋបាលស្រុកនៅតែពុំមានលទ្ធភាពផ្តល់ការគាំទ្រតាមសំណើ។ ទោះបីស្រុកគ្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួនក៏ដោយ ប៉ុន្តែ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តតែងបដិសេធនូវគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលស្រុកក្នុងការងារសង្គមបែបនេះ។

## ៤. សក្តានុពលក្នុងការពង្រីកការអនុវត្តទៅទីកន្លែងផ្សេងទៀត

ការអនុវត្តមុខងារមានលក្ខណៈជាសេវាសង្គម ជួយជនចាស់ជរា និងកុមារគ្មានទីពឹង មានលទ្ធភាពអាចពង្រីកយកទៅអនុវត្តនៅតាមបណ្តារដ្ឋបាលក្រុង ស្រុក ព្រោះមានលក្ខណៈងាយស្រួលដោយរដ្ឋបាលស្រុកដើរតួនាទីជាអ្នកសម្របសម្រួល ទំនាក់ទំនង និងផ្តល់ព័ត៌មានពាក់ព័ន្ធនឹងអ្នកដែលត្រូវទទួលការឧបត្ថម្ភ។ ទោះបីយ៉ាងណា រដ្ឋបាលក្រុង ស្រុក ត្រូវមានថវិការបស់ខ្លួន ហើយអនុវត្តដោយគ្មានការរើសអើង និន្នាការនយោបាយ។

<u>ព័ត៌មានទំនាក់ទំនង</u>

- **នាយករដ្ឋបាលសាលាស្រុក៖ លោក ពេជ ម៉ាខ្សៃ**
- **លេខទូរស័ព្ទ៖ ០១២ ៩៣ ៧១ ៥១**

# ១៤. ការបញ្ឈប់ការបង្ហូរកាកសំណល់ពីរោងចក្រចូលទៅក្នុងទន្លេ ស្រុកស្អាង ខេត្តកណ្ដាល

## ១. សង្ខេបអំពីស្ថានភាពបញ្ហា

ប្រជាពលរដ្ឋរាប់រយគ្រួសារ និងប្រជាកសិករដែលរស់នៅ និងចិញ្ចឹមត្រីនៅតាមបណ្ដោយទន្លេបាសាក់ក្នុងស្រុកស្អាង បានជួបប្រទះបញ្ហាបំពុលទឹក ដែលបណ្ដាលឱ្យត្រីជាច្រើនដែលចិញ្ចឹមក្នុងបែត្រីត្រូវងាប់។ មូលហេតុនេះ គឺដោយសារការបង្ហូរកាកសំណល់ និងទឹកកខ្វក់ដែលមានសារជាតុពុលពីរោងចក្រចូលទៅក្នុងទន្លេ។ ប្រជាពលរដ្ឋ កសិករចិញ្ចឹមត្រី បានជូនដំណឹង និងតវ៉ាមករដ្ឋបាលឃុំ ហើយរដ្ឋបាលឃុំក៏បានជូនដំណឹងតាមរយៈសមាជិកក្រុមប្រឹក្សា និងរដ្ឋបាលស្រុក អំពីការបង្ហូរកាកសំណល់ចូលទៅក្នុងទន្លេដែលបង្កឱ្យត្រីងាប់ជាច្រើន។ ម្យ៉ាងទៀត ប្រជាពលរដ្ឋរស់នៅតាមមានទន្លេមិនអាចប្រើប្រាស់ទឹកនៅក្នុងតំបន់រងផលប៉ះពាល់បាន។ បន្ទាប់ពីទទួលបានបណ្ដឹងតវ៉ាពីប្រជាពលរដ្ឋ គណៈអភិបាលស្រុក បានពិភាក្សា និងឯកភាពពីក្រុមប្រឹក្សា តម្រូវឱ្យការិយាល័យប្រមូលព័ត៌មានបន្ថែម បន្ទាប់មកបានចេញសេចក្ដីណែនាំដល់រោងចក្រនោះ ឱ្យបញ្ឈប់ការបង្ហូរកាកសំណល់ទៅក្នុងទន្លេជាបន្ទាន់ ហើយរង់ចាំវិធានការដោះស្រាយរបស់រដ្ឋបាលស្រុក។ សកម្មភាពនេះបានចាប់ផ្ដើមនៅដើមខែមេសា និងបានបញ្ចប់នៅចុងខែឧសភា២០១៨ (ប៉ុន្តែទោះបីរោងចក្របញ្ឈប់ការបង្ហូរក៏ដោយ រដ្ឋបាលស្រុកនៅតែបន្តតាមដាននៅតំបន់រងផលប៉ះពាល់នោះ)។

## ២. ដំណើរការអនុវត្ត និងលទ្ធផល

បន្ទាប់ពីបានចេញសេចក្ដីណែនាំដល់រោងចក្រនោះ ឱ្យបញ្ឈប់ការបង្ហូរកាកសំណល់ទៅក្នុងទន្លេជាបន្ទាន់ អភិបាលបានជូនដំណឹង និងស្នើសុំការគាំទ្រអន្តរាគមន៍ពីរដ្ឋបាលខេត្ត មន្ទីរបរិស្ថាន កសិកម្ម និងធនធានទឹក ជួយទប់ស្កាត់ និងដោះស្រាយបញ្ហាប៉ះពាល់ពីការបង្ហូរកាកសំណល់នេះ។ ជាមួយគ្នានេះ ក្រុមប្រឹក្សាបានប្រជុំជាមួយគណៈអភិបាល ដោយមានការចូលរួមពីការិយាល័យអន្តរវិស័យ ការិយាល័យកសិកម្ម ការិយាល័យបរិស្ថាន និងការិយាល័យធនធានទឹក ដើម្បីអន្តរាគមន៍ដោះស្រាយនូវបញ្ហាចំពោះមុខ និងរិះរកវិធានការការពារកុំឱ្យកើតមានករណីដូច្នេះលើកក្រោយៗទៀត។ ក្រោយពីក្រុមប្រឹក្សា និងគណៈអភិបាលបានសម្រេចការទប់ស្កាត់ការបង្ហូរកាកសំណល់នេះ អភិបាលស្រុក បានចាត់តាំងអភិបាលរង១រូប ឱ្យធ្វើការងារជាមួយប្រធានការិយាល័យអន្តរវិស័យ និងការិយាល័យបរិស្ថាន ដើម្បីពិនិត្យនូវលិខិតបទដ្ឋានដែលមានដែលដាក់ចេញដោយថ្នាក់ជាតិ ឬសេចក្ដីណែនាំរបស់មន្ទីរបរិស្ថានខេត្ត ពាក់ព័ន្ធនឹងការបង្ការផលប៉ះពាល់បរិស្ថានក្នុងដំណើរការរបស់រោងចក្រសហគ្រាស រោងសិប្បកម្មផ្សេងៗ។ ក្រៅពីនេះ អភិបាលបានណែនាំឱ្យអភិបាលរងនោះ ធ្វើការពិភាក្សាជាមួយការិយាល័យបរិស្ថាន កសិកម្ម និងធនធានទឹក អធិការដ្ឋាននគរបាលស្រុក ដើម្បីធ្វើការងារជាមួយអាជ្ញាធរមូលដ្ឋាន តំណាងរោងចក្រ ប្រជាពលរដ្ឋដែលរស់នៅតំបន់នោះធ្វើការវាយតម្លៃ

អំពីផលប៉ះពាល់ ក្នុងគោលបំណងស្វែងរកដំណោះស្រាយចំពោះមុខ និងរកវិធានការជានាកុំឱ្យកើតមានករណីដូច្នេះជាថ្មីទៀត។ អភិបាលរងស្រុកដែលទទួលការចាត់តាំង បានធ្វើការងារជាមួយការិយាល័យពាក់ព័ន្ធខាងលើ ក្នុងការប្រមូលព័ត៌មានបន្ថែមដូចជាតើបញ្ហានោះកើតមានដូចម្តេច តើបញ្ហាត្រូវដោះស្រាយបន្ទាន់ឬយ៉ាងណា? តើបញ្ហាមានប្រភពពីណា តើឃុំ ភូមិ គ្រួសារប៉ុន្មានដែលរងផលប៉ះពាល់ ដោយត្រូវចុះពិនិត្យផ្ទាល់នៅកន្លែង និងបានពិភាក្សាជាមួយប្រជាពលរដ្ឋដែលប៉ះពាល់។ តាមការសម្របសម្រួលរបស់រដ្ឋបាលស្រុក ការិយាល័យបរិស្ថាន បានទំនាក់ទំនងមន្ទីរបរិស្ថានជួយពិនិត្យគុណភាពទឹកក្រោយពេលរោងចក្របង្ហូរទឹកកខ្វក់ ការិយាល័យកសិកម្ម បានធ្វើការងារជាមួយកសិករចិញ្ចឹមត្រី ដើម្បីធានាថាត្រីដែលងាប់ត្រូវបានហាមឃាត់មិនឱ្យយកទៅលក់ដូរនៅតាមផ្សារ។ ក្រោយពីទទួលបានព័ត៌មានលម្អិតរបស់ក្រុមការងាររបស់រដ្ឋបាលស្រុក អភិបាលស្រុកបានណែនាំនាយករដ្ឋបាលស្រុក ក្នុងការសហការរៀបចំសេចក្តីព្រាងរបាយការណ៍ និងសំណើដំណោះស្រាយសម្រាប់គណៈអភិបាលពិនិត្យផ្តល់យោបល់ មុនដាក់ឆ្លងកិច្ចប្រជុំក្រុមប្រឹក្សា។ ជា**លទ្ធផល** តាមរយៈអន្តរាគមន៍របស់រដ្ឋបាលស្រុកគឺរោងចក្រ បានបញ្ឈប់ការបង្ហូរកាកសំណល់ និងទឹកកខ្វក់ទៅក្នុងទន្លេ និងបានព្រមព្រៀងបញ្ឈប់លែងឱ្យកើតមានបញ្ហានេះបន្តទៀត។ ក្រុមប្រឹក្សាបានលើកឡើងថា ដោយការយកទុកដាក់របស់រដ្ឋបាលស្រុក ការសម្របសម្រួលនិងអន្តរាគមន៍របស់រដ្ឋបាលស្រុក គឺបានឆ្លើយតបនឹងតម្រូវការផលប្រយោជន៍ និងសំណូមពររបស់ប្រជាពលរដ្ឋ ទោះបីការផ្តល់នូវដំណោះស្រាយនេះហាក់យឺតយ៉ាវបន្តិចក៏ដោយ។ ទន្ទឹមនឹងនេះ អភិបាលស្រុកបានចាត់តាំងការិយាល័យអន្តរវិស័យ ការិយាល័យបរិស្ថាន អធិការនគរបាល ដើម្បីជួយរដ្ឋបាលស្រុក ក្នុងការត្រួតពិនិត្យតាមដាន រោងចក្រ និងបានពិគ្រោះយោបល់ជាមួយកសិករ តើរោងចក្រនោះនៅបន្តបង្ហូរកាកសំណល់ចូលទន្លេទៀតដែរឬទេហើយក្រុមប្រឹក្សា បានតាមដានលើលទ្ធផលនៃការអនុវត្តតាមរយៈកិច្ចប្រជុំដែលរាយការណ៍ដោយអភិបាលស្រុក។

## ៣. បទពិសោធន៍ និងបញ្ហាប្រឈម

តាមរយៈការអនុវត្តការងារសម្របសម្រួលដោះស្រាយបញ្ហាខាងលើនេះ រដ្ឋបាលស្រុកបានទទួលបទពិសោធន៍មួយចំនួន ដូចជា៖ (១) ការដោះស្រាយបញ្ហាដែលមានលក្ខណៈសាំញ៉ាំពាក់ព័ន្ធសមត្ថកិច្ចគ្រប់គ្រង (បញ្ហាជាមួយវិស័យឯកជនដែលមានការអនុញ្ញាតពីថ្នាក់ជាតិឬថ្នាក់ខេត្ត) និងតម្រូវការជំនាញបច្ចេកទេសជាក់លាក់ ទាមទារនូវការចូលរួម និងគាំទ្រយ៉ាងសកម្មពីរដ្ឋបាលខេត្ត និងមន្ទីរជំនាញថ្នាក់ខេត្ត។ (២) ផ្អែកតាមស្ថានភាពនៃបញ្ហាការបំពុលទឹក ធ្វើប៉ះពាល់ដល់សុខភាពមនុស្សនិងសត្វ ដំណើរការនៃការដោះស្រាយបញ្ហាបន្ទាន់បែបនេះ តម្រូវឱ្យគណៈអភិបាលធ្វើការជាមួយនាយករដ្ឋបាល ការិយាល័យជំនាញដែលទទួលបន្ទុកវិស័យ ក្នុងការធ្វើអន្តរាគមន៍ដោះស្រាយជាមុន បន្ទាប់មកទើបជូនរាយការណ៍ជូនប្រធានក្រុមប្រឹក្សា ឬរាយការណ៍ជូនក្រុមប្រឹក្សាទាំងមូលពេលកិច្ចប្រជុំប្រចាំខែ។ (៣) តាមការអនុវត្តជាក់ស្តែង ពុំមានស្តង់ដារកំណត់ក្នុងការដោះស្រាយបែបនេះ ព្រោះរដ្ឋបាលស្រុកគ្រាន់តែចាត់វិធានការភ្លាមៗ ក្នុងការបញ្ឈប់ការបង្ហូរកាកសំណល់ពីរោងចក្រ។

ក្នុងការអនុវត្តការងារសម្របសម្រួលរបស់រដ្ឋបាលស្រុក ក្នុងការដោះស្រាយការបង្ហូរកាកសំណល់រោងចក្រចូលទន្លេ រដ្ឋបាលជួបប្រទះនូវបញ្ហា**ប្រឈមមួយចំនួនរួមមាន៖** (១)សមត្ថភាពរបស់សមាជិកក្រុមប្រឹក្សាក្នុងការយល់ដឹងអំពីលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការងារជំនាញនៅមានកម្រិត ដែលធ្វើឱ្យមានការលំបាកក្នុងការផ្តល់យោបល់ណែនាំដល់អភិបាល ឬរដ្ឋបាលស្រុក និងការិយាល័យជំនាញ (២)បុគ្គលិកស្រុកមានចំនួនតិច សមត្ថភាពយល់ដឹងពីគោលនយោបាយតាមវិស័យជំនាញនៅខ្សោយ (៣) ម្ចាស់រោងចក្រមិនគោរពសិទ្ធិអំណាចរបស់រដ្ឋបាលស្រុក ហើយរដ្ឋបាល ក៏មិនមានសិទ្ធិអំណាចពេញលេញក្នុងការដោះស្រាយនៅពេលមានបញ្ហាកើតឡើង ដោយសាររោងចក្រទទួលច្បាប់អនុញ្ញាតពីថ្នាក់ជាតិ។

## ៤. សក្តានុពលក្នុងការពង្រីកការអនុវត្តទៅទីកន្លែងផ្សេងទៀត

បទពិសោធន៍នៃការអនុវត្តមុខងារនេះ អាចយកទៅអនុវត្តនៅគ្រប់ស្ថានភាពភូមិសាស្ត្រ ប៉ុន្តែចាំបាច់រដ្ឋបាលក្រុង ស្រុកនោះ ត្រូវមានការចូលពីជំនាញពាក់ព័ន្ធហើយចាំបាច់ត្រូវមានអន្តរាគមន៍ពីរដ្ឋបាលខេត្ត ដើម្បីណែនាំដល់មន្ទីរជំនាញដែលមានមន្ត្រីបច្ចេកទេស និងឧបករណ៍ជំនាញគ្រប់គ្រាន់។

**<u>ព័ត៌មានទំនាក់ទំនង</u>**

- **នាយករដ្ឋបាល៖ លោក ឃុត ផល្លា**
- **លេខទូរស័ព្ទ៖ ០៧៧ ៣១២ ៣០៩**

# ១៥. ការលើកកម្ពស់អនាម័យ និងសុវត្ថិភាពចំណីអាហារនៅសាលារៀន ស្រុកសំឡូត ខេត្តបាត់ដំបង

## ១. សង្ខេបអំពីស្ថានភាពបញ្ហា

ប្រជាពលរដ្ឋ ឪពុកម្ដាយសិស្សានុសិស្ស ដែលបានចូលរួមនៅក្នុងវេទិកាសាធារណៈរបស់ក្រុមប្រឹក្សាបានលើកឡើងអំពីបញ្ហាកូនឈឺ ដោយសារពុលចំណីអាហារនៅសាលារៀន។ គ.ក.ន.ក ក៏បានលើកក្នុងកិច្ចប្រជុំ គ.ក.ស.ក ហើយបានបន្តរាយការណ៍ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាស្រុក ដោយសាលារៀនបឋមសិក្សាភាគច្រើនប្រឈមនឹងបញ្ហាស្រដៀងគ្នានេះគឺអាហារមានរុយរោម មិនមានគម្របគ្របអាហារត្រឹមត្រូវ គេសជ្ជៈដែលប៉ះពាល់ដល់សុខភាព ខ្វះអនាម័យ ជាដើម។ ដោយមានបណ្ដឹងជាច្រើនមកក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សានិងរដ្ឋបាលស្រុក បានលើកយកបញ្ហានេះមកពិភាក្សាក្នុងកិច្ចប្រជុំ ហើយក៏មានការសន្និដ្ឋានថាបញ្ហាខាងលើ ដែលកើតឡើងចំពោះសិស្សានុសិស្សអាចបណ្ដាលពីការពុលចំណីអាហារ និងកង្វះអនាម័យរបស់អ្នកលក់ដូរនៅតាមសាលារៀនទាំងនោះ។ ហេតុនេះ ក្រុមប្រឹក្សាក៏បានអនុម័តយកបញ្ហានៃការលើកកម្ពស់អនាម័យ និងសុវត្ថិភាពចំណីអាហារនៅសាលារៀនជាអាទិភាពដែលត្រូវដោះស្រាយបន្ទាន់ព្រោះពាក់ព័ន្ធផ្ទាល់ចំពោះសុខភាពសិស្សានុសិស្ស ហើយដែលអាចប៉ះពាល់ដល់ការសិក្សារបស់សិស្សផង និងប៉ះពាល់ជីវភាពសេដ្ឋកិច្ចគ្រួសារប្រសិនស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរ។ ការផ្ដួចផ្ដើមអនុវត្តមុខងារនេះ បានចាប់ផ្ដើមគម្រោង ចុងឆ្នាំ២០១៧ ដល់ ឆ្នាំ២០១៨។

## ២. ដំណើរការអនុវត្ត និងលទ្ធផល

បន្ទាប់ក្រុមប្រឹក្សា បានអនុម័តអនុវត្តការលើកកម្ពស់អនាម័យ និងសុវត្ថិភាពចំណីអាហារនៅសាលារៀនជាបញ្ហាទិភាព ក្រុមប្រឹក្សាបានណែនាំអភិបាល ស្វែងរកលិខិតបទដ្ឋានគតិយុត្តដែលចេញដោយមន្ទីរអប់រំ មន្ទីរសុខាភិបាល មន្ទីរពាណិជ្ជកម្ម ឬអង្គភាពជំនាញពាក់ព័ន្ធនឹងសុវត្ថិភាពចំណីអាហារ ការកំណត់ស្តង់ដារអនាម័យអប្បរមា ឬប្រភេទផលិតផលមួយចំនួនដែលត្រូវហាមឃាត់មិនឱ្យលក់ដូរក្នុងសាលារៀន។ ក្រុមប្រឹក្សាបានណែនាំអភិបាលឱ្យរៀបចំសេចក្ដីព្រាងបង្កើតក្រុមការងារដែលរួមមាន សមាជិកក្រុមប្រឹក្សា អភិបាលរងស្រុក ការិយាល័យអប់រំ មណ្ឌលសុខភាព និងមន្ត្រីសាលាស្រុក ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័តសេចក្ដីសម្រេចបង្កើតក្រុមការងារ ដែលទទួលខុសត្រូវសម្របសម្រួលនិងគាំទ្រការអនុវត្តគម្រោងលើកកម្ពស់អនាម័យ និងសុវត្ថិភាពចំណីអាហារនៅសាលារៀន។ គណៈអភិបាល បានចាត់តាំងអភិបាលរងមួយរូប ជាប្រធានក្រុមការងារដោយទទួលខុសត្រូវក្នុងគម្រោងនេះ ដោយសហការ និងសម្របស្រួលជាមួយក្រុមប្រឹក្សា និងការិយាល័យចំណុះសាលាស្រុក និងការិយាល័យជំនាញ។ ក្រុមការងារបានប្រមូលព័ត៌មានចាំបាច់នានាតាមរយៈកម្រងបញ្ជីសំណួរដោយឡែកៗពីគ្នាទៅតាមប្រភេទនៃអ្នកផ្តល់ចម្លើយ (នាយកសាលាប្រធានមណ្ឌលសុខភាព គណៈកម្មការទ្រទ្រង់សាលា គ.ក.ន.ក គ្រូបង្រៀន ឪពុកម្ដាយ សិស្សស្រី

ប្រុស) និងធ្វើការសម្ភាសន៍នៅសាលាចំនួន៤ ដែលមានបញ្ហាកើតឡើង និងជាមួយអាណាព្យាបាលសិស្សដែលជួយប្រទះបញ្ហា ហើយក្រុមការងារបានជ្រើសរើសយកសាលារៀនចំនួន២ដែលត្រូវអនុវត្ត។ ក្រុមការងារបានរៀបចំសេចក្តីព្រាងសំណើគម្រោងដោយបញ្ចូលនូវសកម្មភាព និងថវិកាសម្រាប់អប់រំផ្សព្វផ្សាយ និងវិធានការនានាក្នុងការលើកកម្ពស់អនាម័យ និងសុវត្ថិភាពចំណីអាហារនៅតាមសាលារៀន និងដាក់ជូនគណៈអភិបាលពិនិត្យផ្តល់យោបល់ មុនដាក់ឆ្លងក្រុមប្រឹក្សាដើម្បីពិនិត្យ និងអនុម័ត។ ដោយសារស្រុកសំឡូតស្ថិតក្នុងតំបន់គោលដៅនៃពីកម្មវិធី EU-DAR អភិបាលស្រុកបានជូនសំណើគម្រោងសកម្មភាព និងថវិកាដែលក្រុមប្រឹក្សាអនុម័តរួច ស្នើសុំការគាំទ្រថវិកាកម្មវិធី EU-DAR ហើយបានទទួលការសម្រេចគាំទ្រ ហើយតាមគោលការណ៍ក្នុងភាពជាដៃគូជាមួយរដ្ឋបាលស្រុក តម្រូវឱ្យរដ្ឋបាលស្រុកត្រូវចូលរួមបដិភាគ១០%នៃថវិកាសរុប។ ក្រៅពីនេះគម្រោង EU-DAR ក៏បានគាំទ្រការធ្វើទស្សនៈកិច្ចសិក្សានៅសាលារៀនចំនួន២ ក្នុងខេត្តសៀមរាប ដែលមានបទពិសោធន៍ស្រដៀងគ្នាក្នុងការរៀបចំគម្រោងសកម្មភាពលើកកម្ពស់អនាម័យ និងសុវត្ថិភាពចំណីអាហារនៅតាមសាលារៀន។ ក្រោយពីទទួលបានការផ្តល់ថវិកាពីកម្មវិធី EU-DAR ក្រុមការងារបានចុះសហការជាមួយសាលារៀនគោលដៅទាំង២ដើម្បីអប់រំអំពីរបៀបរបបទុកដាក់ វេចខ្ចប់ ដឹកជញ្ជូន និងរក្សាអនាម័យចំណីអាហារ។ ជាលទ្ធផលនៃការអនុវត្តគម្រោងនេះ គឺក្រុមការងារបានយល់ដឹងពីការអនុវត្តជាក់ស្តែងនៃការលើកកម្ពស់អនាម័យ និងសុវត្ថិភាពចំណីអាហារនៅតាមសាលារៀនតាមរយៈទស្សនកិច្ចសិក្សា។ គណៈគ្រប់គ្រងសាលារៀន បានរៀបចំអ្នកលក់ដូរឱ្យមានរបៀបរៀបរយ មានកន្លែងសមរម្យ ការទុកដាក់សំរាមសំណល់ផ្សេងៗនៅក្នុងបរិវេណសាលារៀនឱ្យបានត្រឹមត្រូវ និងបានណែនាំអ្នកលក់ដូរជាប្រចាំពីការយកចិត្តទុកដាក់រក្សាអនាម័យចំណីអាហារ។ ក្រុមប្រឹក្សាលើកឡើងថា ប្រជាពលរដ្ឋ នាយកសាលាមានការពេញចិត្តចំពោះគម្រោងនេះ។

## ៣. បទពិសោធន៍ និងបញ្ហាប្រឈម

ការអនុវត្តគម្រោងនេះ ធ្វើឱ្យអ្នកពាក់ព័ន្ធនានានៅថ្នាក់ស្រុកទទួលបានមេរៀនបទពិសោធន៍រួមមាន៖ (១)បានយល់ដឹងអំពីដំណើរការប្រមូលបានបញ្ហា តម្រូវការរបស់ប្រជាពលរដ្ឋ វិធីសាស្ត្រនៃការចាត់អាទិភាពបញ្ហា និងវិធានការដោះស្រាយនានា ព្រមទាំងយល់ដឹងអំពីដំណើរយន្តការនៃការសម្របសម្រួល និងការសហការជាមួយអង្គភាពជំនាញនានា។ (២) ក្រុមប្រឹក្សា និងគណៈអភិបាលមានការយល់ដឹងកាន់តែច្បាស់អំពីតួនាទី និងការទទួលខុសត្រូវ ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក ដែលត្រូវយកចិត្តទុកដាក់ដោះស្រាយបញ្ហានានាដែលជាកង្វល់របស់ប្រជាពលរដ្ឋ។ (៣) សាមគ្គីភាពផ្ទៃក្នុងរវាងក្រុមប្រឹក្សា និងគណៈអភិបាល ព្រមទាំងការចូលរួមគាំទ្រពីពាក់ព័ន្ធ ក្នុងការដោះស្រាយបញ្ហាប្រជាពលរដ្ឋ ជាកម្លាំងជំរុញក្នុងការអនុវត្តគម្រោងបានសម្រេចលទ្ធផល។ ក្នុងការអនុវត្តនេះ រដ្ឋបាលស្រុកបានជួបប្រទះ**បញ្ហាប្រឈមនានាដូចជា៖** ការអនុវត្តសកម្មភាពត្រូវពន្យាពេលច្រើនដង រដ្ឋបាលស្រុកជាប់មមាញឹកសម្របសម្រួលកម្មវិធីបន្ទាន់ៗរបស់ថ្នាក់ជាតិ និងថ្នាក់ខេត្តច្រើន។

### ៤. សក្តានុពលក្នុងការពង្រីកការអនុវត្តទៅទីកន្លែងផ្សេងទៀត

គម្រោងក្នុងដោះស្រាយបញ្ហាប្រហាក់ប្រហែលនេះ អាចអនុវត្តបាននៅគ្រប់រដ្ឋបាលក្រុង ស្រុក ព្រោះបញ្ហានេះបានកំពុងកើតមានស្ទើរគ្រប់ទីន្លែង។ រដ្ឋបាលក្រុង ស្រុក ចង់អនុវត្តគម្រោង គួរមានថវិការបស់ខ្លួន ហើយគួរមានទស្សនកិច្ចសិក្សាទៅស្រុកនានាដែលបានដោះស្រាយបញ្ហាស្រដៀងគ្នាបានជោគជ័យ។

<u>**ព័ត៌មានទំនាក់ទំនង**</u>

- **នាយករដ្ឋបាលសាលាស្រុក៖ លោក ហ៊ុន ធឿន**
- **ទូរស័ព្ទ៖ ០៧៧៨៣៨៦៨២**

# ១៦. រៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវក្នុងទីប្រជុំជនស្រុក

# ស្រុកសំឡូត ខេត្តបាត់ដំបង

## ១. សង្ខេបអំពីស្ថានភាពបញ្ហា

ប្រជាពលរដ្ឋដែលមានលំនៅដ្ឋានតាមដងផ្លូវក្នុងទីប្រជុំជនស្រុក បានបើកធ្វើអាជីវកម្មលក់ដូរទំនិញ និងបានប្រើប្រាស់ចិញ្ចើមផ្លូវទាំងសងខាងសម្រាប់ផលប្រយោជន៍បុគ្គលដោយការដាក់ទំនិញឥវ៉ាន់ផ្សេងៗ ដែលធ្វើឱ្យប៉ះពាល់ដល់អ្នកធ្វើដំណើរ បង្កឱ្យខ្វះសណ្តាប់ធ្នាប់តាមផ្លូវ និងបាត់សោភ័ណភាពក្នុងទីប្រជុំជនស្រុក។ ប្រជាពលរដ្ឋដាក់ពាក្យបណ្តឹងនៅសាលាស្រុកអំពីការប្រើប្រាស់ចិញ្ចើមផ្លូវដោយអាជីវករមួយចំនួន នឹងបានទាមទារឱ្យរដ្ឋបាលស្រុកធ្វើការដោះស្រាយឱ្យមានសណ្តាប់ធ្នាប់ និងសោភ័ណភាពឡើងវិញ។ អភិបាលស្រុកបានលើកបញ្ហានេះ នៅពិភាក្សាក្នុងកិច្ចប្រជុំក្រុមប្រឹក្សា និងបានឯកភាពសម្រេចយកបញ្ហានេះមកដោះស្រាយដោយដាក់វិធានការ ការរំដោះចិញ្ចើមផ្លូវ និងមិនអនុញ្ញាតឱ្យសាងសង់សំយ៉ាប ឬលក់ដូរលើចិញ្ចើមផ្លូវព្រោះបញ្ហានេះបាននាំឱ្យប៉ះពាល់ដល់ប្រយោជន៍សាធារណៈ។ ការអនុវត្តសកម្មភាពនេះ ក្នុងគោលបំណងដើម្បីការរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវ និងលើកកម្ពស់សោភ័ណភាពទីប្រជុំជនស្រុកឡើងវិញ។ សកម្មភាពត្រូវបានចាប់ផ្តើមរៀបចំ និងអនុវត្តចាប់ពីឆ្នាំ២០១៧ ដល់ ឆ្នាំ២០១៨។

## ២. ដំណើរការអនុវត្ត និងលទ្ធផល

ក្រោយពីក្រុមប្រឹក្សាបានសម្រេចឱ្យគណៈអភិបាលធ្វើការដោះស្រាយបញ្ហានៃការលក់ដូរ ការប្រើប្រាស់ចិញ្ចើមផ្លូវសាធារណគ្មានរបៀបរៀបរយ អភិបាលបានប្រជុំគណៈបញ្ជាការឯកភាពស្រុកដើម្បីពិភាក្សា និងបានឯកភាពបង្កើតគណៈកម្មការចម្រុះមួយដើម្បីសម្របសម្រួលការងារដោះស្រាយសណ្តាប់ធ្នាប់។ អភិបាលស្រុក បានចាត់តាំងអភិបាលរងមួយរូប ជាប្រធានគណៈកម្មការចម្រុះ ដែលរួមមាន ការិយាល័យអន្តរវិស័យ ការិយាល័យសូរិយោដី សាធារណៈការ បរិស្ថាន និងកងរាជអាវុធហត្ថ និងប៉ូលីសស្រុក ជាសមាជិក។ ទន្ទឹមនឹងនេះ អភិបាលស្រុកបានចេញប្រកាសស្តីពីការគ្រប់គ្រងសណ្តាប់ធ្នាប់ការប្រើប្រាស់ចិញ្ចើមផ្លូវ។ ដោយផ្អែកលើប្រកាសនេះ គណៈកម្មការបានរៀបចំសេចក្តីជូនដំណឹងស្តីពីការរៀបចំសណ្តាប់ធ្នាប់សាធារណៈតាមដងផ្លូវ ផ្សព្វផ្សាយសេចក្តីជូនដំណឹង ជាពិសេសប្រជាពលរដ្ឋដែលមានលំនៅដ្ឋានហើយដែលមានការប្រើប្រាស់ចិញ្ចើមផ្លូវកន្លងមក ដោយតម្រូវឱ្យរុះរើសំណង់ផ្សេងៗចេញក្នុងរយៈពេល២សប្តាហ៍។ គណៈកម្មការក៏បានចុះណែនាំអប់រំប្រជាពលរដ្ឋរស់នៅតាមដងផ្លូវ និងអ្នកលក់ដូរនៅតាមចិញ្ចើមផ្លូវ ដែលនាំឱ្យខ្វះសណ្តាប់ធ្នាប់ និងអនាម័យនៅតាមដងផ្លូវក្នុងទីប្រជុំជនក្នុងស្រុក ឱ្យទៅលក់ដូរក្នុងផ្សាររបស់ស្រុក។ ជាលទ្ធផល គឺសណ្តាប់ធ្នាប់នៅតាមដងផ្លូវក្នុងទីប្រជុំជនស្រុក បានល្អប្រសើរ លែងមានការសាងសង់សំយ៉ាប ឬតូបលក់ចូលមកលើផ្លូវដើរ ឬលែងមានអ្នកលក់ដូរលើចិញ្ចើមផ្លូវខ្វះសណ្តាប់ធ្នាប់ ហើយលែងមានការបោះចោលសំរាម

និងខ្វះអនាម័យដូចមុន។ គណៈកម្មការចម្រុះ បានរាយការណ៍ក្នុងកិច្ចប្រជុំគណៈបញ្ជាការឯកភាពស្រុក អំពីលទ្ធផលនៃការអនុវត្ត ហើយអភិបាលបានរៀបចំជារបាយការណ៍សម្រាប់ជូនក្រុមប្រឹក្សារៀងរាល់កិច្ចប្រជុំ។

### ៣. បទពិសោធន៍ និងបញ្ហាប្រឈម

អនុវត្តមុខងារបែបនេះ ក្រុមប្រឹក្សា និងអ្នកពាក់ព័ន្ធនានាទទួលបានបទពិសោធន៍រួមមាន៖ (១)ការអនុវត្តទាមទារឱ្យមានការចូលរួមពីសមត្ថកិច្ចជំនាញផ្សេងៗ ពិសេសការិយាល័យភូមិបាលស្រុក ដើម្បីពន្យល់អប់រំ និងផ្សព្វផ្សាយអំពីលិខិតបទដ្ឋាននានារបស់ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ព្រមទាំងត្រូវមានការចូលរួមពីប៉ូលីស និងអាវុធហត្ថស្រុក ព្រោះពាក់ព័ន្ធការអនុវត្តវិធានការចាប់បង្ខំមួយចំនួន (២) ក្នុងការអនុវត្ត រដ្ឋបាលស្រុកចាំបាច់ត្រូវយកចិត្តទុកដាក់ពង្រឹង តាមដានត្រួតពិនិត្យប្រចាំ និងមានវិធានការសមស្របចំពោះអ្នកមិនព្រមអនុវត្តនូវប្រការដែលបានឯកភាពគ្នា។ ទោះបីមានវិធានការក៏ដោយ ប្រជាពលរដ្ឋខ្លះមិនអនុវត្តវិធានការរបស់រដ្ឋបាលស្រុកដោយនៅតែល្មើសការហាមឃាត់ ហើយរដ្ឋបាលស្រុកក៏ពុំចង់អនុវត្តវិធានការដាច់ខាតដោយប្រកាន់យកវិធានការអប់រំជាគោល។ អ្នកលក់ដូរលើចិញ្ចើមផ្លូវ ធ្វើតាមការណែនាំតែនៅពេលមានសមត្ថកិច្ចចុះដល់ទីកន្លែង នៅពេលគ្មានសមត្ថកិច្ចពួកគាត់វិលទៅលក់កន្លែងដដែលវិញ។

### ៤. សក្តានុពលក្នុងការពង្រីកការអនុវត្តទៅទីកន្លែងផ្សេងទៀត

ការអនុវត្តមុខងារនេះ គឺមានលក្ខណៈសមស្របគ្រប់ទីប្រជុំជនទាំងអស់ ហើយដែលចាំបាច់រដ្ឋបាលស្រុកត្រូវមានវិធានការតឹងរ៉ឹងក្នុងការអនុវត្ត ហើយត្រូវមានការត្រួតពិនិត្យជាប្រចាំ ដោយមានកម្លាំងសមត្ថកិច្ចចូលរួម។ ម្យ៉ាងទៀត រដ្ឋបាលស្រុកត្រូវមានទីតាំងសមស្របសម្រាប់បង្កើតជាផ្សារសម្រាប់ប្រជាពលរដ្ឋអាចលក់ដូរបាន ឬទាក់ទាញការវិនិយោគរបស់ឯកជនក្នុងការបង្កើតផ្សារចៀសវាងប្រជាពលរដ្ឋមកលក់ដូរលើចិញ្ចើមផ្លូវ។

<u>ព័ត៌មានទំនាក់ទំនង</u>


- **នាយករដ្ឋបាលសាលាស្រុក៖ លោក ហ៊ុន ឆឿន**
- **ទូរស័ព្ទ៖ ០៧៧៨៣៨៦៨២**

# ១៧. ការបង្កើតមត្តេយ្យសិក្សាសហគមន៍ក្នុងភូមិជនជាតិដើមភាគតិច ស្រុកសំឡូត ខេត្តបាត់ដំបង

## ១. សង្ខេបអំពីស្ថានភាពបញ្ហា

នៅក្នុងស្រុកសំឡូត មានជនជាតិដើមភាគតិចពូង គួយ ចំនួនជាង២០០គ្រួសារ កំពុងរស់នៅ។ កូនចៅប្រជាពលរដ្ឋជាជនជាតិភាគតិចទាំងនោះ ពិសេសកុមារតូចៗ ពុំសូវមានឱកាសបានចូលរៀននៅតាមសាលាដូចប្រជាពលរដ្ឋទូទៅឡើយ។ បញ្ហានៃការមិនបានចូលរៀននេះដោយសារមូលហេតុមួយចំនួនដូចជា វប្បធម៌ប្រពៃណីខុសគ្នា ការយល់ដឹងរបស់ឪពុកម្តាយនៅទាប ខ្វះសាលារៀន ឬសាលារៀននៅឆ្ងាយ។ ចំពោះតម្រូវការក្នុងការបង្កើតថ្នាក់មត្តេយ្យសិក្សាសហគមន៍ ប្រជាពលរដ្ឋជាជនជាតិភាគតិចទាំងនោះ និងក្រុមប្រឹក្សាឃុំ តែងតែលើកឡើងក្នុងវេទិកាសាធារណៈរបស់ក្រុមប្រឹក្សាស្រុក។ ជារៀងរាល់កិច្ចប្រជុំប្រចាំខែរបស់គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារស្រុក(គ.ក.ស.ក) គណៈកម្មាធិការទទួលបន្ទុកនារី និងកុមារឃុំ(គ.ក.ន.ក) តែងរាយការណ៍អំពីតម្រូវការសាលាមត្តេយ្យ ហើយគ.ក.ស.ក ក៏បានរាយការណ៍ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាស្រុក។ ដោយយល់ឃើញថា កូនចៅប្រជាពលរដ្ឋជនជាតិដើមភាគតិចជាច្រើនពុំបានចូលរៀនដោយសារខ្វះសាលាមត្តេយ្យ ហេតុនេះក្រុមប្រឹក្សាក៏បានអនុម័តជ្រើសរើសយកបញ្ហាដែលកុមារតូចៗជាជនជាតិភាគតិចមិនបានចូលរៀន ជាអាទិភាពដែលត្រូវដោះស្រាយ តាមរយៈការបង្កើតសាលាមត្តេយ្យសិក្សាសហគមន៍។ មុខងារនៃការសម្របសម្រួលរៀបចំថ្នាក់មត្តេយ្យសិក្សាសហគមន៍នេះត្រូវបានអនុវត្ត និងចាប់ផ្តើមនៅខែឧសភា ឆ្នាំ ២០១៧ ដល់ ខែមករា ឆ្នាំ ២០១៨ សម្រាប់ប្រជាពលរដ្ឋជនជាតិដើមភាគតិចពូង គួយ ចំនួនប្រហែល ២០០គ្រួសារ។

## ២. ដំណើរការអនុវត្ត និងលទ្ធផល

ផ្អែកតាមសម្រេចរបស់ក្រុមប្រឹក្សាស្រុក ក្នុងការបង្កើតសាលាមត្តេយ្យសិក្សាសហគមន៍សម្រាប់កុមារជនជនជាតិដើមភាគតិច ក្រុមប្រឹក្សាស្រុកបានណែនាំគណៈអភិបាល ដើម្បីគាំទ្រដល់គ.ក.ស.កស្រុក ក្នុងការសម្របសម្រួល និងគាំទ្រដល់រដ្ឋបាលឃុំពាក់ព័ន្ធអាចដំណើរការសាលាមត្តេយ្យសិក្សាសហគមន៍។ បន្ទាប់មកគណៈអភិបាល បានសម្របសម្រួល ជំរុញ និងគាំទ្រដល់គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារស្រុកក្នុងការបំពេញការងារ ការទទួលខុសត្រូវរបស់ខ្លួនតាមការណែនាំរបស់ក្រុមប្រឹក្សា។ គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារស្រុក បានសម្របសម្រួលជាមួយការិយាល័យអប់រំ អង្គការសង្គមស៊ីវិល និងរដ្ឋបាលឃុំពាក់ព័ន្ធ ដើម្បីប្រមូលព័ត៌មានបន្ថែមដូចជាចំនួនភូមិ ឃុំ ស្ថានភាពរស់នៅនិងចំនួនគ្រួសារ ចំនួនកុមារដែលត្រូវចូលរួម និងលទ្ធភាពចូលរួមបដិភាគរបស់គ្រួសារ និងសហគមន៍ ការជ្រើសរើសទីតាំង និងការពិនិត្យស្វែងរកគ្រូស្ម័គ្រចិត្ត ជាដើម។ ក្រៅពីនេះ គណៈអភិបាលបានគាំទ្រគ.ក.ស.កស្រុក ឱ្យសម្របសម្រួលស្នើសុំគាំទ្រជាថវិកា សម្ភារៈសិក្សា

និងកិច្ចការបច្ចេកទេសពី "**អង្គការខេម**" ដែលកំពុងបំពេញការងារនៅក្នុងស្រុក។ បន្ទាប់ពីទទួលបានលទ្ធផលនៃការសិក្សាលើលទ្ធភាពនៃការបង្កើតសាលាមត្តេយ្យសិក្សាសហគមន៍ និងសេចក្តីព្រាងផែនការសកម្មភាព គណៈកម្មាធិការពិគ្រោះយោបល់ស្រ្តី និងកុមារស្រុក រាយការណ៍ជូនគណៈអភិបាល និងក្រុមប្រឹក្សាស្រុកនៅក្នុងកិច្ចប្រជុំដើម្បីពិនិត្យ និងសម្រេច។ ក្នុងដំណើរការបង្កើតសាលាមត្តេយ្យសិក្សាសហគមន៍ គណៈកម្មាធិការសម្របសម្រួលជាមួយឃុំគោលដៅ ការិយាល័យអប់រំស្រុក អង្គការខេម ដើម្បីរៀបចំថ្នាក់មត្តេយ្យ ជ្រើសរើស និងរៀបចំកិច្ចសន្យាគ្រូស្ម័គ្រចិត្ត (កិច្ចសន្យារវាងរដ្ឋបាលឃុំ និងគ្រូស្ម័គ្រចិត្ត ព្រោះរដ្ឋបាលឃុំជាអ្នកផ្តល់ប្រាក់ឧបត្ថម្ភដល់គ្រូស្ម័គ្រចិត្ត)។ បន្ទាប់ពីបានជ្រើសរើសគ្រូស្ម័គ្រចិត្តរួចមក ការិយាល័យអប់រំ និងអង្គការខេម បានបណ្តុះបណ្តាលគ្រូ និងផ្តល់សម្ភារៈសម្រាប់ដំណើរការថ្នាក់មត្តេយ្យសិក្សា។ រដ្ឋបាលស្រុកបានរួមចំណែកចំណាយសម្រាប់កិច្ចប្រជុំនានារបស់គ.ក.ស.ក ហើយប្រជាពលរដ្ឋដែលមានកូនៗ ដោយការផ្តល់នូវព័ត៌មាន ការចូលរួមបដិភាគជាសម្ភារៈ និងឧបត្ថម្ភខ្លះដល់គ្រូស្ម័គ្រចិត្ត និងសម្រាប់ដំណើរការថ្នាក់មត្តេយ្យសិក្សា។ រីឯថវិកាសម្រាប់ប្រតិបត្តិការរបស់ថ្នាក់មត្តេយ្យសិក្សាសហគមន៍បានមកពីថវិកាឃុំ ដែលបានសម្រេចដោយក្រុមប្រឹក្សាឃុំ និងការគាំទ្ររបស់អង្គការខេមគឺឧបត្ថម្ភការសាងសង់ថ្នាក់រៀន ហើយប្រជាពលរដ្ឋចូលរួមផ្តល់ទីតាំងសម្រាប់សាងសង់។ ទោះបីថ្នាក់មត្តេយ្យសិក្សាបានដំណើរការក៏ដោយ គណៈកម្មាធិការ (គ.ក.ស.កស្រុក និងការិយាល័យអប់រំស្រុក បានបន្តត្រួតពិនិត្យតាមដានដំណើរការរបស់ថ្នាក់មត្តេយ្យសិក្សាសហគមន៍ និងរាយការណ៍ប្រចាំខែជូនគណអភិបាលនិងក្រុមប្រឹក្សា។ ជាលទ្ធផលនៃការអនុវត្តមុខងារនេះ រដ្ឋបាលស្រុកបានគាំទ្ររដ្ឋបាលឃុំក្នុងការរៀបចំមត្តេយ្យសិក្សាសហគមន៍នេះបានទទួលជោគជ័យ ហើយឪពុកម្តាយសិស្សមានការពេញចិត្ត ហើយតែងស្នើសុំក្រុមប្រឹក្សាឃុំ និងស្រុកបើកថ្នាក់បន្ថែមទៀត ព្រោះក្រៅពីបានជួយផ្តល់ចំណេះដឹងដល់កុមារតូចៗជាជនជាតិដើមភាគតិច គឺបានជួយសម្រាលបន្ទុករបស់គ្រួសារប្រជាពលរដ្ឋដែលទៅឆ្ងាយៗពីភូមិឃុំ ព្រមទាំងបានផ្តល់ដល់កុមារនៃគ្រួសារដែលមកប្រកបរបរតាមរដូវកាល។

## ៣. បទពិសោធន៍ និងបញ្ហាប្រឈម

តាមរយៈការអនុវត្តមុខងារនេះ រដ្ឋបាលស្រុកបានទទួលនូវមេរៀនបទពិសោធន៍រួមមាន៖ (១) ការលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលស្រុក និងរដ្ឋបាលឃុំ និងការលើកកម្ពស់គណនេយ្យភាពរបស់ក្រុមប្រឹក្សាស្រុកចំពោះក្រុមប្រឹក្សាឃុំ តាមរយៈការគាំទ្រដល់រដ្ឋបាលឃុំ ក្នុងការដោះស្រាយបញ្ហាដែលមានអាទិភាពខ្ពស់ ដូចជាការបង្កើតមត្តេយ្យសិក្សាសហគមន៍ ដែលការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ ប៉ុន្តែក្រុមប្រឹក្សាស្រុក ក៏មានគណនេយ្យភាពចំពោះក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋ ហេតុនេះរដ្ឋបាលស្រុកត្រូវចូលរួមកៀរគរការគាំទ្រលើការបង្កើនចំនួនថ្នាក់មត្តេយ្យសិក្សាសហគមន៍។ (២) ដោយឃើញពីសារៈប្រយោជន៍នៃកិច្ចសហប្រតិបត្តិការ និងការគាំទ្រលក្ខណៈអន្តររដ្ឋបាល រដ្ឋបាលស្រុកបានកំណត់ថា នៅពេលអង្គការខេម បញ្ចប់ការគាំទ្រថវិកា ក្រុមប្រឹក្សា និងគ.ក.ស.កស្រុកនឹងពិភាក្សាជាមួយអភិបាលដើម្បីបញ្ចូលសកម្មភាពនេះទៅក្នុងកម្មវិធីវិនិយោគ និងថវិកាប្រចាំឆ្នាំរបស់

ស្រុកក្នុងឆ្នាំ២០១៩។ (៣) បានផ្តល់នូវការចំណេះដឹងថ្មីៗអំពីកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលស្រុក រដ្ឋបាលឃុំ ការិយាល័យអប់រំ និងអង្គការសង្គមស៊ីវិល លើការកៀរគរធនធាន និងបច្ចេកទេស។ ការអនុវត្តមុខងារនេះ រដ្ឋបាលស្រុកបានជួបបញ្ហាប្រឈមដូចជា៖ (១)ពិបាករកគ្រូស្ម័គ្រចិត្ត ដោយសារប្រាក់ឧបត្ថម្ភមានចំនួនតិចពេកពុំមានអ្នកចង់បង្រៀន ២) រដ្ឋបាលស្រុកខ្វះថវិកា ខ្វះបុគ្គលិកក្នុងការគាំទ្រដល់ឃុំក្នុងការអនុវត្តសកម្មភាព និងការជំរុញនានា (៣) ទីលំនៅរបស់កុមារនៅឆ្ងាយៗពីគ្នាដែលមានការលំបាកប្រមូលផ្តុំបង្កើតថ្នាក់មត្តេយ្យសិក្សាសហគមន៍។

## ៤. សក្តានុពលក្នុងការពង្រីកការអនុវត្តទៅទីកន្លែងផ្សេងទៀត

ការអនុវត្តមុខងារដូចខាងលើនេះ មានសក្តានុពលក្នុងការទទួលបានជោគជ័យ ពិសេសនៅតំបន់ដែលពុំសូវមានសាលាមត្តេយ្យសិក្សារដ្ឋឬសាលានៅឆ្ងាយពីសហគមន៍។ ដើម្បីគាំទ្រដល់រដ្ឋបាលឃុំ រដ្ឋបាលស្រុកចាំបាច់ត្រូវមានកញ្ចប់ថវិការបស់ខ្លួនផ្ទាល់សម្រាប់ចំណាយលើការងារសម្របសម្រួល និងផ្តល់ការគាំទ្របច្ចេកទេសផ្សេងៗ។

<u>**ព័ត៌មានទំនាក់ទំនង**</u>

- **នាយករដ្ឋបាលសាលាស្រុក៖ លោក ហ៊ុន ឆឿន**
- **ទូរស័ព្ទ៖ ០៧៧៨៣៨៦៨២**

# ១៨. ការសម្របសម្រួលការគាំទ្រដល់ដំណើរការមត្តេយ្យសិក្សាសហគមន៍ ស្រុកសំពៅលូន ខេត្តបាត់ដំបង

## ១. សង្ខេបអំពីស្ថានភាពបញ្ហា

ស្រុកសំពៅលូន ជាស្រុកមួយដែលធ្លាប់ជាអតីតតំបន់មានជម្លោះពេលសង្គ្រាម ហេតុនេះ ពុំសូវមានសាលារៀន ពិសេសសាលាមត្តេយ្យរដ្ឋ។ នៅតំបន់នេះ ក្រៅពីមុខរបរធ្វើចំការក្នុងស្រុក ប្រជាពលរដ្ឋភាគច្រើនទៅប្រកបរបរនៅតំបន់ព្រំប្រទល់ប្រទេសថៃ ហើយកូនតូចត្រូវទុកនៅជាមួយមនុស្សចាស់នៅតាមភូមិ។ ដោយសារសាលារៀននៅឆ្ងាយ ក្មេងៗជាច្រើនបង្ខំចិត្តបោះបង់ចោលសាលារៀន។ ម្យ៉ាងទៀត ដោយសារតំបន់នេះមានប្រជាពលរដ្ឋចំណាកស្រុកពីបណ្តាខេត្តភាគកណ្តាលមករស់នៅឬប្រកបរបបការងារចំការតាមរដូវកាល ដោយមានទាំងកូនតូចៗមកជាមួយហើយពុំមានឱកាសចូលរៀន។ ដោយមានសំណូមពរជាច្រើនពីប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំ តាមរយៈវេទិកាសាធារណៈរបស់ក្រុមប្រឹក្សាស្រុក ហើយសមាជិកក្រុមប្រឹក្សាស្រុកចូលរួមកិច្ចប្រជុំប្រចាំខែរបស់ឃុំ បានស្នើសុំឱ្យរដ្ឋបាលស្រុកជួយសម្របសម្រួល កៀរគរការគាំទ្រដល់ការរៀបចំថ្នាក់មត្តេយ្យនៅតាមសហគមន៍ ព្រោះធនធានថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលឃុំមានកម្រិត ហើយតម្រូវថ្នាក់មត្តេយ្យមានច្រើន។ ដោយមានសំណូមពរ និងតម្រូវការជាក់ស្តែងច្រើន ក្រុមប្រឹក្សាស្រុកបានសម្រេចនៅក្នុងកិច្ចប្រជុំរបស់ខ្លួនក្នុងកំណត់សកម្មភាពលើកកម្ពស់ការបង្កើនថ្នាក់មត្តេយ្យសិក្សាសហគមន៍ជាអាទិភាពមួយ ក្នុងគោលបំណងជួយគាំទ្រដល់រដ្ឋបាលឃុំ បង្កើនការផ្តល់ឱកាសដល់ក្មេងតូចៗបានចូលរួមរៀនកាន់តែច្រើន។

## ២. ដំណើរការអនុវត្ត និងលទ្ធផល

បន្ទាប់ពីការសម្រេចរបស់ក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សាស្រុក ពិភាក្សា និងណែនាំអភិបាលនិងប្រធានប្រធានគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារស្រុក ឱ្យទទួលខុសត្រូវក្នុងការសម្របសម្រួល និងគាំទ្រដល់រដ្ឋបាលឃុំក្នុងអនុវត្តសកម្មភាពលើកកម្ពស់ការបង្កើតថ្នាក់មត្តេយ្យសិក្សាសហគមន៍។ បន្ទាប់មកអភិបាល បានសម្របសម្រួលជាមួយប្រធានគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារស្រុក ការិយាល័យអប់រំ ការិយាល័យកិច្ចការនារី ធ្វើទំនាក់ទំនងជាមួយអង្គការUNICEF ស្នើសុំការគាំទ្រលើការបង្កើនចំនួនថ្នាក់មត្តេយ្យសិក្សាសហគមន៍។ ទន្ទឹមនឹងនេះ ប្រធានគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារស្រុកបានសហការជាមួយការិយាល័យអប់រំ អង្គការសង្គមស៊ីវិល និងរដ្ឋបាលឃុំពាក់ព័ន្ធ ដើម្បីប្រមូលព័ត៌មានបន្ថែមដូចជាចំនួនភូមិ ឃុំ ស្ថានភាពរស់នៅនិងចំនួនគ្រួសារ ចំនួនកុមារ និងការចូលរួមបដិភាគរបស់គ្រួសារ ជ្រើសរើសទីតាំង កំណត់ចំនួនកុមារ ស្វែងរកគ្រូស្ម័គ្រចិត្ត ជាដើម។ បន្ទាប់ពីទទួលបានព័ត៌មានចាំបាច់នានា គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារស្រុក បានរៀបចំរបាយការណ៍ សំណើគម្រោងសកម្មភាព និងថវិកា ពាក់ព័ន្ធនឹងតម្រូវការចំនួនថ្នាក់មត្តេយ្យដែលត្រូវបង្កើត ចំនួនគ្រូស្ម័គ្រចិត្ត ដើម្បីដាក់ជូនគណៈអភិបាល និងក្រុមប្រឹក្សា ពិនិត្យផ្តល់យោបល់ និងសម្រេចដើម្បីគាំទ្រដល់រដ្ឋបាលដែលបានលើកសំណើក្នុងការបង្កើនថ្នាក់មត្តេយ្យសិក្សា

សហគមន៍។ បន្ទាប់ពីគណៈអភិបាល និងក្រុមប្រឹក្សា បានឯកភាពលើសំណើគម្រោងសកម្មភាពរួចមក គ.ក.ស.ក.បានសម្របសម្រួលជាមួយឃុំគោលដៅ ការិយាល័យអប់រំស្រុក អង្គការសង្គមស៊ីវិល និង UNICEF ដើម្បីរៀបចំថ្នាក់មត្តេយ្យ ព្រមទាំងដំណើរការប្រកាសជ្រើសរើស និងរៀបចំកិច្ចសន្យាគ្រូស្ម័គ្រចិត្ត(កិច្ចសន្យារវាងរដ្ឋបាលឃុំនិងគ្រូស្ម័គ្រចិត្ត)។ បន្ទាប់ពីជ្រើសរើសបានគ្រូស្ម័គ្រចិត្តការិយាល័យអប់រំស្រុក និងUNICEF ចាប់ផ្តើមបណ្តុះបណ្តាលគ្រូ និងផ្តល់សម្ភារៈសិក្សាដល់ថ្នាក់និងសិស្ស ចំណែករដ្ឋបាលឃុំ បានសហការគ្នាជាមួយមេភូមិដើម្បីជូនដំណឹង និងប្រមូលកុមារតូចៗចូលរៀន។ ក្នុងពេលដំណើរការថ្នាក់មត្តេយ្យ គ.ក.ស.ក. និងការិយាល័យអប់រំស្រុកត្រួតពិនិត្យតាមដានដំណើរការរបស់ថ្នាក់មត្តេយ្យសិក្សាសហគមន៍ និងរាយការណ៍ប្រចាំខែជូនគណៈអភិបាលនិងក្រុមប្រឹក្សា។ ជា**លទ្ធផលនៃ**ការអនុវត្តមុខងារនេះ គឺបានបង្កើតថ្នាក់មត្តេយ្យសិក្សាសហគមន៍បានចំនួន២០ថ្នាក់ ដែលមានសិស្សតូចៗចំនួនប្រហែល១៨០នាក់។ រដ្ឋបាលស្រុកបានលើកឡើងថា ឪពុកម្តាយសិស្សមានការពេញចិត្ត ហើយតែងស្នើសុំឃុំនិងស្រុកបើកថ្នាក់បន្ថែមទៀត ព្រោះក្រៅពីបានជួយផ្តល់ចំណេះដឹងដល់កុមារតូចៗ គឺបានជួយសម្រាលបន្ទុករបស់គ្រួសារប្រជាពលរដ្ឋដែលទៅឆ្ងាយៗពីភូមិឃុំ។

## ៣. បទពិសោធន៍ និងបញ្ហាប្រឈម

មេរៀនបទពិសោធន៍ទទួលបាន រួមមាន៖ (១) លើកកម្ពស់ការយល់ដឹងពីគណនេយ្យភាពរបស់ក្រុមប្រឹក្សា និងរដ្ឋបាលស្រុកចំពោះក្រុមប្រឹក្សាឃុំ តាមរយៈការគាំទ្រចំពោះតម្រូវការខ្ពស់របស់ប្រជាពលរដ្ឋ។(២)ទទួលចំណេះដឹងពីសារៈសំខាន់នៃការសហប្រតិបត្តិការ និងការគាំទ្រអន្តររដ្ឋបាលរវាងរដ្ឋបាលស្រុក និងរដ្ឋបាលឃុំ បានផ្តល់លទ្ធផលការងារច្រើនក្នុងការសម្រេចបាននូវគោលបំណងរួម។ (៣) យល់ដឹងអំពីការសម្របសម្រួល និងសហការរវាងអង្គភាពជំនាញ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា។ ក្នុងអំឡុងពេលអនុវត្តរដ្ឋបាលស្រុកបាន**បញ្ហាប្រឈមដូចជា៖** (១)ខ្វះគ្រូស្ម័គ្រចិត្តពីព្រោះប្រាក់ឧបត្ថម្ភមានតិចពេក ពិបាករកគ្រូ (២) រដ្ឋបាលស្រុកខ្វះថវិកា ខ្វះបុគ្គលិកក្នុងការគាំទ្រការអនុវត្តសកម្មភាព (៣) ទីលំនៅរបស់កុមារ នៅឆ្ងាយៗពីគ្នាដែលមានការលំបាកប្រមូលផ្តុំបង្កើតថ្នាក់មត្តេយ្យសិក្សាសហគមន៍។

## ៤. សក្តានុពលក្នុងការពង្រីកការអនុវត្តទៅទីកន្លែងផ្សេងទៀត

ការអនុវត្តមុខងារដូចខាងលើនេះ មានសក្តានុពលក្នុងការទទួលបានជោគជ័យ ពិសេសនៅតំបន់ដែលពុំសូវមានសាលាមត្តេយ្យសិក្សាឬសាលានៅឆ្ងាយពីសហគមន៍។ ដើម្បីគាំទ្រដល់រដ្ឋបាលឃុំ រដ្ឋបាលស្រុកចាំបាច់ត្រូវមានកញ្ចប់ថវិការបស់ខ្លួនផ្ទាល់សម្រាប់ចំណាយលើការងារសម្របសម្រួល និងផ្តល់ការគាំទ្របច្ចេកទេសផ្សេងៗ។

<u>ព័ត៌មានទំនាក់ទំនង</u>

- **នាយករដ្ឋបាលសាលាស្រុក៖ លោក ត្រែ រ័ត្ន**
- **លេខទូរស័ព្ទ៖ ០១២៨៦៤៧៦៧**

# ១៩. យុទ្ធនាការអប់រំការយល់ដឹងលើការគ្រប់គ្រងសំរាម ស្រុកសន្ទែ ខេត្តបាត់ដំបង

## ១. សង្ខេបអំពីស្ថានភាពបញ្ហា

មានបណ្តឹង និងការតវ៉ាជាច្រើនពីប្រជាពលរដ្ឋ អំពីសំរាមត្រូវបានបោះចោលពាសវាលពាសកាលតាមទីសាធារណៈ ដោយគ្មានការវេចខ្ចប់ត្រឹមត្រូវ ក្លិនស្អុយតាមទីប្រជុំជនស្រុក រួមទាំងការចោលសំរាមនៅជិតសាលារៀនដែលអាចបង្កគ្រោះថ្នាក់សុខភាពដល់សិស្ស ខូចខាតបរិស្ថាន និងបំផ្លាញសោភ័ណភាពទីប្រជុំជនស្រុក ដែលស្ថិតនៅមិនឆ្ងាយពីទីរួមខេត្ត និងស្ថិតនៅតាមបណ្តាលផ្លូវជាតិលេខ៥។ ដោយសារបញ្ហាគ្រប់គ្រងសំរាម មិនបានត្រឹមត្រូវល្អ ក្រុមប្រឹក្សាបានពិភាក្សាជាមួយគណៈអភិបាលស្រុកដោយមានការគាំទ្រពីការិយាល័យជំនាញ ក្នុងការរកដំណោះស្រាយលើបញ្ហានេះ។ ក្រុមប្រឹក្សា និងគណៈអភិបាលដោយមានការគាំទ្រពីការិយាល័យជំនាញ បានកំណត់អាទិភាពដោះស្រាយបញ្ហានេះដោយការបោះឆ្នោតក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។ គោលបំណងនៃការអនុវត្តមុខងារនៃការរៀបចំយុទ្ធនាការអប់រំការយល់ដឹងអំពីការគ្រប់គ្រងសំរាម គឺដើម្បីបង្កើនការយល់ដឹងអំពីគ្រោះថ្នាក់នៃការបោះចោលសំរាមពាសវាលពាសកាលតាមទីសាធារណៈ ដោយគ្មានការវេចខ្ចប់ត្រឹមត្រូវ និងដើម្បីលើកកម្ពស់សោភ័ណភាពទីប្រជុំជនកាន់តែល្អប្រសើរ។ រដ្ឋបាលស្រុកបានផ្តួចផ្តើមកិច្ចការងារនេះនៅក្នុងខែកុម្ភៈឆ្នាំ២០១៨ ហើយកំពុងរៀបចំឯកសារគម្រោង កាលបរិច្ឆេទបញ្ចប់គម្រោងគឺប្រហែលពាក់កណ្តាលឆ្នាំ២០១៩ ដែលត្រូវអនុវត្តក្នុងឃុំចំនួន៥ (មានលំនៅដ្ឋានរាប់ពាន់ក់ រួមទាំងអាជីករលក់ដូរ)។

## ២. ដំណើរការអនុវត្ត និងលទ្ធផល

ក្រុមប្រឹក្សាបានពិភាក្សាបញ្ហានេះ និងបានផ្តល់អាទិភាពខ្ពស់ក្នុងការដោះស្រាយ អនុម័តផែនការសកម្មភាពក្នុងការកំណត់ពីបញ្ហា ការរៀបចំសំណើគម្រោងជាមួយអ្នកពាក់ព័ន្ធ(រាល់ជំហាននៃការរៀបចំត្រូវបានអនុម័តដោយក្រុមប្រឹក្សាស្រុក) អនុម័តនូវសំណើគម្រោងសម្រាប់ដាក់ជូន EU-DAR ក្នុងការស្នើសុំថវិកា និងបន្តត្រួតពិនិត្យតាមដានលើវឌ្ឍនភាពនៃការអនុវត្តសកម្មភាពតាមរយៈរបាយការណ៍នៅក្នុងកិច្ចប្រជុំរបស់ខ្លួន។ ដោយមានការគាំទ្រពីនាយករដ្ឋបាល និងការិយាល័យចំណុះសាលាស្រុក គណៈអភិបាល បានគាំទ្រក្រុមប្រឹក្សាក្នុងស្វែងរកលិខិតបទដ្ឋានពាក់ព័ន្ធលើការគ្រប់គ្រងសំរាម ដោយទំនាក់ទំនងជាមួយរដ្ឋបាលខេត្ត មន្ទីរបរិស្ថានខេត្ត រៀបចំសេចក្តីផែនការសកម្មភាពសម្រាប់កំណត់បញ្ហា រៀបចំសំណើគម្រោង រៀបចំកិច្ចប្រជុំនានាដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ដាក់សំណើគម្រោងជូនក្រុមប្រឹក្សាពិភាក្សា និងអនុម័ត សម្របសម្រួលជាមួយការិយាល័យបរិស្ថាន ការិយាល័យស្រុកប្រតិបត្តិសុខាភិបាល អ្នកគ្រប់គ្រងផ្សារ ការិយាល័យអប់រំ ដើម្បីបញ្ចូលក្នុងក្រុមការងារ និងបន្តតាមដានការងាររបស់ក្រុមការងារក្នុងការរៀបចំនូវរបាយការណ៍វឌ្ឍនភាពនៃសកម្មភាពសម្រាប់ដាក់ជូនក្រុមប្រឹក្សា ទំនាក់ទំនងជាមួយការិយាល័យជំនាញពាក់ព័ន្ធ រដ្ឋបាលឃុំ អ្នកគ្រប់គ្រង

ផ្សារ អ្នកប្រមូលសំរាម ដើម្បីចូលរួមក្នុងយុទ្ធនាការលើកកម្ពស់ការយល់ដឹងអំពីសំរាម។ ដោយសារបញ្ហាមានទំហំធំពេកក្នុងការដោះស្រាយ អភិបាលស្រុកបានបង្កើតក្រុមការងារទទួលបន្ទុកលើបញ្ហាសំរាម។ ក្រុមការងារនឹងរៀបចំស្នើអំពីផែនការសកម្មភាព ដោយបញ្ចូលនូវការបញ្ហាដោយប្រមូលព័ត៌មានបន្ថែមជាមួយប្រជាពលរដ្ឋ។ ក្រុមការងារនឹងពិភាក្សាអំពីជម្រើសនានាក្នុងការដោះស្រាយ អំពីតួនាទីរបស់អ្នកពាក់ព័ន្ធ (ប្រជាពលរដ្ឋ អាជីវករលក់ដូរ អ្នកគ្រប់គ្រងផ្សារ អ្នកប្រមូលសំរាម សាលារៀន មណ្ឌលសុខភាព និងរដ្ឋបាលឃុំ) ក្នុងការអប់រំអំពីការគ្រប់គ្រងសំរាម។ ព័ត៌មានទាំងអស់នេះនឹងត្រូវរៀបចំជាសំណើគម្រោងសម្រាប់ការពិភាក្សាបន្ថែមទៀតជាមួយគណៈអភិបាល និងក្រុមប្រឹក្សា។ បន្ទាប់ពីការពិភាក្សា ការកែសម្រួល និងការអនុម័តដោយក្រុមប្រឹក្សា សេចក្តីព្រាងនៃសំណើគម្រោងនឹងត្រូវដាក់ជូន EU-DAR ស្នើសុំថវិកា។ ក្នុងដំណាក់កាលនៃការអនុវត្ត ក្រុមការងារនឹងរៀបចំផែនការសកម្មភាព និងថវិកាលម្អិតស្នើសុំការអនុម័តពីក្រុមប្រឹក្សា និងរៀបចំកិច្ចប្រជុំនានាជាមួយអ្នកពាក់ព័ន្ធរៀបចំយុទ្ធនាការអប់រំ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ អាជីករលក់ដូរ សិស្សសាលា ដាក់ស្លាកសញ្ញាព័ត៌មានអប់រំតាមទីប្រជុំជន។ ក្រុមការងារសហការជាមួយនាយករដ្ឋបាលស្រុក ក្នុងការរៀបចំរបាយការណ៍ប្រចាំខែ សម្រាប់ជូនគណៈអភិបាល និងក្រុមប្រឹក្សា។ រដ្ឋបាលស្រុក បានប្រគល់ការទទួលខុសត្រូវលើការត្រួតពិនិត្យតាមដានការងារនេះដល់ក្រុមការងារ ពិសេសការិយាល័យបរិស្ថាន ការិយាល័យអន្តរវិស័យក្នុងការបំពេញតួនាទីចម្បងលើការត្រួតពិនិត្យតាមដាន និងធ្វើរបាយការណ៍ប្រចាំខែជូនគណៈអភិបាល និងក្រុមប្រឹក្សា។ **ថវិកា៖**ការអនុវត្តមុខងារនៃការរៀបចំយុទ្ធនាការអប់រំការយល់ដឹងអំពីការគ្រប់គ្រងសំរាម ស្ថិតក្នុងដំណាក់កាលកំពុងរៀបចំហើយគម្រោងនេះនឹងស្នើសុំថវិកាពី EU-DAR ក្នុងនោះមានចំណែក១០%ជាថវិការបស់រដ្ឋបាលស្រុក។

រដ្ឋបាលស្រុកបានដឹងអំពីការពេញចិត្តរបស់ប្រជាពលរដ្ឋ ហើយពួកគាត់ពេញចិត្តក្នុងការចូលរួមគាំទ្រ និងបង់កម្រៃលើការផ្តល់សេវានេះ។ នៅពេលអនុវត្ត រដ្ឋបាលស្រុក និងអ្នកពាក់ព័ន្ធនានា នឹងធ្វើការអប់រំប្រជាពលរដ្ឋ អ្នកលក់ដូរ សិស្សសាលាអំពីការវេចខ្ចប់សំរាម អំពីកាតព្វកិច្ចរបស់ប្រជាពលរដ្ឋក្នុងការបង់ថ្លៃប្រមូលសំរាម និងការពិន័យចំពោះការមិនគោរពច្បាប់។ រដ្ឋបាលស្រុក នឹងផលិតស្លាកសញ្ញាអប់រំនៅតាមផ្សារ តាមសាលារៀន និងតាមទីសាធារណៈអំពីការគ្រប់គ្រងសំរាម។ រដ្ឋបាលស្រុកសហការជាមួយអ្នកប្រមូលសំរាមអំពីការកំណត់ពេលវេលាប្រមូលសំរាមតាមផ្ទះ។

## ៣. បទពិសោធន៍ និងបញ្ហាប្រឈម

មេរៀនបទពិសោធន៍ទទួលបាន៖ (១)ការអនុវត្តមុខងារគឺមានការពាក់ព័ន្ធជាមួយក្រុមយុវជន និងសិស្សសាលា ដែលនឹងដើរតួនាទីយ៉ាងសកម្មក្នុងការអប់រំអំពីការគ្រប់គ្រងសំរាម ហើយអាជីវករលក់ដូរ និងអ្នកនៅតាមលំនៅដ្ឋានត្រូវចូលរួមបង់កម្រៃសេវាប្រមូលសំរាម។ (២)ការរៀបចំសកម្មភាពនេះគឺមានការចូលរួមពីអង្គការសង្គមស៊ីវិលពាក់ព័ន្ធនឹងចូលរួមក្នុងកិច្ចប្រជុំនានា ជាមួយរដ្ឋបាលស្រុក និងគាំទ្រក្នុងដំណើរការយុទ្ធនាការអប់រំអំពីការគ្រប់គ្រងសំរាម (៣) ជារបៀបសហការថ្មីមួយរវាងរដ្ឋបាលស្រុក និងវិស័យឯកជនលើការផ្តល់សេវា ដោយរដ្ឋបាលស្រុកនឹងសហការជាមួយផ្នែកឯកជនក្នុងការប្រមូលសំរាម រីឯថវិកាគម្រោងគឺសម្រាប់គាំទ្រការអប់រំ ផ្សព្វផ្សាយការយល់ដឹង និងការផលិតស្លាក

សញ្ញាព័ត៌មានអប់រំ(៤) ក្រុមប្រឹក្សានឹងធ្វើការងារជាមួយឃុំ និងលើកទឹកចិត្តក្នុងការបញ្ចូលការងារនេះទៅក្នុងថវិកាឃុំ (៥) រដ្ឋបាលបានលើកឡើងថាប្រសិនពុំមានការគាំទ្រ និងសហការពីរដ្ឋបាលខេត្ត និងរដ្ឋបាលក្រុង ស្រុកមានព្រំប្រទល់ជាប់គ្នា និងការគាំទ្រពីខាងក្រៅ នោះរដ្ឋបាលស្រុកមិនអាចអនុវត្តសកម្មភាពដោះស្រាយបញ្ហាធំៗដូច្នេះបានទេ ដោយស្រុកពុំមានធនធាន និងបុគ្គលិកគ្រប់គ្រាន់។ ដូច្នេះស្រុកបានបង្កើតក្រុមការងារដើម្បីប្រមូលធនធានមនុស្សពីអង្គភាពផ្សេងៗ និងឃុំសម្រាប់គាំទ្រការអនុវត្ត។

**បញ្ហាប្រឈម៖** (១)បញ្ហាសំរាមមានវិសាលធំ ដែលពាក់ព័ន្ធមនុស្ស និងគ្រួសារជាច្រើន (២) ដំណើរការរៀបចំសំណើគម្រោង សម្រាប់ស្នើសុំថវិកាត្រូវអនុវត្តជំហានជាច្រើនដែលត្រូវការពេលវេលាច្រើន (៣) អ្នកប្រមូលសំរាមចុះកិច្ចសន្យាជាមួយខេត្តធ្វើឱ្យស្រុកមានការលំបាកក្នុងការធ្វើការងារជាមួយ (៤) រដ្ឋបាលស្រុកពុំមានថវិកា និងខ្វះបុគ្គលិកដែលមានបទពិសោធន៍លើបញ្ហានេះ។

## ៤. សក្ដានុពលក្នុងការពង្រីកការអនុវត្តទៅទីកន្លែងផ្សេងទៀត

ក្នុងការអនុវត្តមុខងារគ្រប់គ្រងសំរាម តាមទីប្រជុំជន រដ្ឋបាលស្រុកត្រូវតែមានសិទ្ធិអំណាចក្នុងការវិភាជថវិកាប្រចាំរបស់ខ្លួនសម្រាប់គាំទ្រ ការអនុវត្តការផ្ដល់សេវាបែបនេះ។ រដ្ឋបាលក្រុង ស្រុក ត្រូវត្រៀមទីតាំងសម្រាប់ធ្វើជាទីលានចាក់សំរាម ឬរដ្ឋបាលក្រុង ស្រុកអាចពិភាក្សាជាមួយរដ្ឋបាលខេត្ត ឬរដ្ឋបាលក្រុង ស្រុកផ្សេងទៀតក្នុងប្រើប្រាស់ទីលានរួមគ្នា ម្យ៉ាងទៀតត្រូវមានវិធានការម៉ឺងម៉ាត់ចំពោះអ្នកចោលសំរាមពាលវាលពាសកាល បើមិនដូច្នេះ ការគ្រប់គ្រងសំរាមនឹងមិនបានជោគជ័យ។ ម្យ៉ាងទៀតកិច្ចសន្យាប្រមូលសំរាមរបស់ក្រុមហ៊ុនឯកជន ត្រូវតែព្រមព្រៀងជាមួយរដ្ឋបាលស្រុកដើម្បីរដ្ឋបាលស្រុកមានសិទ្ធិត្រួតពិនិត្យ តាមដាន ឬដាក់ពិន័យក្នុងករណីក្រុមហ៊ុនមិនអនុវត្តតាម។

**<u>ព័ត៌មានទំនាក់ទំនង</u>**

- **នាយករដ្ឋបាលសាលាស្រុក៖ លោក សុខ ហឿន**
- **លេខទូរស័ព្ទ៖ ០៩២ ៣៣ ៤០ ៦៧**

# ២០. ការរៀបចំតំបន់ទេសចរណ៍ធម្មជាតិ
# ស្រុកថ្មគោល ខេត្តបាត់ដំបង

## ១. សង្ខេបអំពីស្ថានភាពបញ្ហា

ចំនួនបឹងបួធម្មជាតិជាច្រើននៅក្នុងស្រុក កំពុងគោករាក់ ដោយសារកត្តាធម្មជាតិ កត្តាប្រើប្រាស់របស់មនុស្ស ការធ្វើដំណាំនៅតាមមាត់បឹង កង្វះការថែទាំ និងគ្មានការគ្រប់គ្រងត្រឹមត្រូវ ដោយការបូមបាចដើម្បីចាប់ត្រី។ ការថយចុះចំនួនបឹងបួនេះ បានធ្វើឱ្យមានព្រួយបារម្ភជាខ្លាំងចំពោះសហគមន៍ ប្រជាពលរដ្ឋដែលប្រើប្រាស់បឹងបួទាំងនោះសម្រាប់វិស័យកសិកម្ម សម្រាប់ការប្រើប្រាស់របស់មនុស្ស សត្វ និងជាប្រភពជម្រកមេត្រីពូជ និងសត្វស្លាបផ្សេងៗ។ ដោយបានឃើញស្ថានភាពប្រែប្រួលបែបនេះប្រជាសហគមន៍បានសំណូមជាច្រើនតាមរយៈក្រុមប្រឹក្សាឃុំ និងសំណូមពរផ្ទាល់មកក្រុមប្រឹក្សា និងរដ្ឋបាលស្រុកតាមរយៈវេទិកានានារបស់រដ្ឋបាលស្រុក ដើម្បីជួយដោះស្រាយ ធ្វើយ៉ាងណាអភិរក្សបឹងបួធម្មជាតិទាំងនោះ សម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព។ ដោយមានសំណូមពរជាច្រើន ទើបក្រុមប្រឹក្សានិងរដ្ឋបាលស្រុក បានឯកភាព និងបានលើកគំនិតផ្តួចផ្តើមអំពីការស្តារបឹងមួយចំនួន ក្នុងកិច្ចប្រជុំក្រុមប្រឹក្សា ហើយបានសម្រេចបញ្ចូលទៅក្នុងកម្មវិធីវិនិយោគរបស់ស្រុកក្នុងឆ្នាំ ២០១៧ ដោយលើកគម្រោងសម្រាប់រៀបចំជាតំបន់ទេសចរណ៍ធម្មជាតិ"**បឹងថ្កូវ**"។ គម្រោងរៀបចំតំបន់ទេសចរណ៍ធម្មជាតិបឹងថ្កូវនេះ គឺដើម្បីលើកកម្ពស់ការយល់ដឹងអំពីសារៈប្រយោជន៍ និងអភិរក្សបឹងធម្មជាតិសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព ដែលគម្រោងនេះចាប់ផ្តើមអនុវត្តពីចុងឆ្នាំ ២០១៧ ដល់ឆ្នាំ២០១៨។ គម្រោងនេះ ត្រូវបានប្រើប្រាស់ថវិការួមគ្នាគឺ មូលនិធិស្រុកបានប្រើប្រាស់ក្នុងការស្តារបឹង ហើយមូលនិធិឃុំ បានប្រើប្រាស់សម្រាប់សាងសង់ផ្លូវទៅបឹង។ ទោះបីយ៉ាងនេះក៏ដំណើរការធ្វើលទ្ធកម្មត្រូវអនុវត្តដាច់ដោយឡែកពីគ្នាតាមនីតិវិធីហិរញ្ញវត្ថុផ្សេងៗគ្នា។ សហគមន៍បានចូលរួមថវិកាបដិភាគក្នុងមូលនិធិឃុំលើគម្រោងសាងសង់ផ្លូវចូលបឹង។ រដ្ឋបាលព្រៃឈើផ្តល់កូនឈើដើម្បីដាំជុំវិញតំបន់បឹង។

## ២. ដំណើរការអនុវត្ត និងលទ្ធផល

បន្ទាប់ពីក្រុមប្រឹក្សា បានអនុម័តអនុវត្តគម្រោងរៀបចំតំបន់ទេសចរណ៍ធម្មជាតិបឹងថ្កូវ ដែលមាននៅក្នុងកម្មវិធីវិនិយោគរបស់ស្រុក ដោយប្រើប្រាស់មូលនិធិអភិវឌ្ឍន៍ស្រុក ក្រុមប្រឹក្សាស្រុក បានណែនាំអភិបាលឱ្យរៀបចំសេចក្តីព្រាងសេចក្តីសម្រេចក្នុងការបង្កើតក្រុមការងារ ដើម្បីសិក្សាគម្រោងផលប៉ះពាល់បរិស្ថាន និងផលប៉ះពាល់ផ្សេងៗទៀត។ ក្រុមប្រឹក្សាស្រុកបានអនុម័តសមាសភាពក្រុមការងារនេះ ដែលត្រូវបានដឹកនាំដោយអភិបាលរងស្រុក១រូប និងមានសមាសភាពមកពីអង្គភាពលទ្ធកម្ម ការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ ការិយាល័យអន្តរវិស័យ ការិយាល័យបរិស្ថាន និងការិយាល័យកសិកម្ម និងការិយាល័យធនធានទឹក។ ទន្ទឹមនឹងនេះ អភិបាល បានសម្របសម្រួលជាមួយរដ្ឋបាលឃុំ

ពាក់ព័ន្ធអនុវត្តគម្រោងមូលនិធិឃុំ(បានប្រើប្រាស់សម្រាប់សាងសង់ផ្លូវទៅបឹង) ដែលជាផ្នែកមួយនៃគម្រោងកែលម្អតំបន់ទេសចរណ៍ធម្មជាតិ ព្រមទាំងបានសម្របសម្រួលជាមួយការិយាល័យជំនាញ និងមន្ទីរពាក់ព័ន្ធដូចជាបរិស្ថាន ធនធានទឹក និងកសិកម្មក្នុងការគាំទ្របច្ចេកទេសដល់ការអនុវត្តគម្រោងនេះ។ ដោយមានការគាំទ្របច្ចេកទេសពីអង្គភាពថ្នាក់ខេត្ត ក្រុមការងារបានរៀបចំព័ត៌មានគម្រោង ទំហំការងារដែលត្រូវធ្វើ សិក្សាតម្លៃប៉ាន់ស្មាន និងសិក្សាផលប៉ះពាល់នានាស្របតាមនិតិវិធីណែនាំនៃការសិក្សាគម្រោងក្រុង ស្រុក។ លទ្ធផលនៃការសិក្សាគម្រោងនេះ ត្រូវបានដាក់ជូនអភិបាលក្នុងនាមជាប្រធានគណៈកម្មាធិការលទ្ធកម្មរបស់ស្រុក ដើម្បីណែនាំដល់អង្គភាពលទ្ធកម្មរបស់រដ្ឋបាលស្រុក និងអ្នកពាក់ព័ន្ធនានា បានចូលរួមក្នុងការរៀបចំផែនការសកម្មភាពពាក់ព័ន្ធការងារលទ្ធកម្ម និងការអនុវត្តនៃការស្តារបឹងធម្មជាតិ ហើយសេចក្តីព្រាងនេះ ត្រូវបានដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាស្រុកដើម្បីពិភាក្សា និងសម្រេច។ ដោយសារគម្រោងនេះ ប្រើប្រាស់មូលនិធិអភិវឌ្ឍន៍ស្រុក ហេតុនេះដំណើរការធ្វើលទ្ធកម្ម ការអនុវត្តគម្រោង និងការទូទាត់ត្រូវបានអនុវត្តស្របតាមសេចក្តីណែនាំស្តីពីវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ លទ្ធផលនៃការអនុវត្តគម្រោងនេះ គឺបានស្តារបឹង កែលម្អផ្លូវទៅកាន់បឹង ដាំដើមឈើ និងតុបតែងលម្អជុំវិញបឹង ដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ ហើយ ប្រជាពលរដ្ឋមានការអបអរនឹងគម្រោងនេះ ព្រោះបានឆ្លើយតបតាមការស្នើសុំរបស់ប្រជាពលរដ្ឋ រស់នៅជុំវិញបឹងធម្មជាតិអាចរកប្រាក់ចំណូលបានពីទេសចរណ៍ ហើយបឹងបានក្លាយជាប្រភពទឹកប្រើប្រាស់របស់មនុស្ស សត្វ ការដាំដំណាំ និងជាប្រភពជម្រកមេត្រីពូជ និងសត្វស្លាបផ្សេងៗ។

## ៣. បទពិសោធន៍ និងបញ្ហាប្រឈម

ជារួមតាមរយៈការអនុវត្តគម្រោងនេះ រដ្ឋបាលស្រុក និងរដ្ឋបាលឃុំទទួលបានបទពិសោធន៍ដូចជា៖ (១). ពង្រឹងកិច្ចសហការរវាងរដ្ឋបាលស្រុក និងរដ្ឋបាលឃុំ ជាមួយសហគមន៍ដោយគម្រោងនេះបានប្រើប្រាស់ទាំងមូលនិធិអភិវឌ្ឍន៍ស្រុក និងមូលនិធិអភិវឌ្ឍន៍ឃុំ ហើយប្រជាពលរដ្ឋចូលរួមសម្បទានដីដល់គម្រោង ពួកគាត់មានការពេញចិត្ត ដោយគម្រោងឆ្លើយតបនឹងតម្រូវការរបស់ពួកគាត់ និងផ្តល់ផលប្រយោជន៍រួមដល់សហគមន៍ផងដែរដើម្បីគោលបំណងរួមរបស់សហគមន៍ (២). បានលើកកម្ពស់ការយល់ដឹងថ្មីៗដល់ក្រុមប្រឹក្សា និងមន្ត្រីស្រុកអំពីការដោះស្រាយបញ្ហាអាទិភាពដែលសម្រេចបាននូវគោលបំណងច្រើនយ៉ាង គឺបានសម្រេចនូវគោលបំណងច្រើនទាំងការលើកកម្ពស់បរិស្ថានធម្មជាតិ ប្រភពទឹកប្រើប្រាស់ និងរក្សាពូជត្រី បង្កើតតំបន់ទេសចរណ៍ធម្មជាតិ និងការរួមចំណែកលើកកម្ពស់សេដ្ឋកិច្ចមូលដ្ឋាន។ បញ្ហាប្រឈមដែលរដ្ឋបាលស្រុកជួបប្រទះរួមមាន៖ (១). ដំណើរការសិក្សា រៀបចំគម្រោង លទ្ធកម្ម និងការអនុវត្តត្រូវចំណាយពេលយូរ ដោយសារមានការពាក់ព័ន្ធជាមួយសមត្ថកិច្ចច្រើន ហើយត្រូវចរចារជាមួយប្រជាពលរដ្ឋដែលប៉ះពាល់ដីធ្លី (២).ខ្វះអ្នកជំនាញបច្ចេកទេសក្នុងការអនុវត្តគម្រោងនេះ (៣). ការផ្ទេរថវិកាមករដ្ឋបាលស្រុកមានការយឺតយ៉ាវ និងទទួលបានថវិកាពេលរដូវវស្សាដែលពិបាកក្នុងការអនុវត្តសកម្មភាពដែលត្រូវធ្វើក្នុងរដូវប្រាំង។

## ៤. សក្តានុពលក្នុងការពង្រីកការអនុវត្តទៅទីកន្លែងផ្សេងទៀត

មុខងារមានសក្តានុពលអនុវត្តបានស្ទើរគ្រប់ទីកន្លែង ពិសេសនៅតាមបណ្តាស្រុកតាមជនបទដែលសំបូរបឹងធម្មជាតិ ប៉ុន្តែស្រុកដែលចង់អនុវត្តមុខងារត្រូវមានថវិការបស់ស្រុកផ្ទាល់ ហើយត្រូវមានគោលការណ៍ណែនាំច្បាស់លាស់ក្នុងការទប់ស្កាត់ការរំលោភទន្រ្ទានផ្សេងៗ ដើម្បីផលប្រយោជន៍បុគ្គល។ ជាការប្រសើរ ការអនុវត្តគម្រោងដែលមានលក្ខណៈអន្តររដ្ឋបាល គម្រោងដែលផ្តល់ផលប្រយោជន៍ដល់សហគមន៍ដែលរស់នៅក្នុងឃុំផ្សេងៗគ្នា ឬស្រុកផ្សេងៗគ្នាគួរមានគណៈកម្មការគ្រប់គ្រងរួម ដើម្បីលើកកម្ពស់ការពង្រីកកិច្ចសហប្រតិបត្តិការ និងការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋពីរដ្ឋបាលមួយទៅរដ្ឋបាលមួយទៀត។

**<u>ព័ត៌មានទំនាក់ទំនង</u>**

- **នាយករដ្ឋបាលសាលាស្រុក៖ លោកស្រី សៀន ផាវី**
- **លេខទូរស័ព្ទ៖ ០៧៧ ៦៣៦ ២៥៨**

# ២១. ការគ្រប់គ្រងសហគមន៍ឥណទានមានជ័យ

# ឃុំគោកបន្ទាយ ស្រុករលាផ្អៀរ ខេត្តកំពង់ឆ្នាំង

## ១. សង្ខេបអំពីស្ថានភាពបញ្ហា

ក្រោយពេលអង្គការប្រាសាក់បញ្ចប់គម្រោងក្រុមសន្សំប្រាក់របស់ខ្លួន ក្រុមសន្សំប្រាក់ជាច្រើននៅក្នុងឃុំជិតខាង បានចាប់ផ្តើមរំសាយជាបណ្តើរៗដោយសារកង្វះការគ្រប់គ្រង និងការគាំទ្រ។ ដោយមានការព្រួយបារម្ភ ក្រុមប្រឹក្សាឃុំគោកបន្ទាយបានសម្រេចចិត្តរៀបចំពង្រឹងឡើងវិញនូវក្រុមសន្សំប្រាក់នេះបន្តពីអង្គការប្រាសាក់ ដោយបានសម្រេចប្រែក្លាយក្រុមសន្សំប្រាក់នេះទៅជាសហគមន៍សន្សំប្រាក់ដែលមានឈ្មោះថា "សហគមន៍ឥណទានមានជ័យ"។ សហគមន៍ឥណទាននេះ បានរៀបចំឱ្យមានលក្ខន្តិកៈ គោលការណ៍ ផែនការអភិវឌ្ឍសមត្ថភាព និងស្វែងរកការគាំទ្រពីអង្គការសង្គមស៊ីវិលនានាក្នុងការអភិវឌ្ឍសមត្ថភាពដល់សហគមន៍ឥណទានលើការគ្រប់គ្រង និងបច្ចេកទេសផ្នែកហិរញ្ញវត្ថុជាដើម។

## ២. ដំណើរការអនុវត្ត និងលទ្ធផល

ក្រុមប្រឹក្សាឃុំបានចាត់ឱ្យសមាជិកក្រុមប្រឹក្សាមួយរូបចុះរៀបចំចងក្រងឡើងវិញ និងពង្រីកនូវក្រុមសន្សំប្រាក់នៅក្នុងសហគមន៍ឥណទាននេះ។ ក្រោយទទួលបាននូវការចាត់តាំងរបស់ក្រុមប្រឹក្សាឃុំ សមាជិកក្រុមប្រឹក្សារូបនេះបានរៀបចំចងក្រងនូវលក្ខន្តិកៈ រៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាលសហគមន៍ឥណទាន និងជ្រើសរើសអ្នកស្ម័គ្រចិត្ត ដើម្បីធ្វើការផ្សព្វផ្សាយ ពង្រឹង និងពង្រីកសហគមន៍ឥណទាននេះ។ សមាជិកក្រុមប្រឹក្សាមួយរូបត្រូវបានជ្រើសរើសជាប្រធានក្រុមប្រឹក្សាភិបាលនេះ មានសមាជិកក្រុមប្រឹក្សាមួយរូបជាប្រធានសហគមន៍ឥណទាន។ ទន្ទឹមនឹងនេះ ក្រុមប្រឹក្សាឃុំបន្តផ្តល់ការគាំទ្រជាប្រចាំដល់សហគមន៍ឥណទាននេះ ក្នុងការផ្សព្វផ្សាយ ការសម្រួលផ្តល់លិខិតស្នាមចាំបាច់នានាសម្រាប់ស្នើសុំខ្ចីប្រាក់ ការសម្របសម្រួលវិវាទ ក៏ដូចជាបន្តស្វែងរកការគាំទ្រក្នុងការអភិវឌ្ឍន៍សមត្ថភាពជាប្រចាំ និងពិភាក្សាដោះស្រាយបញ្ហានានានៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាឃុំ។ ការរៀបចំឡើងវិញសហគមន៍ឥណទាន មិនមានតម្រូវការថវិកាច្រើនឡើយ ដោយសារកិច្ចការភាគច្រើនជាការងារសម្របសម្រួល ការកៀរគរ ការផ្សព្វផ្សាយ ដោយផ្អែកទៅលើការតាំងចិត្ត និងស្ម័គ្រចិត្តរបស់អ្នកពាក់ព័ន្ធ។ ជាលទ្ធផលសហគមន៍ឥណទានត្រូវបានចងក្រងឡើងវិញ និងបង្កើនសមាជិកពីមួយថ្ងៃទៅមួយថ្ងៃ ព្រមទាំងបានចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន តាមរយៈការផ្តល់នូវសេវាប្រាក់សន្សំ និងប្រាក់កម្ចីដែលមានលក្ខណៈងាយស្រួល ឆាប់រហ័ស និងអត្រាការប្រាក់ប្រកួតប្រជែងដល់ប្រជាពលរដ្ឋនៅក្នុងឃុំ ជាពិសេសដល់សមាជិកក្រុមសន្សំប្រាក់ និងតាមរយៈការប្រើប្រាស់ប្រាក់ចំណេញមួយចំណែកសម្រាប់ជួយដល់ជនចាស់ជរា ស្ត្រីមេម៉ាយ កុមារក្រីក្រ និងកសាងហេដ្ឋារចនាសម្ព័ន្ធនានានៅក្នុងឃុំ។ ជាក់ស្តែងក្រុមសន្សំប្រាក់បានពង្រីកដើមទុនពីប្រមាណ១លានរៀល ក្នុងឆ្នាំ ២០០៣ ទៅ១០៣៩លានរៀលនាពេលបច្ចុប្បន្ន និងមានសមាជិកកើនពី៧០រូប ដល់១៣៥៦រូប។

ទន្ទឹមនឹងនេះដែរសហគមន៍ឥណទាននេះ ធ្លាប់ទទួលបានពានរង្វាន់លេខ០៣ នៅក្នុងការប្រកួតប្រជែងគម្រោងឃុំសង្កាត់ថ្នាក់ជាតិកាលពីឆ្នាំ២០០៨។

## ៣. បទពិសោធន៍ និងបញ្ហាប្រឈម

តាមរយៈការអនុវត្តមុខងារនេះ ក្រុមប្រឹក្សាឃុំ និងអ្នកពាក់ព័ន្ធនានាបានទទួលបទពិសោធន៍មួយចំនួនដូចជា៖ (១). ក្រុមប្រឹក្សាឃុំ និងអ្នកពាក់ព័ន្ធនានា បានយល់ដឹងអំពីវិធានការដាក់ស្តែងក្នុងការលើកកម្ពស់មានការចូលរួម ការរៀបចំផែនការ គោលការណ៍ លក្ខន្តិកៈ និងរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់ (២). ក្រុមគ្រប់គ្រងគម្រោងទទួលបានការយល់ដឹងអំពីចក្ខុវិស័យវែងឆ្ងាយ សុចរិតភាព តម្លាភាព គណនេយ្យភាព ក្នុងការបង្កើនទំនុកចិត្តពីប្រជាពលរដ្ឋ (៣). ក្រុមប្រឹក្សាឃុំបានយល់ដឹងអំពីកិច្ចការតាមដានត្រួតពិនិត្យការអនុវត្តការងារ និងការអភិវឌ្ឍសមត្ថភាពជាប្រចាំ (៤). ក្រុមគ្រប់គ្រងសហគមន៍ឥណទានបានយល់ដឹងអំពីការផ្តល់សេវាដែលមានភាពងាយស្រួលឆាប់រហ័ស បត់បែន និងការប្រកួតប្រជែង ព្រមទាំងយល់ដឹងអំពីរបៀបទាក់ទាញការគាំទ្រ និងបង្កើនជំនឿទុកចិត្តតាមរយៈការបែងចែកនូវផលប្រយោជន៍ដល់សមាជិក និងចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន (៥). សមាជិកសហគមន៍បានយល់ដឹងអំពីការធ្វើការរួមគ្នា និងការបង្កើនសាមគ្គីភាពគ្នានៅមូលដ្ឋាន។

ទោះបីជាសហគមន៍ឥណទាននេះទទួលបានជោគជ័យក៏ដោយ ប៉ុន្តែក៏នៅមានបញ្ហាប្រឈមមួយចំនួនដូចជា (១). ជួបហានិភ័យដោយសារប្រជាពលរដ្ឋមួយចំនួនពុំមានលទ្ធភាព ឬពុំព្រមសងប្រាក់ដែលខ្ចីពីសហគមន៍ និង(២). ការខ្ចីប្រាក់សម្រាប់ប្រកបមុខរបរខ្លះប្រឈមការខាតបង់ (៣). ការយល់ដឹងរបស់ប្រជាពលរដ្ឋមានកម្រិត (ការពិនិត្យលើលិខិតស្នាម របៀបនៃការប្រមូលប្រាក់ ឬសេវាការប្រាក់ជាដើម)។

## ៤. សក្តានុពលក្នុងការពង្រីកការអនុវត្តទៅទីកន្លែងផ្សេងទៀត

មុខងារនេះមានសក្តានុពលអាចអនុវត្តបានគ្រប់មូលដ្ឋានជាពិសេសតំបន់ជនបទ ដែលកំពុងមានគម្រោងឥណទាន ហើយត្រូវការការគាំទ្រ ការសម្របសម្រួលពីរដ្ឋបាលឃុំ សង្កាត់។ រដ្ឋបាលឃុំសង្កាត់អាចចូលរួមយោបល់ និងបំពេញតួនាទីជាក្រុមប្រឹក្សាភិបាល ចូលរួមជំរុញ លើកកម្ពស់ការចូលរួម និងតាមដានពិនិត្យក្នុងការរៀបចំចងក្រង និងដំណើរការសហគមន៍ឥណទានដោយត្រូវពិចារណាឱ្យមានអ្នកគ្រប់គ្រងដែលមានសុចរិតភាព តម្លាភាព និងទទួលបានការជឿជាក់ពីប្រជាពលរដ្ឋ មានផែនការ និងចក្ខុវិស័យវែងឆ្ងាយ មានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់សាល់ ការសហការដោះស្រាយបញ្ហា ការអភិវឌ្ឍសមត្ថភាព និងការតាមដាន ត្រួតពិនិត្យ និងគាំទ្រជាប្រចាំ។


<u>ព័ត៌មានទំនាក់ទំនង</u>

- **មេឃុំ ៖ លោក យឹម យ៉ន**
- **លេខទូរស័ព្ទ៖ ០១២ ៧២៥ ២៤៧**

# ២២. រៀបចំមត្តេយ្យសិក្សាសហគមន៍

# នៅឃុំកន្ទ្រាំង ស្រុកប្រាសាទបាគង ខេត្តសៀមរាប

## ១. សង្ខេបអំពីស្ថានភាពបញ្ហា



ឃុំកន្ទ្រាំងជាឃុំមួយស្ថិតនៅក្នុងស្រុកប្រាសាទបាគង មានភូមិចំនួន០៨ និងមានប្រជាពលរដ្ឋប្រមាណ ១០.០៩៤ នាក់ នៅក្នុងឃុំមានមត្តេយ្យសិក្សារដ្ឋចំនួន០៦ ប៉ុន្តែមិនអាចរ៉ាប់រងបាននូវចំនួនកុមារដែលចេះតែកើនឡើងជារៀងរាល់ឆ្នាំ។ ដោយឡែកកុមារនៅក្នុងភូមិអង្គ្រង ត្រូវធ្វើដំណើរឆ្ងាយទៅសាលារៀន ឆ្លងកាត់ផ្លូវមមាញឹកច្រើននៅតាមផ្លូវជាតិលេខ០៦ និងទីប្រជុំជន ដែលបានបណ្ដាលឱ្យមានគ្រោះថ្នាក់ជាញឹកញាប់។ ដោយមើលឃើញបញ្ហាដូច្នេះប្រជាពលរដ្ឋក៏បានលើកឡើងនូវបញ្ហាដាក់ជូនក្រុមប្រឹក្សាឃុំ ដើម្បីមានវិធានការដោះស្រាយ។ ក្រោយពីទទួលបានសំណូមពររបស់ប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំក៏បានលើកយកបញ្ហានេះមកដាក់ចូលក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ ដើម្បីពិនិត្យ និងបានសម្រេចយកជាបញ្ហាអាទិភាពក្នុងចំណោមបញ្ហាជាច្រើនដើម្បីធ្វើការដោះស្រាយ។ ការសម្រេចអំពីតម្រូវការអាទិភាពនៅមូលដ្ឋាន គឺស្របនឹងគោលនយោបាយកំណត់របស់ថ្នាក់ជាតិ ឱ្យក្រុមប្រឹក្សាឃុំរៀបចំឱ្យមានមត្តេយ្យសិក្សាសហគន៍ និងជាតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋនៅក្នុងភូមិអង្គ្រង ហេតុដូច្នេះក្រុមប្រឹក្សាឃុំបានសម្រេចបង្កើតមត្តេយ្យសិក្សាសហគមន៍នេះឡើងក្នុងឆ្នាំ២០១៤។

## ២. ដំណើរការអនុវត្ត និងលទ្ធផល

ដោយមើលឃើញបញ្ហាខាងលើជាបញ្ហាអាទិភាពដែលត្រូវដោះស្រាយ ក្រុមប្រឹក្សាបានសម្រេចបង្កើតគណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍នេះឡើង ដើម្បីសិក្សាអំពីតម្រូវការចាំបាច់នានាក្នុងរៀបចំមត្តេយ្យសិក្សាសហគមន៍ និងបានផ្ដល់យោបល់ឱ្យមេឃុំធ្វើការសម្របសម្រួលអំពីតម្រូវការនៃការបង្កើតមត្តេយ្យសិក្សាសហគមន៍ និងបានអនុម័តយកបញ្ហានេះដាក់ចូលក្នុងកម្មវិធីវិនិយោគបីឆ្នាំរបស់ឃុំ។

អនុវត្តតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាឃុំ លោកមេឃុំកន្ទ្រាំងបានរៀបចំបង្កើតគណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍នេះឡើង និងបានដឹកនាំគណៈកម្មការនេះចុះសិក្សាអំពីតម្រូវការរបស់ប្រជាពលរដ្ឋនៅភូមិអង្គ្រងដោយចាត់ឱ្យក្រុមការងារចុះប្រមូលព័ត៌មានផ្ទាល់ជាមួយប្រជាពលរដ្ឋ។ គណៈកម្មការ បានប្រមូលព័ត៌មានជាក់លាក់ដូចជា៖ ចំនួនកុមារអាយុក្រោម០៥ឆ្នាំ ចម្ងាយផ្លូវពីភូមិទៅសាលាមត្តេយ្យសិក្សារដ្ឋ ចំនួនកុមារដែលគ្រោះថ្នាក់ចរាចរដែលធ្វើដំណើរឆ្លងផ្លូវ និងកាត់តាមទីប្រជុំជន និងសំណូមពររបស់ប្រជាពលរដ្ឋ។ ក្រោយពីចុះសិក្សា និងប្រមូលព័ត៌មាន គណៈកម្មការ

បានរាយការណ៍ជូនក្រុមប្រឹក្សាឃុំអំពីតម្រូវការជាក់ស្តែងនៅក្នុងសហគមន៍ ក្រៅពីនេះរដ្ឋបាលឃុំក៏បានធ្វើការទំនាក់ទំនងជាមួយការិយាល័យអប់រំស្រុក មន្ទីរអប់រំខេត្ត អង្គការសង្គមស៊ីវិល អ្នកពាក់ព័ន្ធនានា ស្នើសុំការគាំទ្រការរៀបចំមត្តេយ្យសិក្សាសហគមន៍នេះឱ្យកើតមានឡើង។ តាមរយៈការសម្របសម្រួលរបស់រដ្ឋបាលឃុំ ប្រជាពលរដ្ឋបានចូលរួមថវិកាសម្រាប់ទិញដី និងសាងសង់បន្ទប់មត្តេយ្យសិក្សាសហគមន៍ ដែលមានថវិកាសរុបប្រមាណ១០.០០០ដុល្លារអាមេរិក(បានទិញដីមួយកន្លែងតម្លៃ៦.០០០ដុល្លារ និងបានសាងសង់បន្ទប់រៀនចំនួន០១មានតម្លៃប្រមាណ៤.០០០ដុល្លារ ស្របតាមស្តង់ដារបច្ចេកទេសពីក្រសួងអប់រំ) បានជួយសាងសង់ផ្លូវចូលសាលា និងបានចូលរួមផ្តល់សម្ភារៈផ្សេងៗសម្រាប់សិស្ស ការិយាល័យអប់រំស្រុកផ្តល់ការបណ្តុះបណ្តាលគ្រូស្ម័គ្រចិត្ត សម្ភារៈបច្ចេកទេសសៀវភៅ អង្គការសង្គមស៊ីវិលបានផ្តល់សម្ភារៈសិក្សាដល់សិស្សផងដែរ។ ក្រុមប្រឹក្សាបានអនុម័តយកបញ្ហាការរៀបចំមត្តេយ្យសិក្សាសហគមន៍ដាក់ទៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិល របស់ឃុំ និងបានវិភាជន៍ថវិកាចំនួន ២០០.០០០រៀល សម្រាប់ឧបត្ថម្ភគ្រូមត្តេយ្យសិក្សាសហគមន៍ជារៀងរាល់ខែ។

តាមរយៈការអនុវត្តមុខងារនេះ រដ្ឋបាលឃុំទទួលបានលទ្ធផលមួយចំនួនរួមមានៈបានបញ្ជូនគ្រូមត្តេយ្យចូលរួមវគ្គបណ្តុះបណ្តាលដែលរៀបចំដោយក្រសួងអប់រំបានចំនួន០៦វគ្គ ទទួលស្គាល់ពីក្រសួងអប់រំជាមត្តេយ្យសិក្សាសហគមន៍ស្តង់ដារនៅក្នុងឆ្នាំ២០១៨ហើយមានសិស្សចុះឈ្មោះចូលរៀនផ្លូវការជារៀងរាល់ឆ្នាំចំនួន២៥នាក់។ នៅឆ្នាំ២០១៨នេះ មានសិស្សចុះឈ្មោះចូលរៀនផ្លូវការជារៀងរាល់ឆ្នាំចំនួន២៥នាក់ (ស្រី១៦នាក់) និងមានសិស្សធ្វើចំនួន០៥នាក់។ ការបង្កើតមត្តេយ្យសិក្សាសហគមន៍នេះ បានចូលរួមកាត់បន្ថយគ្រោះថ្នាក់នានាពេលធ្វើដំណើរទៅសាលា រីឯមាតាបិតាសិស្សមានការពេញចិត្ត និងមានពេលវេលាច្រើនក្នុងការប្រកបមុខរបរផ្សេងៗ ។



## ៣. បទពិសោធន៍ និងបញ្ហាប្រឈម

តាមរយៈការអនុវត្តមុខងារនេះ ក្រុមប្រឹក្សាឃុំទទួលបាននូវបទពិសោធន៍មួយចំនួនដូចជាៈ មានការយល់ដឹង និងរបៀបនៃការចាត់អាទិភាពទៅលើបញ្ហាផ្សេងៗដែលកើតមាននៅក្នុងឃុំ ទទួលបានចំណេះដឹងអំពីការរៀបចំផែនការសកម្មភាព ការគ្រោងថវិកាសម្រាប់គាំទ្រមត្តេយ្យសិក្សាសហគមន៍ ចំណេះដឹងអំពីការតាមដាន គាំទ្រផ្សេងដល់ដំណើរការរបស់សាលាមត្តេយ្យ បង្កើនសមត្ថភាពក្នុងការទំនាក់ទំនង និងកៀរគរធនធានដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍនៅមូលដ្ឋាន (គណៈកម្មការបានធ្វើការទំនាក់ទំនងជាមួយប្រជាពលរដ្ឋ ចាស់ព្រឹទ្ធាចារ្យ និងអាជីវករនៅក្នុងសហគមន៍)។ ក្រៅពីនេះ រដ្ឋបាលឃុំ បានទទួលចំណេះដឹងអំពីរបៀបសម្របសម្រួល និងរបៀបធ្វើការងារជាមួយប្រជាពលរដ្ឋ ការឆ្លើយតបតម្រូវការ និងសំណូមពររបស់មូលដ្ឋាន។

ទោះជាយ៉ាងណាក៏ការអនុវត្តមុខងារនេះជួបនូវបញ្ហាលំបាកមួយចំនួន ដោយសារថវិការបស់ឃុំមានចំនួនតិចដែលធ្វើឱ្យប្រាក់ឧបត្ថម្ភមានចំនួនតិចតួចសម្រាប់គ្រូមត្តេយ្យសិក្សាសហគមន៍ មុនពេលមានការគាំទ្រពីក្រសួងអប់រំ មានការផ្លាស់ប្តូរគ្រូស្ម័គ្រចិត្តញឹកញាប់ ហើយមានការលំបាកស្វែងរកគ្រូដែលមានសមត្ថភាព និងមានបទពិសោធន៍ ចំនួនកុមារកើនឡើងជារៀងរាល់ឆ្នាំ ដែលឃុំខ្វះធនធាន និងទីតាំងសម្រាប់បង្កើតមត្តេយ្យសិក្សាសហគមន៍ថ្មីទៀតតាមសំណូមពរ។

## ៤. សក្តានុពលក្នុងការពង្រីកការអនុវត្តទៅទីកន្លែងផ្សេងទៀត

ការរៀបចំឱ្យមានមត្តេយ្យសិក្សាសហគមន៍នៅឃុំកន្ទ្រាំងនេះ គឺជាមេរៀនបទពិសោធន៍ល្អសម្រាប់រដ្ឋបាលឃុំ សង្កាត់ដទៃទៀតយកទៅអនុវត្តបន្ត ដោយត្រូវពិចារណាលើបញ្ហាមួយចំនួនដើម្បីទទួលបានជោគជ័យ ដូចជាការរៀបចំឱ្យមានគណៈកម្មការគ្រប់គ្រងមត្តេយ្យ ត្រូវគ្រោងថវិកាសមស្របសម្រាប់ឧបត្ថម្ភដល់គ្រូមត្តេយ្យ ត្រូវត្រៀមសម្ភារៈបំពាក់ឱ្យសាលា ត្រូវត្រៀមដីសម្រាប់សាងសង់បន្ទប់សិក្សា និងត្រូវជ្រើសរើសគ្រូដែលមានចំណេះដឹង និងបទពិសោធន៍សមស្រប៕

<u>ព័ត៌មានទំនាក់ទំនង</u>

- **ជំទប់ទី១ឃុំកន្ទ្រាំង៖ លោកស្រី ជួះ ធីតា**
- **លេខទូរស័ព្ទ៖ ០៩២ ៩៤៦៦៤៨**

# ២៣. សហគមន៍ទេសចរណ៍ធម្មជាតិ
# នៅឃុំខ្នារពោធិ៍ ស្រុកសូទ្រនិគម ខេត្តសៀមរាប

## ១. សង្ខេបអំពីស្ថានភាពបញ្ហា


សហគមន៍

ស្រុកសូទ្រនិគមជាស្រុកមួយក្នុងចំណោមក្រុង ស្រុកទាំង១២ របស់ខេត្តសៀមរាប។ សកម្មភាពសេដ្ឋកិច្ចរបស់ស្រុកពឹងផ្អែកទៅលើវិស័យកសិកម្ម និងការលក់ដូរ សេវាកម្មទេសចរណ៍ ព្រោះស្រុកមានសក្តានុពលទេសចរណ៍ ដោយសារស្រុកសូទ្រនិគមមានព្រំប្រទល់ជាប់ស្រុកបន្ទាយស្រី ស្រុកប្រាសាទបាគង និងស្រុកស្វាយលើដែលសម្បូរទៅដោយប្រាសាទបុរាណ។ ឃុំខ្នារពោធិ៍មានភូមិចំនួន០៨ ជាឃុំមួយក្នុងចំណោមឃុំទាំង១០នៃស្រុកសូទ្រនិគម មានសក្តានុពលវិស័យទេសចរណ៍ដូចជា នៅជិតនឹងប្រាសាទបន្ទាយអំពិល ប្រាសាទបន្ទាយស្រី ភ្នំគូលេន និងជិតទំនប់ការពារមេត្រីពូជជប់រំដេង និងតំបន់ដីសើមដែលមានព្រៃសហគមន៍ចំនួន១.០២២ហិតា។ កត្តាទាំងអស់នេះហើយដែលធ្វើឱ្យមានការចាប់អារម្មណ៍យ៉ាងខ្លាំងពីអ្នកទេសចរ ជាពិសេសក្រុមហ៊ុនទេសចរណ៍ដែលកំពុងប្រតិបត្តិការនៅក្នុងខេត្តសៀមរាប។ នៅក្នុងឆ្នាំ២០១២ កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន (REDIII-GIZ) បានសហការជាមួយរដ្ឋបាលស្រុកសូទ្រនិគម អនុវត្តគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋានផ្អែកលើសក្តានុពលរបស់ស្រុក។ ដោយការសហការ និងគាំទ្រពី (REDIII-GIZ) រដ្ឋបាលស្រុកបានបង្កើតក្រុមការងារ ដើម្បីគាំទ្រក្នុងការអនុវត្តគម្រោង និងបានចុះធ្វើការសិក្សាអំពីតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋនៅតាមបណ្តាឃុំនានា ដោយបានទទួលសំណូមពររបស់ប្រជាពលរដ្ឋនៅភូមិជប់ ឃុំខ្នារពោធិ៍ ក្នុងការផ្តល់សេវាវិស័យទេសចរណ៍ តាមរយៈការបង្កើតជាសហគមន៍ទេសចរណ៍ធម្មជាតិ។ ការបង្កើតជាសហគមន៍ទេសចរណ៍ធម្មជាតិ គឺដើម្បីជួយអភិរក្សធនធានធម្មជាតិផង និងដើម្បីលើកកម្ពស់ប្រាក់ចំណូលគ្រួសារចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅមូលដ្ឋានផង ក្រុមប្រឹក្សាស្រុកបានសម្រេចយកបញ្ហានេះជាអាទិភាព និងបានចាប់ផ្តើមអនុវត្តចាប់ពីឆ្នាំ២០១៣។

## ២. ដំណើរការអនុវត្ត និងលទ្ធផល

ក្រុមប្រឹក្សាស្រុក បានណែនាំគណៈអភិបាលបង្កើតក្រុមការងារទទួលបន្ទុកជួយរៀបចំតំបន់ទេសចរណ៍ធម្មជាតិខ្នារពោធិ៍ និងបានអនុម័តដាក់បញ្ចូលការបង្កើតតំបន់ទេសចរណ៍ទៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរបស់ស្រុក។ ក្រុមការងារនេះមានសមាសភាពចំនួន០៦រូប ដឹកនាំដោយអភិបាលស្រុក និងមានសមាជិកមកពីក្រុមប្រឹក្សាចំនួន០២រូប ប្រធានការិយាល័យផែនការ និងគាំទ្រឃុំសង្កាត់ អនុប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ និងប្រធានការិយាល័យកសិកម្មស្រុក។ ក្រុមការងារមានតួនាទីចុះប្រមូលព័ត៌មានអំពីតម្រូវការនៃការបង្កើតសហគមន៍ រៀបចំផែនការសកម្មភាពនិងថវិកា កំណត់ពេលវេលានៃការអនុវត្តគម្រោង និងធ្វើកិច្ចការចាំបាច់នានាតាមតម្រូវការរបស់គណៈអភិបាល។ ចំណែកក្រុមប្រឹក្សាឃុំមានតួនាទីសម្របសម្រួលជាមួយប្រជាពលរដ្ឋ ក្នុងការចូលរួមកិច្ចប្រជុំនានារបស់ក្រុមការងារ

និងសហការក្នុងការអនុវត្តគម្រោង  រីឯមន្ទីរទេសចរណ៍ខេត្តមានតួនាទីជួយដល់ក្រុមប្រឹក្សាស្រុកក្នុងការរៀបចំចងក្រងសហគមន៍ ការបណ្តុះបណ្តាលការងារបដិសណ្ឋារកិច្ច ការចម្អិនអាហារ និងការបណ្តុះការបណ្តាលភាសាអង់គ្លេសដល់សហគមន៍។

អង្គការ (REDIII-GIZ) បានដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំតំបន់ទេសចរណ៍ខ្នារពោធិ៍នេះ ដោយបានផ្តល់ជាបច្ចេកទេសដល់ក្រុមការងារ ផ្តល់ថវិកាក្នុងការអនុវត្តគម្រោងដែលមានកញ្ចប់ថវិកាចំនួន ៩.៧២១ដុល្លារអាមេរិក ជួយសម្របសម្រួលការអនុវត្តគម្រោង ជួយអភិវឌ្ឍន៍សមត្ថភាពក្រុមការងារគាំទ្រអនុវត្តគម្រោងរបស់ស្រុក និងបានជួយគាំទ្រដល់ដំណើរទស្សនកិច្ចសិក្សារបស់អភិបាល និងសមាជិកក្រុមប្រឹក្សាស្រុកមួយរូបអំពីការអភិវឌ្ឍសេដ្ឋកិច្ចតំបន់នៅសាធារណៈរដ្ឋសហព័ន្ធអាល្លឺម៉ង់។ ក្នុងការបង្កើតសហគមន៍ទេសចរណ៍ខ្នារពោធិ៍ រដ្ឋបាលស្រុកបានចូលរួមជាបដិភាគថវិកាជាមួយអង្គការ (REDIII-GIZ) ចំនួន១៥%។


ផ្ទះស្នាក់

រដ្ឋបាលស្រុក បានជួយសម្របសម្រួលក្នុងការបង្កើតគណៈកម្មការគ្រប់គ្រងសហគមន៍ រួមមានសមាសភាពចំនួន០៨រូប ដែលដឹកនាំដោយប្រធាន អនុប្រធាន ០១រូប ហិរញ្ញិក០១ រដ្ឋបាល០១រូប អ្នកនាំភ្ញៀវចំនួន០២ រូប អ្នកអភិរក្សព្រៃឈើ០១រូប និងចុងភៅមួយ០១រូប។ គណៈកម្មការគ្រប់គ្រងសហគមន៍ មានតួនាទីកំណត់កម្រៃសេវាសម្រាប់ភ្ញៀវទេសចរ រៀបចំក្រុមផ្ទះស្នាក់នៅ រៀបចំក្រុមរទេះគោ រៀបចំក្រុមធ្វើអំបោស រៀបចំក្រុមត្បាល់ក្បឿង និងត្បាល់កិនស្រូវសម្រាប់ភ្ញៀវទេសចរទស្សនា រៀបចំក្រុមចម្អិនម្ហូបអាហារ អប់រំប្រជាពលរដ្ឋអំពីអនាម័យ និងបរិស្ថាននៅជុំវិញផ្ទះ រៀបចំវេនភ្ញៀវដាក់តាមផ្ទះស្នាក់នៅ និងធ្វើការទំនាក់ទំនងជាមួយក្រុមហ៊ុនទេសចរណ៍។


ក្រុមរទេះគោ


រោងសហគមន៍

តាមរយៈការអនុវត្តមុខងារនេះ ក្រុមប្រឹក្សាស្រុកទទួលបាននូវលទ្ធផលមួយចំនួន៖ បច្ចុប្បន្នសហគមន៍មានផ្ទះស្នាក់ចំនួន១៥ រទេះគោដឹកភ្ញៀវទេសចរចំនួន ១៨ ក្រុមត្បាញអំបោស ត្បាល់ក្បឿង និងត្បាល់កិនស្រូវចំនួនមួយ ក្រុមចម្អិនអាហារមានចំនួន៥៨ផ្ទះ បានជួលគ្រូបង្រៀនភាសាអង់គ្លេស បង្រៀនដល់ប្រជាពលរដ្ឋក្នុងសហគមន៍បានមួយថ្នាក់ បានសង់រោងទទួលទានអាហារសម្រាប់ភ្ញៀវចំនួន០១ សាង់សង់រោងសហគមន៍ចំនួន ០១ បានសាងសង់បន្ទប់រៀនភាសាអង់គ្លេសចំនួន០១ ប្រជាពលរដ្ឋបានយល់ដឹងអំពីអនាម័យ និងបរិស្ថាន និងការរៀបចំបង្គន់អនាម័យនៅតាមផ្ទះប្រជាពលរដ្ឋមានចំណេះដឹងផ្នែកបដិសណ្ឋារកិច្ច និងការចំអិនចំណីអាហារ ជីវភាពរបស់ពួកគាត់មានការកើនឡើងជាលំដាប់។ កម្រៃបានពីសេវាទេសចរណ៍ សហគមន៍បានជួយដល់គ្រួសារដែលមានសមាជិកស្លាប់ចំនួន១០០.០០០ រៀល/១គ្រួសារ ជួយជួសជុលរបងសាលារៀន ជួយសម្ភារៈដល់

មណ្ឌលសុខភាព ជួយជាសម្ភារៈដល់សាលាមត្តេយ្យសិក្សាសហគមន៍ បានសាងសង់ផ្ទះគ្រូដែលមានទីលំនៅឆ្ងាយពីសាលារៀនមួយផ្ទះ សន្តិសុខ និងសុវត្ថិភាពរបស់ភ្ញៀវទេសចរត្រូវបានធានា តាមរយៈការចូលរួមយ៉ាងសកម្មរបស់ប្រជាពលរដ្ឋ ប្រជាការពារ និងប៉ុស្តិ៍នគរបាលរដ្ឋបាល។

## ៣. បទពិសោធន៍ និងបញ្ហាប្រឈម

តាមរយៈការអនុវត្តមុខងារនេះ រដ្ឋបាលស្រុកទទួលបាននូវបទពិសោធន៍មួយចំនួនដូចជា៖ សមត្ថភាពយល់ដឹងរបស់រដ្ឋបាលស្រុក អំពីការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានបានប្រសើរជាងមុន មានសមត្ថភាពក្នុងការទំនាក់ទំនងរវាងអង្គភាពជំនាញ ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលបានល្អជាងមុន។ ប្រជាពលរដ្ឋ កាន់តែមានការយល់ដឹងអំពីរបៀបទាក់ទាញភ្ញៀវទេសចរណ៍ដូចជាការងារបដិសណ្ឋារកិច្ច និងអនាម័យបរិស្ថានជុំវិញផ្ទះ ប្រជាពលរដ្ឋមានគំនិតអាជីវកម្មល្អជាងមុន។ សហគមន៍ទទួលបានបទពិសោធន៍ក្នុងការរៀបចំចាត់ចែង និងអនុវត្តគម្រោង ប្រជាពលរដ្ឋមានជីវភាពធូរជារ និងមានទំនុកចិត្តទៅលើអាជ្ញាធរមូលដ្ឋាន សមត្ថភាពរបស់សហគមន៍ក្នុងការធ្វើទំនាក់ទំនងជាមួយក្រុមហ៊ុនទេសចរណ៍នានា និងមានសមត្ថភាពទាក់ទាញភ្ញៀវទេសចរឱ្យមកកំសាន្ត និងការរៀបចំផែនការអាជីវកម្មត្រូវបានកែលម្អ សហគមន៍ត្រូវបានផ្សព្វផ្សាយទៅកាន់ពិភពលោកតាមរយៈក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរ និងតាមរយៈវេបសាយរបស់សហគមន៍។

ទោះជាយ៉ាងណាក៏នៅមានបញ្ហាប្រឈមមួយចំនួនដូចជា៖ ប្រជាពលរដ្ឋមួយចំនួននៅតែគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួនជាជាងផលប្រយោជន៍សហគមន៍ ដែលបណ្តាលឱ្យមានទំនាស់ផលប្រយោជន៍ជាញឹកញាប់ នៅតែមានការកាប់បំផ្លាញព្រៃឈើរបស់សហគមន៍ពីសំណាក់ប្រជាពលរដ្ឋមួយចំនួន។ ថ្វីត្បិតតែសហគមន៍បានបង្កើតឡើងតាំងពីឆ្នាំ២០១៣ តែសហគមន៍មិនទាន់បានចុះបញ្ជីជាផ្លូវការនៅឡើយ និងមានការលំបាកក្នុងការគ្រប់គ្រងថវិការបស់សហគមន៍។

## ៤. សក្តានុពលក្នុងការពង្រីកការអនុវត្តទៅទីកន្លែងផ្សេងទៀត

ការរៀបចំឱ្យមានតំបន់ទេសចរណ៍ធម្មជាតិនេះ រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសក្តានុពលទេសចរណ៍និងមានបំណងចងក្រងសហគមន៍ទេសចរណ៍ ត្រូវពិចារណាលើបញ្ហាមួយចំនួនដូចជា៖ ត្រូវមានទីតាំងភូមិសាស្ត្រធម្មជាតិអំណោយផលល្អដែលអាចទាក់ទាញភ្ញៀវ ត្រូវរៀបចំឱ្យមានគណៈកម្មការគ្រប់គ្រងគម្រោង ត្រូវគ្រោងថវិកាសមស្របសម្រាប់រៀបចំអនុវត្តគម្រោង ត្រូវកំណត់ទីតាំងដែលមានសក្តានុពលអាចទាក់ទាញភ្ញៀវទេសចរ ត្រូវមានការគាំទ្រពីអង្គភាពជំនាញទេសចរណ៍ក្នុងការជួយរៀបចំផែនការច្បាស់លាស់ និងមានប្លង់មេសម្រាប់អភិវឌ្ឍវិស័យទេសចរណ៍ក្នុងតំបន់មូលដ្ឋាន ត្រូវមានការតាំងចិត្តខ្ពស់ក្នុងការកៀរគរធនធាន សម្ភារៈ ថវិកា និងការគាំទ្រផ្សេងៗ ត្រូវមានទំនាក់ទំនងល្អជាក្រុមហ៊ុនទេសចរណ៍ ពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអនុវត្ត អាជ្ញាធរមូលដ្ឋាន និងគណៈកម្មការគ្រប់គ្រងសហគមន៍ត្រូវមានការតាំងចិត្តក្នុងការសម្របសម្រួល និងដោះស្រាយទំនាស់ដែលកើតមានឡើងសម្រាប់ជាប្រយោជន៍ប្រជាពលរដ្ឋ និងសហគមន៍៕

**<u>ព័ត៌មានទំនាក់ទំនង</u>**

- **អភិបាលស្រុក៖ ម៉ក់ ប្រុស លេខទូរស័ព្ទ៖ ០៩៥ ៨០០៨៨៣**
- **ប្រធានសហគមន៍៖ ស្មើ សុខុយ លេខទូរស័ព្ទ៖ ០៨៩ ២៣៥៤២៨**

# ២៤. ជីកស្រះយកទឹកសម្រាប់សហគមន៍
# ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

## ១. សង្ខេបអំពីស្ថានភាពបញ្ហា

ស្រុកត្រពាំងប្រាសាទជាស្រុកមួយស្ថិតក្នុងតំបន់ខ្ពង់រាបភាគពាយ័ព្យនៃប្រទេសកម្ពុជា។ ពេលរដូវប្រាំងប្រជាពលរដ្ឋតែងជួបគ្រោះរាំងស្ងួត ពិសេសខ្វះទឹកប្រើប្រាស់នៅតាមគ្រួសារ។ ដោយសារស្រុកស្ថិតនៅតំបន់ខ្ពង់រាបធ្វើឱ្យមានការលំបាកក្នុងការជីកអណ្តូងស្នប់ ឬអណ្តូងលូដើម្បីយកទឹក ឬត្រូវជីកអណ្តូងស្នប់ដែលមានជម្រៅជ្រៅ ហើយគុណភាពទឹកទៀតសោតសម្បូរទៅដោយសារជាតុកំបោរ និងរ៉ែផ្សេងៗមិនអាចប្រើប្រាស់បាន។ ដោយមានសំណូមពររបស់ប្រជាពលរដ្ឋនៅទីប្រជុំជនស្រុកតាមរយៈការចូលរួមក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាស្រុក និងពិនិត្យឃើញថាបញ្ហាខ្វះទឹកប្រើប្រាស់ជាបញ្ហាអាទិភាព រដ្ឋបាលស្រុកត្រពាំងប្រាសាទបានសម្រេចយកបញ្ហាខ្វះទឹកប្រើប្រាស់ជាតម្រូវការអាទិភាពដែលត្រូវដោះស្រាយជូនប្រជាពលរដ្ឋ ហើយគម្រោងនេះក៏បានចាប់ផ្តើមអនុវត្តចាប់ពីឆ្នាំ២០១៨កន្លងមក។ គម្រោងនេះ រួមមាន ជីកស្រះទឹក សាងសង់ទំនប់បង្ហៀរ។

## ២. ដំណើរការអនុវត្ត និងលទ្ធផល

ដោយសារបញ្ហាខ្វះទឹកប្រើប្រាស់ ជាបញ្ហាអាទិភាពក្រុមប្រឹក្សាស្រុកបានសម្រេចដាក់បញ្ចូលទៅក្នុងកម្មវិធីវិនិយោគរបស់ស្រុក សម្រាប់អនុវត្តគម្រោងដោយប្រើប្រាស់មូលនិធិអភិវឌ្ឍន៍ស្រុកក្នុងឆ្នាំ២០១៨។ ក្រុមប្រឹក្សាស្រុក បានសម្រេចបង្កើតក្រុមការងារមួយដែលដឹកនាំដោយ អភិបាលរងម្នាក់ និងមានការចូលរួមពីសមាជិកក្រុមប្រឹក្សា នាយករដ្ឋបាល មន្រ្តីការិយាល័យជំនាញជុំវិញស្រុក។ ក្រុមការងារនេះមានតួនាទីក្នុងការសម្របសម្រួលជាមួយប្រជាពលរដ្ឋ អាជីវករ និងស្វះស្វែងរកក្រុមហ៊ុនឯកជនជួយគាំទ្រគម្រោងនេះ ដោយសារតម្លៃគម្រោងស្រះទឹក និងទំនប់បង្ហៀរមានចំនួនលើសមូលនិធិអភិវឌ្ឍន៍ស្រុក។ តាមរយៈការសម្របសម្រួលរបស់រដ្ឋបាលស្រុក មានក្រុមហ៊ុនចំនួន០២បានយល់ព្រមជួយជីកស្រះទឹកចំនួន២ ហើយក្រុមហ៊ុនស្នើសុំដីកអាចម៍ដីសម្រាប់លក់ ឬប្រើប្រាស់តាមតម្រូវការរបស់ក្រុមហ៊ុន រីឯមូលនិធិស្រុកចំណាយលើការសាងសង់ទំនប់បង្ហៀរដោយអនុវត្តតាមនីតិវិធីលទ្ធកម្មកំណត់។

តាមរយៈការអនុវត្តគម្រោងនេះរដ្ឋបាលស្រុកទទួលបាននូវសមិទ្ធផលមួយចំនួនដូចជា៖ (១). ជីកបានស្រះចំនួន០២ ស្រះទីមួយមានទំហំ២០០ម៉ែត្រគុណ២០០ម៉ែត្រ និងស្រះទី២មានទំហំ២០០ម៉ែត្រ គុណ៤២០ម៉ែត្រ (២). បានធ្វើទំនប់បង្ហៀទឹកចំនួន០១ ដើម្បីយកទឹកបញ្ចូលស្រះទាំងពីរដោយចំណាយថវិកាអស់១៤២.០០០.០០០រៀល ហើយទំនប់បង្ហៀរ១ទៀតគ្រោងនឹងអនុវត្តនៅឆ្នាំ២០២០។ ស្រះទឹកទាំងពីរអាចមានសមត្ថភាពផ្គត់ផ្គង់ទឹកជូនប្រជាពលរដ្ឋនៅទីប្រជុំជនស្រុកត្រពាំងប្រាសាទបានរយៈពេល០៥ឆ្នាំ។ ជារួម ប្រជាពលរដ្ឋមានការពេញចិត្តចំពោះរដ្ឋបាលស្រុកដែលបានយកចិត្តទុកដាក់ឆ្លើយតបចំពោះតម្រូវការជាអាទិភាពរបស់ពួកគាត់។

## ៣. បទពិសោធន៍ និងបញ្ហាប្រឈម

តាមរយៈការអនុវត្តគម្រោងនេះក្រុមប្រឹក្សា និងរដ្ឋបាលស្រុកទទួលបាននូវបទពិសោធន៍មួយចំនួនដូចជា៖ (១). សមត្ថភាព និងការយល់ដឹងកាន់តែប្រសើរអំពីវិធីសាស្ត្រសម្របសម្រួល និងការប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធនានាក្នុងការអនុវត្តគម្រោង (២). មានសមត្ថភាពក្នុងការកៀរគរធនធានដែលធ្វើឱ្យគម្រោងអាចសម្រេចបានជោគជ័យ ពិសេសការលើកកម្ពស់ភាពជាដៃគូជាមួយវិស័យឯកជន (៣). សមត្ថភាពយល់ដឹងអំពីនីតិវិធីនៃការរៀបចំកម្មវិធីវិនិយោគ ការរៀបចំផែនការសកម្មភាព និងថវិកា នីតិវិធីអនុវត្តគម្រោង និងការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍ និងការសម្របសម្រួលដោះស្រាយបញ្ហា ដើម្បីគាំទ្រការអនុវត្តគម្រោងរបស់មន្ត្រីនៃរដ្ឋបាលស្រុកបានកាន់តែប្រសើរ។

ការអនុវត្តគម្រោងនេះ រដ្ឋបាលស្រុកនៅជួបប្រទះបញ្ហាមួយចំនួន៖ (១). ថវិការបស់រដ្ឋបាលស្រុកនៅមានកម្រិតតិចមិនទាន់អាចឆ្លើយតបតាមតម្រូវការជាច្រើនរបស់ប្រជាពលរដ្ឋ (២). ស្រះទឹកមានទំហំធំ ដែលធ្វើឱ្យការថែទាំមិនបានដិតដល់ ប្រជាពលរដ្ឋខ្លះនៅតែបណ្តោយឱ្យគោក្របីស្រុកចុះក្នុងស្រះទឹក ដែលធ្វើឱ្យខូចគុណភាពទឹក និងប៉ះពាល់សុខភាពរបស់ប្រជាពលរដ្ឋ។

## ៤. សក្តានុពលក្នុងការពង្រីកការអនុវត្តទៅទីកន្លែងផ្សេងទៀត

ការអនុវត្តគម្រោងជីកស្រះយកទឹកនេះគឺជាមេរៀនបទពិសោធន៍ល្អ សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដទៃទៀតដែលប្រជាពលរដ្ឋក្នុងមូលដ្ឋាននោះជួបប្រទះស្ថានភាពខ្វះទឹកប្រើប្រាស់ ពិសេសតាមបណ្តាមូលដ្ឋានជនបទដែលពុំមានប្រភពទឹកជាធម្មជាតិ។ គម្រោងបែបនេះ អាចមានលទ្ធភាពច្រើនក្នុងការកៀរគរការចូលរួមរបស់ផ្នែកឯកជនព្រោះក្រុមហ៊ុន ឬអាជីវករដែលប្រកបរបរសំណង់ឬការងារដីអាចមានមធ្យោបាយ និងប្រយោជន៍ច្រើនអំពីការចូលរួមជាដៃគូជាមួយរដ្ឋបាលមូលដ្ឋាន។ ទោះជាយ៉ាងណា រដ្ឋបាលដែលមានបំណងអនុវត្តគម្រោងប្រហាក់ប្រហែលនេះ ត្រូវពិចារណាលើបញ្ហាមួយចំនួនដើម្បីទទួលបានជោគជ័យ៖ (១). ត្រូវរៀបចំឱ្យមានគណៈកម្មការគ្រប់គ្រងគម្រោង និងថែទាំ ប្រើប្រាស់ឱ្យបានត្រឹមត្រូវ ដោយមានការចូលរួមពីរដ្ឋបាលស្រុក និងអ្នកពាក់ព័ន្ធដែលមកពីការិយាល័យជំនាញ និងប្រជាពលរដ្ឋ។ (២). ត្រូវគ្រោងថវិកាសមស្របសម្រាប់អនុវត្តគម្រោងក្នុងករណីដែលមិនអាចស្វែងរកអាជីវករចូលរួមអនុវត្តគម្រោងបាន៕

**<u>ព័ត៌មានទំនាក់ទំនង</u>**

- **នាយករដ្ឋបាលសាលាស្រុក**
- **លេខទូរស័ព្ទ៖ ០៩៧៥៨៦៣៩១៨**

# ២៥. ស្វែងរកទីផ្សារកសិផលជូនប្រជាពលរដ្ឋ
# ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

## ១. សង្ខេបអំពីស្ថានភាពបញ្ហា

ស្រុកត្រពាំងប្រាសាទជាស្រុកមួយស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា ប្រជាពលរដ្ឋភាគច្រើនប្រកបមុខរបរធ្វើដំណាំចំការ ដូចជាចំការដំឡូងមី ស្វាយ និងស្វាយចន្ទី ហើយផលិតផលទាំងនេះភាគច្រើនសម្រាប់នាំចេញទៅលក់នៅប្រទេសថៃ។ រៀងរាល់រដូវប្រមូលផលដំណាំទាំងនេះ ប្រជាកសិករតែងជួបប្រទះបញ្ហាតម្លៃកសិផល ដោយសារឈ្មួញកណ្តាលតែងបន្ទាបតម្លៃជាងទីផ្សារនៅប្រទេសថៃ ដែលធ្វើឱ្យប្រជាកសិករបាត់បង់ប្រាក់ចំណូល កសិករខ្លះត្រូវប្រឈមការបាត់បង់ដើមទុនដោយសារខ្វះទីផ្សារលក់ផលិតផលដែលផលិតបាន នាំឱ្យជីវភាពត្រូវជួបប្រទះការលំបាកផ្សេងៗ។ ដោយមានសំណូមពររបស់ប្រជាពលរដ្ឋក្នុងការដោះស្រាយទីផ្សារកសិផល និងពិនិត្យឃើញស្ថានភាពជាក់ស្តែង រដ្ឋបាលស្រុកត្រពាំងប្រាសាទ បានសម្រេចកំណត់យកការស្វែងរកទីផ្សារផលិតផលជាកិច្ចការអាទិភាព ដែលត្រូវសម្របសម្រួលដោះស្រាយ ពិសេសផ្តោតលើតម្លៃដំឡូងមី ដែលប្រជាពលរដ្ឋផលិតបានច្រើនជាងដំណាំផ្សេងៗទៀត ចំនួនរាប់សែនតោនក្នុងមួយឆ្នាំៗ។ បង្កើតក្រុមការងារមួយរបស់រដ្ឋបាលស្រុក ដើម្បីធ្វើការស្វះស្វែងរកទីផ្សារ និងធ្វើការពិភាក្សាជាមួយអ្នកពាក់ព័ន្ធអំពីតម្លៃដំឡូងនៅក្នុងស្រុកត្រពាំងប្រាសាទ គម្រោងនេះបានអនុវត្តចាប់ពីឆ្នាំ២០១៧

រហូតមកដល់បច្ចុប្បន្ន។

## ២. ដំណើរការអនុវត្ត និងលទ្ធផល

ដើម្បីដំណើរការកិច្ចការនេះ ក្រុមប្រឹក្សាបានណែនាំគណៈអភិបាលបង្កើតក្រុមការងារអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋានដែលដឹកនាំដោយអភិបាលរង នាយករងរដ្ឋបាល ប្រធានការិយាល័យផែនការ ប្រធានការិយាល័យ អន្តរវិស័យ។ ក្រុមការងារនេះមានតួនាទីក្នុងការសម្របសម្រួលជាមួយប្រជាពលរដ្ឋ អាជីវករប្រមូលទិញកសិផល និងពិភាក្សាជាមួយភាគីអ្នកនាំចេញដើម្បីសម្របសម្រួលជួយស្វែងរកទីផ្សារជូនប្រជាពលរដ្ឋនៅក្នុងស្រុកត្រពាំងប្រាសាទ ដោយបានជួបពិភាក្សាជាមួយអាជីវករប្រមូលទិញដំឡូងមី និងកសិករ ដើម្បីពិភាក្សាពេលវេលាប្រមូល គុណភាព តម្លៃដំឡូងមី និងចងក្រងសហគមន៍ដំឡូងមីប្រចាំស្រុកត្រពាំងប្រាសាទ។

តាមរយៈការអនុវត្តគម្រោងនេះរដ្ឋបាលស្រុកទទួលបាននូវសមិទ្ធផលមួយចំនួនដូចជា៖ (១). បានបង្កើតសហគមន៍ដំឡូងមីប្រចាំស្រុកត្រពាំងប្រាសាទដោយមានអាជីវក និងកសិករចំនួន ១៥៧គ្រួសារជាសមាជិក (២). បានធ្វើការសម្របសម្រួលជាមួយការិយាល័យកសិកម្ម និងសហគមន៍ដំឡូងមីប្រចាំស្រុកធ្វើការបណ្តុះបណ្តាលដល់កសិករអំពីវិធីសាស្ត្រជ្រើសរើសពូជ ការប្រើប្រាស់ជី និងការរៀបចំដី វិធីសាស្ត្រក្នុងការដាំដុះ ដើម្បីទទួលបានផលល្អ (៣). បានធ្វើការសម្របសម្រួលជាមួយ

ក្រុមហ៊ុនពីប្រទេសថៃដោយអនុញ្ញាតឱ្យថយន្តចូលទិញ និងដឹកដំឡូងដល់ស្រុកត្រពាំងប្រាសាទតែម្តងដែលកាត់បន្ថយចំណាយរបស់កសិករ (៤) បានធ្វើការកំណត់តម្លៃដំឡូងស្រស់តម្លៃ២៥០-៣៥០រៀលក្នុងមួយគីឡូសម្រាប់ដំឡូងស្រស់ រីឯដំឡូងស្ងួតតម្លៃពី៤៥០-៧៥០ក្នុងមួយគីឡូក្រាម (៥).ប្រជាពលរដ្ឋមានការពេញចិត្តចំពោះការស្វែងរកទីផ្សារជូនពួកគាត់ (៦). សម្របសម្រួលឱ្យអ្នកប្រមូលទិញផ្តល់តម្លៃដូចគ្នាទោះកសិករមិនមែនសមាជិកសហគមន៍ដំឡូងមីក៏ដោយ។ ជារួមនៅពេលដែលបានតម្លៃសមរម្យតាមទីផ្សារ ប្រជាពលរដ្ឋធ្វើចំណាកស្រុកទៅរកការងារធ្វើនៅបណ្តាស្រុកក្នុងប្រទេសថៃជាប់ព្រំដែនក៏មានការថយចុះដែរ។

**៣. បទពិសោធន៍ និងបញ្ហាប្រឈម**

តាមរយៈការអនុវត្តគម្រោងនេះក្រុមប្រឹក្សា រដ្ឋបាលស្រុក និងអ្នកពាក់ព័ន្ធនានាទទួលបាននូវបទពិសោធន៍មួយចំនួនដូចជា៖ (១). សមត្ថភាព និងការយល់ដឹងអំពីរបៀបរបបសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធនានាកើនឡើង (២) ការយល់ដឹងអំពីការលើកកម្ពស់ភាពជាដៃគូរវាងប្រជាកសិករ អាជីវករអ្នកប្រមូលទិញ និងអ្នកនាំចេញកសិផល (៣). បង្កើនការយល់ដឹង និងសមត្ថភាពជំនាញតាមរយៈវគ្គបណ្តុះបណ្តាលបច្ចេកទេសដាំដុះ ការប្រើប្រាស់ជី ការប្រើប្រាស់ដី និងការជ្រើសរើសពូជ និងអំពីគុណភាពកសិផលសម្រាប់នាំចេញ ៤). សមត្ថភាពកាន់តែកើនឡើងលើការកៀរគរការគាំទ្រ និងការចូលរួមពីខាងក្រៅដើម្បីរួមចំណែកអភិវឌ្ឍស្រុក ៥). ស្វែងយល់កាន់តែប្រសើរអំពីការតាំងចិត្ត ការសម្រសម្រួលប្រកបដោយតម្លាភាព និងភាពបត់បែនតាមស្ថានភាព ពេលវេលា និងផលប្រយោជន៍អ្នកពាក់ព័ន្ធនានា។

ការអនុវត្តគម្រោងនេះ បានជួបប្រទះបញ្ហាមួយចំនួន៖ (១). ថវិកា មធ្យោបាយរបស់រដ្ឋបាលស្រុកមានតិចសម្រាប់គាំទ្រដល់ក្រុមការងារ (២). ប្រជាពលរដ្ឋមិនទាន់យល់ច្បាស់អំពីការពង្រឹងគុណភាពកសិផលឆ្លើយតបនឹងតម្រូវការទីផ្សារ ដោយអនុវត្តបច្ចេកទេសដាំដុះតាមទម្លាប់យល់ដឹងតៗគ្នា (៣). ការលំបាកក្នុងការសម្របសម្រួលជាមួយសមត្ថកិច្ចដទៃទៀតនៅច្រកព្រំដែនដែលស្ថិតនៅក្រៅសមត្ថកិច្ចរបស់រដ្ឋបាលស្រុក។

**៤. សក្តានុពលក្នុងការពង្រីកការអនុវត្តទៅទីកន្លែងផ្សេងទៀត**

គម្រោងប្រហាក់ប្រហែលនេះ អាចអនុវត្តបាននៅតាមមូលដ្ឋានដែលមានសក្តានុពលសម្រាប់ផលិតផលកសិកម្ម ឬផលិតសិប្បកម្មផ្សេងៗដែលមានបរិមាណផលិតច្រើន ពិសេសសម្រាប់នៅតាមតំបន់ដែលនៅជិតព្រំដែនប្រទេសជិតខាង មានសក្តានុពលខ្លាំងនៃការនាំចេញ។ រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានបំណងអនុវត្តគម្រោងប្រហាក់ប្រហែលនេះត្រូវពិចារណាលើបញ្ហាមួយចំនួន៖ (១). ត្រូវរៀបចំឱ្យមានគណៈកម្មការ ឬក្រុមការងារអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋានមួយច្បាស់លាស់ ដើម្បីធ្វើការសិក្សា និងស្វែងយល់ពីតម្រូវការរបស់ប្រជាពលរដ្ឋ និងធ្វើការសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធនានា (២). ត្រូវកញ្ចប់ថវិកាសមស្របសម្រាប់គាំទ្រក្រុមការងារ៕

<u>**ព័ត៌មានទំនាក់ទំនង**</u>

- **នាយករដ្ឋបាលសាលាស្រុក**
- **លេខទូរស័ព្ទ៖ ០៩៧ ៥៨ ៦៣ ៩១៨**

# ២៦. ការលើកកម្ពស់អនាម័យជូនប្រជាពលរដ្ឋ

# សង្កាត់បន្ទាយរាក់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ

## ១. សង្ខេបអំពីស្ថានភាពបញ្ហា

បញ្ហាអនាម័យ និងសុខភាពជាបញ្ហាចម្បងមួយក្នុងចំណោមបញ្ហាសំខាន់ៗរបស់សង្កាត់បន្ទាយរាក់ បញ្ហានេះកើតឡើងដោយសារប្រជាពលរដ្ឋមួយចំនួននៅតែបន្ទោរបង់នៅតាមទីវាល និងគុម្ពោតព្រៃក្បែរៗផ្ទះ ដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់សហគមន៍ ជាពិសេសសុខភាពកុមារ។ ម្យ៉ាងវិញទៀត ដោយសារសង្កាត់បន្ទាយរាក់មានព្រំប្រទល់ជាប់នឹងប្រទេសថៃ និងមានប្រជាពលរដ្ឋចំណាកស្រុកទៅធ្វើការនៅប្រទេសថៃច្រើន ហើយនៅពេលត្រឡប់មកវិញពួកគាត់តែងតែត្អូញត្អែរអំពីបញ្ហាបន្ទោរបង់ពាសវាលពាសកាលរបស់ប្រជាពលរដ្ឋនៅក្នុងសង្កាត់។ ដោយមើលឃើញបញ្ហាខ្វះអនាម័យ ផលប៉ះពាល់សុខភាពសាធារណៈ ព្រមទាំងមានសំណូមពរពីប្រជាពលរដ្ឋ និងដោយមានការគាំទ្រពីអង្គការប្រាកម្ពុជា ក្រុមប្រឹក្សាសង្កាត់បានសម្រេចយក បញ្ហាការលើកកម្ពស់អនាម័យជនបទជាគម្រោងអាទិភាពរបស់ខ្លួន និងចាប់អនុវត្តគម្រោងនេះចាប់ពីឆ្នាំ២០១២ រហូតមកដល់បច្ចុប្បន្ន។

## ២. ដំណើរការអនុវត្ត និងលទ្ធផល

ដោយសារបញ្ហាអនាម័យជនបទ និងកង្វះបង្គន់អនាម័យជាបញ្ហាសំខាន់ដែលធ្វើឱ្យប៉ះពាល់ដល់សុខុមាលភាពរបស់ប្រជាពលរដ្ឋនៅក្នុងសង្កាត់ ក្រុមប្រឹក្សាសង្កាត់បានសម្រេចយកបញ្ហានេះជាបញ្ហាអាទិភាពដែលត្រូវធ្វើការដោះស្រាយបន្ទាន់ ក្នុងនោះក្រុមប្រឹក្សាសង្កាត់បានចាត់ឱ្យគណៈកម្មការទទួលបន្ទុកកិច្ចការនារី និងកុមារសង្កាត់(គ.ក.ន.ក)ទទួលបន្ទុកអនុវត្តគម្រោងនេះ។ ដោយមានការសម្រេចពីក្រុមប្រឹក្សាសង្កាត់ គ.ក.ន.កសង្កាត់ បានចុះធ្វើការប្រមូលទិន្នន័យ ព័ត៌មាន បញ្ហា តម្រូវការរបស់ប្រជាពលរដ្ឋ និងបានធ្វើការស្វែងរកការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាលនានា។ គ.ក.ន.ក បានធ្វើការទំនាក់ទំនងជាមួយអង្គការ**ប្រាកម្ពុជា** ដែលកំពុងអនុវត្តកម្មវិធីរបស់ខ្លួនលើការងារអនាម័យជនបទ និងអង្គការដៃគូចំនួន០២ទៀតគឺ អង្គការកែប្រែសហគមន៍ (CTO) និងអង្គការ CDO ដែលអនុវត្តការងារលើវិស័យកសិកម្ម ក្នុងការរៀបចំផែនការសកម្មភាពលម្អិត និងថវិកាសម្រាប់ការផ្សព្វផ្សាយ និងការផ្ដល់សម្ភារៈក្នុងការរៀបចំបង្គន់តាមផ្ទះ។

តាមរយៈការអនុវត្តគម្រោងនេះ រដ្ឋបាលសង្កាត់ទទួលបាននូវសមិទ្ធផលមួយចំនួនដូចជា៖ ១). បានផ្ដល់សម្ភារៈសាងសង់បង្គន់អនាម័យដល់ប្រជាពលរដ្ឋចំនួន០៨ភូមិ ស្មើនឹង១.៤១៤ខ្នងផ្ទះ ក្នុងនោះគ្រួសារដែលមានអត្តសញ្ញាណប័ណ្ណជនក្រីក្រទទួលបានលូបីកង់ គម្របបង្គន់ចំនួន០១ ចានបង្គន់ចំនួន០១ និងទម្រចានបង្គន់ចំនួន០១ រីឯគ្រួសារដែលគ្មានអត្តសញ្ញាណប័ណ្ណជនក្រីក្រទទួលបានលូចំនួន០៣កង់ និងចានបង្គន់ចំនួន០១។ ២). ផ្ដល់អាងត្រងទឹកភ្លៀងធ្វើពីលូក្នុងមួយភូមិចំនួន ១៥គ្រួសារ ៣). ផ្ដល់ធុងចម្រោះទឹកស្អាតចំនួន១៨គ្រួសារក្នុងមួយភូមិ (ផ្ដល់ឱ្យតែគ្រួសារក្រីក្រ)

៤). បានរៀបចំសួនកុមារ និងអាងលាងដៃនៅសាលាបឋមសិក្សាពោធិវង្ស ៥). បានធ្វើការអប់រំអំពីអនាម័យ និងបរិស្ថានដល់ប្រជាពលរដ្ឋនៅក្នុងសង្កាត់ ៥). បានធ្វើយុទ្ធនាការផ្សព្វផ្សាយអំពីអនាម័យ ការការពារជម្ងឺគ្រុនឈាម ។

## ៣. បទពិសោធន៍ និងបញ្ហាប្រឈម

តាមរយៈការអនុវត្តគម្រោងនេះរដ្ឋបាលសង្កាត់ទទួលបាននូវបទពិសោធន៍មួយចំនួនដូចជា៖ ១). ទទួលបានចំណេះដឹងអំពីការងារទំនាក់ទំនង និងការកៀរគរធនធានក្នុងការអភិវឌ្ឍសង្កាត់ ២). សមត្ថភាពសម្របសម្រួល និងធ្វើការជាមួយសហគមន៍ អង្គការក្រៅរដ្ឋាភិបាល និងប្រជាពលរដ្ឋ មានការកើនឡើង ៣). យល់ដឹងអំពីការធ្វើការជាក្រុម និងភាពជាដៃគូពីអ្នកពាក់ព័ន្ធដែលពិតជាមានសារៈសំខាន់ក្នុងការអភិវឌ្ឍនៅមូលដ្ឋាន ៤). ប្រជាពលរដ្ឋមានជំនឿទុកចិត្តកាន់តែប្រសើរជាងមុនចំពោះក្រុមប្រឹក្សាសង្កាត់ដែលជាអាជ្ញាធរមូលដ្ឋានទទួលការបោះឆ្នោតពីប្រជាពលរដ្ឋ ។

ការអនុវត្តគម្រោងនេះ ក្រុមប្រឹក្សាសង្កាត់ បានជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចជា៖ ១). ប្រជាពលរដ្ឋខ្លះនៅមិនទាន់បោះបង់ទម្លាប់បន្ទោរបង់ក្រៅបង្គន់ ២). ការសាងសង់បង្គន់អនាម័យមានការយឺតយ៉ាវ ៣). ថវិកាសម្រាប់អភិវឌ្ឍរបស់សង្កាត់មានចំនួនតិចតួច មិនអាចឆ្លើយតបនឹងតម្រូវការដ៏ច្រើនរបស់ប្រជាពលរដ្ឋ។

## ៤. សក្តានុពលក្នុងការពង្រីកការអនុវត្តទៅទីកន្លែងផ្សេងទៀត

គម្រោងស្តីពីការលើកកម្ពស់អនាម័យជនបទ អាចអនុវត្តបាននៅតាមរដ្ឋបាលឃុំ សង្កាត់ផ្សេងទៀតនៅតាមតំបន់ជនបទ ដែលប្រជាពលរដ្ឋនៅពុំទាន់យល់ដឹងអំពីប៉ះពាល់នៃការបន្ទោរបង់តាមទីវាល ដោយគ្មានអនាម័យ។ ការអនុវត្តគម្រោងមានលក្ខណៈជាគម្រោងសេវាសង្គម ដែលផ្តោតលើការងារអនាម័យ និងសុខុមាលភាពសាធារណៈត្រូវ៖ (១). មានក្រុមការងារសម្របសម្រួលជាមួយដៃគូពាក់ព័ន្ធលើការគាំទ្រការអនុវត្តគម្រោងសម្រាប់អប់រំផ្សព្វផ្សាយប្រជាពលរដ្ឋអំពីអនាម័យ និងបរិស្ថានឱ្យបានជាប្រចាំ (២). មានប្រជាពលរដ្ឋដែលសកម្មក្នុងសហគមន៍ជាអ្នកជំរុញ និងផ្សព្វផ្សាយបន្តអំពីការលើកកម្ពស់អនាម័យនៅតាមគ្រួសារ ៣). មានការចូលរួមបដិភាគរបស់ប្រជាពលរដ្ឋក្នុងការអនុវត្តគម្រោង ដើម្បីឱ្យគម្រោងមាននិរន្តរភាព និងមានទទួលខុសត្រូវក្នុងការដឹកនាំ៕

**<u>ព័ត៌មានទំនាក់ទំនង</u>**

- **ចៅសង្កាត់**
- **លេខទូរស័ព្ទ៖ ០៩៧៦៥៨២៣២៣**

# ២៧. គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
# ក្រុងកំពត ខេត្តកំពត

## ១. សង្ខេបអំពីស្ថានភាពបញ្ហា

បញ្ហាសំរាម និងសំណល់រឹងទីប្រជុំជន កំពុងក្លាយជាបញ្ហាចម្បងមួយនៅក្នុងក្រុងកំពត ដោយបានធ្វើឱ្យប៉ះពាល់ដល់សោភ័ណភាព អនាម័យបរិស្ថាន និងសុខភាពរបស់ប្រជាពលរដ្ឋ ពិសេសប៉ះពាល់ដល់វិស័យទេសចរណ៍ ព្រោះក្រុងកំពតគឺជាទីក្រុងទេសចរណ៍ ដែលមានភ្ញៀវទេសចរជាតិ និងអន្តរជាតិចូលមកកំសាន្ត។ ដោយមើលឃើញផលប៉ះពាល់ដល់កំណើនភ្ញៀវទេសចរ និងដោយមានសំណូមពរពីប្រជាពលរដ្ឋ និងអាជីវករ រដ្ឋបាលក្រុងបានចាប់ផ្តើមអនុវត្តសាកល្បងក្នុងការប្រមូលសំរាម សំណល់រឹងទីប្រជុំជនច្រើនឆ្នាំមកហើយ ពិសេសបន្ទាប់ពីការដាក់ចេញអនុក្រឹត្យលេខ១១៣ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនចាប់ពីឆ្នាំ២០១៥ រហូតមកដល់បច្ចុប្បន្ន។

## ២. ដំណើរការអនុវត្ត និងលទ្ធផល

ផ្អែកលើអនុក្រឹត្យលេខ១១៣ ក្រុមប្រឹក្សាក្រុងបានសម្រេចឱ្យគណៈអភិបាលរៀបចំបង្កើតគណៈកម្មការគ្រប់គ្រងសំរាម សំណល់រឹង ដោយមានអភិបាលរងក្រុងមួយរូបជាប្រធាន នាយករដ្ឋបាល ប្រធានការិយាល័យអភិវឌ្ឍក្រុង ការិយាល័យជំនាញ និងចៅសង្កាត់ទាំងអស់របស់ក្រុងជាសមាជិក ។ គណៈកម្មការមានតួនាទីទំនាក់ទំនងជាមួយអ្នកម៉ៅការប្រមូលសំរាម លើកកម្ពស់ការអប់រំ ផ្សព្វផ្សាយ និងពង្រឹងការគ្រប់គ្រងសំរាម សំណល់រឹងក្នុងក្រុង រួមទាំងដាក់ចេញវិធានការផាកពិន័យចំពោះជនទាំងឡាយណាបោះចោលសំរាមតាមទីសាធារណៈ។ តាមរយៈការអនុវត្តគម្រោងនេះរដ្ឋបាលក្រុងទទួលបាននូវលទ្ធផលមួយចំនួនដូចជា៖ (១). បានបង្កើតក្រុមការងាររៀបចំសណ្តាប់ធ្នាប់ និងអនាម័យក្រុង (២).បានចុះកិច្ចសន្យាបណ្តោះអាសន្នជាមួយក្រុមហ៊ុនហ្គាអៀរ ដើម្បីធ្វើការប្រមូលសំរាមនៅក្នុងក្រុងកំពត ដោយកំណត់ពេលវេលាឱ្យក្រុមហ៊ុនទទួលបានការប្រមូលសំរាមតាមផ្លូវសំខាន់ៗ០៦ដងក្នុងមួយសប្តាហ៍ ផ្លូវខាងក្នុង០៣ដងក្នុងមួយប្តាហ៍ និងតំបន់ឆ្ងាយ០២ដងក្នុងមួយសប្តាហ៍ (៣). បានធ្វើការសហការជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលមានដូចជា អង្គការអភិរក្សនិងការពារធនធានធម្មជាតិ អង្គការយូអិនអេសស្កាស អង្គការស្កាវ៉ូ អង្គការតម្លាភាពកម្ពុជា ជាដើម ដើម្បីធ្វើការផ្សព្វផ្សាយអំពីអនាម័យ និងបរិស្ថានជូនប្រជាពលរដ្ឋនៅក្នុងក្រុងកំពត ផ្តល់ការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរបស់រដ្ឋបាលក្រុងក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងបានជួយបង្កើតមណ្ឌលកែច្នៃជីកំប៉ុស ដែលអាចផលិតជីបានប្រមាណ៣តោនក្នុងមួយខែ (៤). បានផ្សព្វផ្សាយអំពីអនាម័យ និងបរិស្ថានតាមរយៈឧឃោសនស័ព្ទ តាមវិទ្យុជារៀងរាល់ថ្ងៃ តាមសង្កាត់ទាំង០៥ ចំនួន០២ដងក្នុងមួយសប្តាហ៍ (៥). បានសម្របសម្រួលឱ្យសង្កាត់នីមួយៗមានរ៉ឺម៉កម៉ូតូដឹកសំរាមចំនួន០១គ្រឿង (៦). រដ្ឋបាលក្រុងបានចុះកិច្ចព្រមព្រៀងជាមួយក្រុមយុវជនស្រលាញ់សន្តិភាព និងស.ស.យ.ក ដើម្បីធ្វើការប្រមូលសំរាមក្នុងក្រុងចំនួន០២ដងក្នុងមួយសប្តាហ៍ (៧). បានរៀបចំទូកុងថេន័រចំនួន០២សម្រាប់

ចាក់ទុកដាក់សំរាមបណ្តោះអាសន្នដែលមានទីតាំងនៅផ្សារកំពត។ តាមរយៈសកម្មភាពខាងលើនេះ ឥរិយាបថរបស់ប្រជាពលរដ្ឋមានការផ្លាស់ប្តូរ និងការយល់ដឹងរបស់ប្រជាពលរដ្ឋកើនឡើងក្នុងការទុកដាក់សំរាម និងការបង់កម្រៃសេវាប្រមូលសំរាម។

## ៣. បទពិសោធន៍ និងបញ្ហាប្រឈម

តាមរយៈការអនុវត្តគម្រោងនេះរដ្ឋបាលក្រុងទទួលបានបទពិសោធន៍មួយចំនួនដូចជា៖ (១). សមត្ថភាពក្នុងការសម្របសម្រួលជាមួយប្រជាពលរដ្ឋ ក្រុមហ៊ុនទទួលការ និងអង្គការដៃគូនានាកាន់តែប្រសើរឡើង (២). សមត្ថភាព និងការយល់ដឹងរបស់ក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីក្នុងការអប់រំផ្សព្វផ្សាយ អំពីអនាម័យ បរិស្ថាន ការពង្រឹងវិធានការនានា និងការសម្របសម្រួលដោះស្រាយមានការកើនឡើង (៣). បង្កើនការយល់ដឹងអំពីភាពជាដៃគូ និងភាពបត់បែនដែលត្រូវមានការសហការគ្នាជាមួយអ្នកពាក់ព័ន្ធនានា ពិសេសការធ្វើជាដៃគូជាមួយវិស័យឯកជន។

ក្នុងការអនុវត្តការងារ រដ្ឋបាលក្រុងបានជួបបញ្ហាប្រឈមមួយចំនួនដូចជា៖ (១). ក្រុងមិនទាន់មានទីលានចាក់សំរាមរបស់ខ្លួន (២). មានការពិបាកក្នុងការប្រមូលកម្រៃសេវាប្រមូលសំរាមប្រជាពលរដ្ឋដែលបានបង់ថ្លៃសេវាមានតែ៤៨%ប៉ុណ្ណោះជូនក្រុមហ៊ុនទទួលការប្រមូលសំរាម (៣). សំរាមសំណល់រឹងទីប្រជុំជនមានការកើនឡើងជាលំដាប់ ដែលធ្វើឱ្យក្រុមហ៊ុនទទួលការមិនអាចប្រមូលសំរាមបានតាមកិច្ចសន្យា។

## ៤. សក្តានុពលក្នុងការពង្រីកការអនុវត្តទៅទីកន្លែងផ្សេងទៀត

គម្រោងនេះ អាចអនុវត្តនៅគ្រប់ទីប្រជុំជន ហើយរដ្ឋបាល ត្រូវយកចិត្តទុកដាក់ចំណុចមួយចំនួន៖(១). ត្រូវមានទីតាំងទំហំសមស្រប ឬសហការជាមួយរដ្ឋបាលផ្សេងសម្រាប់ទុកដាក់សំរាម (២). ត្រូវមានការអប់រំផ្សព្វផ្សាយអំពីអនាម័យ និងបរិស្ថានឱ្យបានទៀងទាត់ រួមទាំងការអនុវត្តវិធានការពិន័យឱ្យបានម៉ឺងម៉ាត់និងជាប្រចាំ (៣). ត្រូវបង្កើតគណៈកម្មការ ឬក្រុមការងារអនុវត្តគម្រោងឱ្យបានច្បាស់លាស់ (៤). ត្រូវធ្វើការសហការជាមួយអង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធនានាក្នុងការអនុវត្តគម្រោង (៥). រដ្ឋបាលត្រូវមានសិទ្ធិចុះកិច្ចសន្យាផ្ទាល់ជាមួយក្រុមហ៊ុនដែលមានសមត្ថភាព ធនធាន និងបច្ចេកទេសក្នុងការអនុវត្តកិច្ចសន្យា (៦). ត្រូវធ្វើការកំណត់ម៉ោងពេល ក្នុងការប្រមូល និងបញ្ចេញសំរាម និងតាមដានការអនុវត្តឱ្យបានជាប្រចាំ (៧). ត្រូវរៀបចំឱ្យមានទីតាំងទុកដាក់សំរាមបណ្តោះអាសន្ន សម្រាប់ប្រជាពលរដ្ឋដែលស្ថិតនៅតាមដងផ្លូវដែលរថយន្តប្រមូលសំរាមមិនអាចចូលបាន៕

<u>**ព័ត៌មានទំនាក់ទំនង**</u>

- **នាយករដ្ឋបាលសាលាក្រុង៖ ស្វាយ មិត្ត**
- **លេខទូរស័ព្ទ៖ ០១២៥៩៣០៤៩**

# ២៨. ការស្តារប្រឡាយស្រោចស្រព សង្គ្រោះស្រូវ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង

## ១. សង្ខេបអំពីស្ថានភាពបញ្ហា

ជីវភាពប្រជាពលរដ្ឋស្រុកស្វាយអន្ទរភាគច្រើន ពឹងផ្អែកជាចម្បងលើការប្រកបរបរកសិកម្ម ពិសេសដំណាំស្រូវ និងក្រោយពេលប្រមូលផលស្រូវរួច កសិករមួយចំនួនបានដាំដំណាំអំពៅ ដំណាំឈូក ដំណាំឱឡឹក និងបន្លែរួមផ្សំផ្សេងៗសម្រាប់លក់ដូរ។ ក្នុងឆ្នាំ២០១៨កន្លងមក ប្រជាពលរដ្ឋនៅក្នុងស្រុក បានជួបប្រទះគ្រោះរាំងស្ងួតធ្ងន់ធ្ងរ ហើយប្រឡាយតូចៗដែលបំបែកចេញពីប្រឡាយមេក៏ពុំអាចបម្រើការស្រោចស្រពសង្គ្រោះស្រូវ និងដំណាំផ្សេងៗរបស់ប្រជាពលរដ្ឋបាន ដោយសារប្រព័ន្ធប្រឡាយតូចៗភាគច្រើនគោករាក់ និងខ្វះប្រភពនាំទឹក ព្រោះពុំមានការស្តារ និងថែទាំជាប្រចាំ ដែលធ្វើឱ្យប្រជាពលរដ្ឋមួយចំនួនត្រូវប្រឈមនឹងការខូចខាតដំណាំស្រូវ និងចំការអំពៅ ធ្វើឱ្យប៉ះពាល់ដល់ជីវភាពគ្រួសារ និងសេដ្ឋកិច្ចនៅក្នុងមូលដ្ឋាន។ ដោយមានការព្រួយបារម្ភខ្លាំងចំពោះការបាត់បង់ផលដំណាំរបស់ខ្លួន ប្រជាពលរដ្ឋក្នុងឃុំមួយចំនួនក្នុងស្រុកស្វាយអន្ទរ បានលើកសំណើតាមរយៈអាជ្ញាធរភូមិ ឃុំ ហើយរដ្ឋបាលស្រុកក៏បានបញ្ចូលសកម្មភាពនេះទៅកម្មវិធីវិនិយោគរបស់ស្រុក។ ផ្អែកតាមតម្រូវការចាំបាច់ និងបន្ទាន់ រដ្ឋបាលស្រុកបានសម្រេចស្តារប្រឡាយ១ក្នុងចំណោមប្រឡាយតូចៗជាច្រើនគឺប្រឡាយសំរោង ដែលផ្តល់ផលដល់ប្រជាពលរដ្ឋនៅក្នុងឃុំ២គឺឃុំសំរោង និងឃុំដំរីពួន ហើយដែលត្រូវចំណាយពេលជិត១ខែទើបបានបញ្ចប់។

## ២. ដំណើរការអនុវត្ត និងលទ្ធផល

ក្នុងការអនុវត្តការប្រឡាយនេះ រដ្ឋបាលស្រុកបានសម្រេចបង្កើតក្រុមការងារបន្ទុកការស្តារប្រឡាយ ដោយមានអភិបាលរងស្រុកទទួលបន្ទុកសេដ្ឋកិច្ច១រូប ជាប្រធានក្រុមការងារ និងមានសមាជិកក្រុមប្រឹក្សាស្រុក ប្រធានការិយាល័យផែនការនិងគាំទ្រឃុំ ការិយាល័យធនធានទឹក កសិកម្ម មេឃុំពាក់ព័ន្ធ និងមេភូមិមួយចំនួនដែលពាក់ព័ន្ធនឹងប្រឡាយដែលត្រូវស្តារ ជាសមាជិក។ ក្រុមការងារនេះមានតួនាទីក្នុងការសម្របសម្រួល ជំរុញការចូលរួម និងរាយការណ៍មកថ្នាក់ដឹកនាំស្រុក រាល់បញ្ហានានាដែលពាក់ព័ន្ធក្នុងមូលដ្ឋានស្រុក។ ក្រុមការងារបានធ្វើការងារជាមួយប្រជាពលរដ្ឋដែលពាក់ព័ន្ធ ក្នុងប្រមូលទិន្នន័យសំខាន់ៗដូចជា ចំនួនប្រជាជនដែលទទួលផលពីប្រឡាយ ចំនួនផ្ទៃដីដាំដុះ (ទាំងដំណាំស្រូវ ដំណាំចំការ) ប្រភេទដំណាំ ទំហំប៉ាន់ស្មានធនធានដែលប្រជាជនបានរងផលប៉ះពាល់ពីគ្រោះរាំងស្ងួត។ រីឯថ្នាក់ដឹកនាំរដ្ឋបាលស្រុក (ទាំងក្រុមប្រឹក្សា និងអភិបាលស្រុក) បានដើរតួនាទីក្នុងការទំនាក់ទំនង និងពិភាក្សាស្នើការគាំទ្រពីមន្ទីរធនធានទឹកខេត្ត ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានស្រុក ក្នុងការស្តារប្រឡាយនេះ។ ដោយសារមូលនិធិស្រុក ពុំមានគ្រប់គ្រាន់សម្រាប់ប្រើប្រាស់លើគម្រោងនេះ រដ្ឋបាលស្រុកស្នើសុំ និងទទួលបានការគាំទ្រជាគ្រឿងចក្រ មន្ត្រីបច្ចេកទេស ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន

បានជួយជាប្រេងសាំងសម្រាប់គ្រឿងចក្រ ប្រជាពលរដ្ឋបានចូលរួមជាកម្លាំងពលកម្ម ប្រេងសាំង ហើយរដ្ឋបាលស្រុកបានចូលរួមថវិកា១លានរៀល សម្រាប់គាំទ្រជាប្រេងសាំង។ ក្នុងការអនុវត្ត ក្រុមការងារបន្ទុកការស្តារប្រឡាយតែងរាយការណ៍ និងស្នើសុំការគាំទ្រពីក្រុមប្រឹក្សាស្រុករាល់កិច្ចប្រជុំពាក់ព័ន្ធនានា ហើយថ្នាក់ដឹកនាំរដ្ឋបាលស្រុកតែងចុះពិនិត្យផ្ទាល់នៅទីតាំងក្នុងពេលដំណើការស្តារប្រឡាយ។

តាមរយៈកិច្ចខិតខំប្រឹងប្រែង និងការគាំទ្ររបស់រដ្ឋបាលស្រុក ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា ក្នុងការអនុវត្តគម្រោងនេះ បានសម្រេចនូវលទ្ធផល រួមមាន៖ ស្តារប្រឡាយប្រវែង៦,៥គ.ម កាត់ ២ឃុំ (ទំហំមាត់លើ៣ម បាតក្រោម១,៥ម) បានសង្គ្រោះស្រូវចំនួនប្រមាណ៨០០ហ.ត ក្នុងឆ្នាំ ២០១៨ ដែលប្រជាជនទទួលផលមានចំនួនប្រមាណ ១.០០០គ្រួសារ ហើយតាមរយៈប្រឡាយស្រោចស្រពដែលបានស្តាររួច ប្រជាពលរដ្ឋមួយចំនួនអាចធ្វើស្រែបាន២ទៅ៣ដងហើយអាចប្រើប្រាស់សម្រាប់ដំណាំ និងបន្លែផ្សេងៗទៀតសម្រាប់ទីផ្សារផងដែរ។

## ៣. បទពិសោធន៍ និងបញ្ហាប្រឈម

ការអនុវត្តគម្រោងនេះ បានផ្តល់បទពិសោធន៍មួយចំនួន ដូចជា៖(១). ការយល់ដឹងអំពីការចាត់អាទិភាពនៃបញ្ហា និងអត្ថប្រយោជន៍នៃការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ផ្អែកតាមសំណើជាតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋមូលដ្ឋាន (២).យល់ដឹងអំពីភាពចាំបាច់នៃការសម្របសម្រួលជាមួយប្រជាពលរដ្ឋក្នុងការបែងចែកទឹកសម្រាប់ស្រោចស្រពឱ្យបានសមស្របនិងសមធម៌ ព្រោះប្រសិនពុំមានគោលការណ៍ និងសិទ្ធចាត់ចែងរបស់រដ្ឋបាលស្រុក នោះអាចនាំឱ្យមានការថ្នាំងថ្នាក់ និងជម្លោះរវាងប្រជាពលរដ្ឋជាមួយប្រជាពលរដ្ឋ និងរវាងប្រជាពលរដ្ឋជាមួយអាជ្ញាធរ (៣). លើកកម្ពស់សមត្ថភាពក្នុងការសម្របសម្រួល និងបញ្ចុះបញ្ចូលឱ្យមានការគាំទ្រ ជំរុញ និងសម្របសម្រួលពីក្រុមការងារថ្នាក់ជាតិ មន្ទីរធនធានទឹក ហើយមានការចូលរួមពីប្រជាពលរដ្ឋទាំងកម្លាំងពលកម្ម និងសម្ភារៈ។

ទោះបីយ៉ាងណាក៏ដោយ រដ្ឋបាលស្រុកបានប្រឈមនឹងបញ្ហាខ្វះធនធានថវិកាផ្ទាល់ ព្រោះថវិការបស់រដ្ឋបាលស្រុកត្រូវបានអនុម័តនៅដើមឆ្នាំសម្រាប់អនុវត្តគម្រោងអាទិភាពផ្សេងទៀត រីឯតម្រូវការក្នុងការស្តាប្រឡាយស្រោចស្រពនេះ បានស្នើឡើងបន្ទាន់ព្រោះជាបញ្ហាចាំបាច់ដែលត្រូវដោះស្រាយបន្ទាន់ក្នុងការសង្គ្រោះស្រូវ និងដំណាំផ្សេងៗរបស់ប្រជាពលរដ្ឋ ហើយស្រុកមិនអាចធ្វើវិសោធនកម្មភ្លាមៗបានទាន់ពេលវេលា។ ម្យ៉ាងទៀត រដ្ឋបាលស្រុកពុំមានដៃគូ ឬអង្គការមិនមែនរដ្ឋាភិបាលធ្វើការក្នុងមូលដ្ឋានគាំទ្រ។

## ៤. សក្តានុពលក្នុងការពង្រីកការអនុវត្តទៅទីកន្លែងផ្សេងទៀត

រដ្ឋបាលក្រុង ស្រុក ដែលមានបំណងអនុវត្តគម្រោងប្រហាក់ប្រហែលនេះ ត្រូវមានការគិតគូរពិចារណាលើតម្រូវការទឹក ប្រភពទឹក ទំហំដីស្រែ ដីចំការដែលត្រូវសង្គ្រោះ បរិមាណស្រូវ និងដំណាំផ្សេងៗទៀត ដែលអាចរងផលប៉ះពាល់ខូចខាត និងបរិមាណស្រូវដែលអាចសង្គ្រោះបាន ធៀបនឹង

ទំហំនៃការចំណាយធនធាន ហើយតម្រូវឱ្យមានការចូលរួមគាំទ្របច្ចេកទេសពីអង្គភាពជំនាញគឺមន្ទីរធនធានទឹក។

ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តគម្រោងប្រហាក់ប្រហែលនេះ រដ្ឋបាលក្រុង ស្រុក ចាំបាច់ត្រូវមានការចាត់តាំងក្រុមការងារទទួលបន្ទុកច្បាស់លាស់ ដែលមានតំណាងរដ្ឋបាលស្រុកជាអ្នកសម្របសម្រួលជាមួយអង្គភាពជំនាញ និងយន្តការគាំទ្រដ៏ទៃទៀតដូចជាក្រុមការងារថ្នាក់ជាតិ ការសម្របសម្រួលជាមួយរដ្ឋបាលឃុំ អាជ្ញាធរភូមិ និងប្រជាពលរដ្ឋ ការកៀរគរសម្របសម្រួលជាមួយអង្គភាពជំនាញពាក់ព័ន្ធ ហើយនៅពេលប្រើប្រាស់ទឹកស្រោចស្រពត្រូវមានការចូលរួមសម្របសម្រួលបែងចែកទឹក និងការដោះស្រាយជម្លោះផ្សេងៗពាក់ព័ន្ធការប្រើប្រាស់ទឹកស្រោចស្រពនេះ។

**ព័ត៌មានទំនាក់ទំនង**

- **នាយករដ្ឋបាលសាលាស្រុក៖ ហុក ម៉ិច**
- **លេខទូរស័ព្ទ៖ ០៨៨២២២៩៩៨៤**

# ២៩. និរន្តរភាពអនាម័យដើម្បីឆាំងរស់គ្នា

# ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ

## ១. សង្ខេបអំពីស្ថានភាពបញ្ហា

បញ្ហាអនាម័យនៅតាមសហគមន៍ និងការខ្វះបង្គន់អនាម័យជាបញ្ហាសំខាន់ក្នុងចំណោមបញ្ហាសំខាន់ៗរបស់ស្រុកបរសេដ្ឋ ដែលបញ្ហានេះកើតឡើងដោយសារប្រជាពលរដ្ឋមួយចំនួននៅតែបន្ទបន្ទោរបង់នៅតាមទីវាល និងគុម្ពោតព្រៃក្បែរៗផ្ទះ ដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់ពួកគាត់។ ពិសេសកុមារនៅក្នុងសហគមន៍ ដែលបង្កជាជម្ងឺរាគរូស អាសន្នរោគ និងជម្ងឺផ្សេងៗ។ ដោយមើលឃើញថាបញ្ហាបន្ទោរបង់ពាលវាលពាសកាលបែបនេះបង្ករជាបញ្ហាច្រើនដល់សុខភាព មណ្ឌលសុខភាពបានលើកបញ្ហានេះមកពិភាក្សាក្នុងកិច្ចប្រជុំប្រចាំខែរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារស្រុក (គ.ក.ស.ក) ព្រមទាំងបានបញ្ចូលនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្រុក ហើយបានកំណត់បញ្ហាអនាម័យនៅតាមសហគមន៍ជាអាទិភាពដែលត្រូវដោះស្រាយ។ នៅឆ្នាំ២០១៥ ដោយមានការស្នើសុំពីរដ្ឋបាលស្រុក អង្គការយូនីសេហ្វបានគាំទ្រការអនុវត្តសកម្មភាពការលើកកម្ពស់ការយល់ដឹងអំពីអនាម័យនៅតាមសហគមន៍ ដោយអនុវត្តទៅឃុំចំនួន០២ ដោយបានផ្តោតជាសំខាន់ទៅលើការអប់រំ ផ្សព្វផ្សាយអំពីផលវិបាកដែលកើតពីការបន្ទោរបង់តាមទីសាធារណៈ។ ដោយទទួលលទ្ធផលបានល្អក្នុងការលើកកម្ពស់ការយល់ដឹងអំពីអនាម័យនៅតាមសហគមន៍ ចាប់ពីឆ្នាំ២០១៧ ដល់បច្ចុប្បន្ន រដ្ឋបាលស្រុកបានសហការ និងមានការគាំទ្រពីថវិកានិងបច្ចេកទេសពីអង្គការ SNV រដ្ឋបាលស្រុកបានពង្រីកសកម្មភាពនេះនៅគ្រប់ឃុំទូទាំងស្រុក។

## ២. ដំណើរការអនុវត្ត និងលទ្ធផល

ក្នុងការគ្រប់គ្រងសកម្មភាពនេះ រដ្ឋបាលស្រុកបានបង្កើតគណៈកម្មការដែលដឹកនាំដោយអភិបាលរងស្រុក១រូប ដោយមានការចូលរួមពីគ.ក.ស.ក មណ្ឌលសុខភាព និងការិយាល័យពាក់ព័ន្ធ ដោយបានប្រមូលព័ត៌មាន បញ្ហាសុខភាព តម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ និងបានធ្វើការស្វែងរកការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាលនានា ដែលកំពុងអនុវត្តកម្មវិធីរបស់ខ្លួនក្នុងដែនសមត្ថកិច្ចរបស់ស្រុក ហើយទទួលបានការគាំទ្រពីអង្គការ**យូនីសេហ្វ** និងអង្គការ SNV ដែលអនុវត្តសកម្មភាពលើកកម្ពស់អនាម័យជនបទ។ គណៈកម្មការនេះ សហការជាមួយអ្នកពាក់ព័ន្ធនានាពិសេសអាជ្ញាធរឃុំ ភូមិ ក្នុងការរៀបចំផែនការសកម្មភាពនិងថវិកាសម្រាប់អនុវត្ត កំណត់ក្រុមគោលដៅសម្រាប់ការអប់រំផ្សព្វផ្សាយអំពីផលវិបាកបណ្តាលពីការបន្ទោរបង់តាមទីសាធារណៈ និងអត្ថប្រយោជន៍នៃការប្រើប្រាស់បង្គន់អនាម័យតាមផ្ទះ។ គណៈកម្មការនេះ បានចាត់តាំងឱ្យមានក្រុមជនបង្គោលទទួលខុសត្រូវចុះអប់រំផ្សព្វផ្សាយនៅតាមលំនៅដ្ឋានផ្ទាល់របស់ក្រុមគោលដៅតូចៗ។ គណៈកម្មការនេះត្រូវរាយការណ៍ប្រចាំខែជូនគណៈអភិបាល និងក្រុមប្រឹក្សាស្រុក អំពីវឌ្ឍនភាពនិងប្រឈមនានា ជាមួយគ្នានេះ

ផងដែររដ្ឋបាលស្រុកបានកំណត់គោលដៅនៅឆ្នាំ២០១៩ គឺប្រជាពលរដ្ឋនៅតាមសហគមន៍ត្រូវមានបង្គន់អនាម័យគ្រប់ផ្ទះ។

តាមរយៈការអនុវត្តគម្រោងនេះរដ្ឋបាលសង្កាត់ទទួលបាននូវសមិទ្ធផលមួយចំនួនដូចជា៖ (១). ប្រជាពលរដ្ឋមានការយល់ដឹងតាមរយៈការអប់រំ ផ្សព្វផ្សាយអំពីសារសំខាន់បញ្ហាអនាម័យ និងបរិស្ថាន (២). ប្រជាពលរដ្ឋបានចំណាយថវិកាក្នុងការសាងសង់បង្គន់អនាម័យប្រើប្រាស់តាមផ្ទះរៀងៗខ្លួនចំនួន២៦.៤៤៤ ជាបង្គន់ចាក់ទឹក និង ២.២១១ជាបង្គន់ស្ងួត (៣). ស្រុកទទួលបានចំណាត់ថ្នាក់ជាស្រុកដែលមិនមានការបន្ទោរបង់ដោយគ្មានបង្គន់អនាម័យ(៤). ស្ថានភាពសុខភាពនិងជីវភាពរបស់ប្រជាពលរដ្ឋបានល្អប្រសើរជាងមុន (៥). ប្រជាពលរដ្ឋមានការពេញចិត្ត និងគាំទ្រលើរដ្ឋបាលស្រុកក្នុងការអនុវត្តសកម្មភាពនេះ។

## ៣. បទពិសោធន៍ និងបញ្ហាប្រឈម

តាមរយៈការអនុវត្តគម្រោងនេះរដ្ឋបាលស្រុក ទទួលបាននូវបទពិសោធន៍មួយចំនួនដូចជា៖ (១). មានការយល់ដឹងអំពីវិធីសាស្ត្រ និងរបៀបរបបក្នុងការទំនាក់ទំនង និងកៀរគរធនធានសម្រាប់អនុវត្តសកម្មភាព (២). មានសមត្ថភាពក្នុងការសម្របសម្រួល សហការ និងធ្វើការជាមួយសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល និងប្រជាពលរដ្ឋ (៣). ផ្តល់ការគាំទ្រនិងសម្របសម្រួលឱ្យប្រជាពលរដ្ឋដែលសកម្មនៅតាមសហគមន៍ដើម្បីផ្តល់ការអប់រំផ្សព្វផ្សាយផ្ទាល់ជាមួយប្រជាពលរដ្ឋគោលដៅ (៤). ប្រជាពលរដ្ឋកាន់តែមានជំនឿលើអាជ្ញាធរ និងរដ្ឋបាលស្រុក តាមរយៈការអនុវត្តសកម្មភាពប្រកបដោយតម្លាភាព និងមានការលើកទឹកចិត្តចំពោះប្រជាពលរដ្ឋដែលខិតខំប្រឹងប្រែង តាមរយៈការផ្តល់សម្ភារៈសម្រាប់រៀបចំបង្គន់។

ការអនុវត្តគម្រោងនេះ រដ្ឋបាលស្រុកនៅតែជួបនូវបញ្ហាប្រឈមមួយចំនួនដូចជា ថវិកាសម្រាប់អភិវឌ្ឍរបស់ស្រុកមានចំនួនតិច ហើយនៅពឹងផ្អែកលើការគាំទ្ររបស់ដៃគូ (អង្គការមិនមែនរដ្ឋាភិបាល) ក្នុងការគាំទ្រដល់ការផ្សព្វផ្សាយ ការផ្តល់សម្ភារៈសម្រាប់សាងសង់បង្គន់។

## ៤. សក្តានុពលក្នុងការពង្រីកការអនុវត្តទៅទីកន្លែងផ្សេងទៀត

គម្រោងនិរន្តរភាពអនាម័យដើម្បីទាំងអស់គ្នានេះគឺជាគម្រោងដែលមានលក្ខណៈល្អ និងអាចជាមេរៀនសម្រាប់រដ្ឋបាលផ្សេងទៀតព្រោះ គម្រោងនេះមានលក្ខណៈជាគម្រោងសេវាសង្គម ដែលផ្តោតលើការងារអនាម័យ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ។ រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានបំណងអនុវត្តសកម្មភាពប្រហាក់ប្រហែលនេះ ត្រូវពិចារណានូវចំណុចមួយចំនួនមុននឹងអនុវត្ត៖ (១). ការអនុវត្តគម្រោងបែបនេះ តម្រូវឱ្យមានការសហការយ៉ាងជិតស្និត ដោយការបង្កើតក្រុមការងាររួមគ្នារវាងរដ្ឋបាលស្រុក ជាមួយរដ្ឋបាលឃុំ ឬអាជ្ញាធរភូមិ (២). ធ្វើការអប់រំប្រជាពលរដ្ឋអំពីអនាម័យ និងបរិស្ថានឱ្យបានញឹកញាប់ ការចំណាយក្នុងការអនុវត្តគម្រោងប្រជាពលរដ្ឋជាអ្នកចំណាយលើការងារសាងសង់ ១០០% (៣). គួរដាក់បញ្ចូលគម្រោងទៅក្នុងកម្មវិធីវិនិយោគ០៣ឆ្នាំរំកិលរបស់ខ្លួន (៤). ការ

ផ្សព្វផ្សាយត្រូវដឹកនាំដោយប្រជាពលរដ្ឋសកម្មនិងចុះអនុវត្តដោយផ្ទាល់ (៥). ត្រូវមានបដិភាគរបស់ប្រជាពលរដ្ឋក្នុងការអនុវត្តគម្រោង ដើម្បីឱ្យគម្រោងមាននិរន្តរភាព និងមានការចូលរួម (៦). គួរជ្រើសរើសប្រជាពលរដ្ឋដែលធ្លាប់តែជាអ្នកតែងតែបន្ទោរបង់តាមទីសាធារណៈ មកអប់រំឱ្យយល់ពីបញ្ហាសុខភាព អនាម័យ និងបរិស្ថាន រួចហើយជ្រើសរើសគាត់ជាជនបង្គោលក្នុងការអនុវត្តគម្រោង។

**<u>ព័ត៌មានទំនាក់ទំនង</u>**

- **នាយករដ្ឋបាលសាលាស្រុក**
- **លេខទូរស័ព្ទ៖ ០១៥ ៤០០ ៤២៧**

បោះពុម្ពដោយលេខាធិការដ្ឋាន គ.ជ.អ.ប.

គាំទ្រដោយកម្មវិធីកំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល (DAR)